អង្គការពលកម្មអន្តរជាតិ

# ការអនុវត្តល្អ
# ដើម្បីដោះស្រាយពលកម្មកុមារនៅកម្ពុជា



កម្មវិធីអន្តរជាតិស្តីពីការ
លុបបំបាត់ពលកម្មកុមារ
**(IPEC)**

ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
អង្គការពលកម្មអន្តរជាតិ ( ILO )

# ការអនុវត្តល្អ
# ដើម្បីដោះស្រាយពលកម្មកុមារនៅកម្ពុជា

កម្មវិធីអន្តរជាតិស្តីពី
ការលុបបំបាត់ពលកម្មកុមារ
(IPEC)

ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
អង្គការពលកម្មអន្តរជាតិ ( ILO )

រក្សាសិទ្ធិដោយ អង្គការពលកម្មអន្តរជាតិ ឆ្នាំ 2014
បោះពុម្ពលើកទី១ ឆ្នាំ 2014

ការបោះពុម្ពរបស់អង្គការពលកម្មអន្តរជាតិបានទទួលការរក្សាសិទ្ធិក្រោមពិធីសារលេខ២ នៃសិទ្ធិសញ្ញារក្សាសិទ្ធិជាសកល។ ទោះជាយ៉ាងនេះក្តី ការដកស្រង់ខ្លីៗ ពីឯកសារនេះយកទៅផ្សាយបន្ត អាចធ្វើទៅបាន ដោយមិនបាច់មានការអនុញ្ញាតជាមុន តែចាំបាច់ត្រូវបញ្ជាក់ប្រភពសម្រង់សេចក្តីទាំងនោះ។ សម្រាប់សិទ្ធិនៃការបកប្រែ ឬការផលិតឡើងវិញ ការស្នើសុំ ត្រូវធ្វើទៅកាន់ការិយាល័យបោះពុម្ពរបស់អង្គការ ILO (សិទ្ធិនិងការអនុញ្ញាតិ) ការិយាល័យ អង្គការពលកម្មអន្តរជាតិ CH-1211 ហ្សឺណែវ 22 ស្វីហ្សឺឡែន ឬ តាមរយៈអ៊ីម៉ែល: pubdroit@ilo.org។ ការិយាល័យអង្គការពលកម្មអន្តរជាតិស្វាគមន៍ការស្នើសុំបែបនេះ។

បណ្ណាល័យ ស្ថាប័ននានា និង អ្នកប្រើប្រាស់ដ៏ទៃទៀត ដែលបានចុះឈ្មោះជាមួយអង្គភាពសុំសិទ្ធិ ផលិតឡើងវិញ អាចធ្វើការថតចំលង ដោយយោងទៅតាមអាជ្ញាប័ណ្ណដែលអនុញ្ញាតិអោយសម្រាប់គោលបំណងនេះ។ សូមចូលទៅមើល www.ifrro.org ដើម្បីស្វែងរកអង្គភាព ដែលអាចសុំសិទ្ធិផលិតបាននៅក្នុងប្រទេសរបស់អ្នក។

---

**IPEC**

ការអនុវត្តល្អដើម្បីដោះស្រាយពលកម្មកុមារនៅកម្ពុជា/អង្គការពលកម្មអន្តរជាតិ កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC) - ភ្នំពេញ: ILO, 2014

ISBN:978-92-2-828985-5; 978-92-2-828986-2 (Web PDF)

International Labour Office; ILO International Programme on the Elimination of Child Labour/Child Labour/prevention/good practices/community participation/income generating activities/sectoral planning/Cambodia – 13.01.2

ក៏អាចរកបានជាភាសាអង់គ្លេស: Good practices for tackling child labour in Cambodia

ISBN: 978-92-2-128985-2; 978-92-2-128986-9 (Web PDF), Phnom Penh, 2014.

## សេចក្តីថ្លែងអំណរគុណ

ឯកសារនេះរៀបរៀងឡើងដោយអ្នកស្រី អាន ប៊ីស្ហប ( Ann Bishop ) សម្រាប់អង្គការ ILO-IPEC និង សម្របសម្រួល ដោយ អ៊ុក ស៊ីសុវណ្ណ ពីការិយាល័យអង្គការ ILO-IPEC នៅកម្ពុជា និង វ៉ាហ៊ីតជឺ រ៉ាមែន ( Wahidur Rahman ) ពីអង្គការ ILO-IPEC ប្រចាំនៅហ្សឺណែវ។

អ្នកស្រី អាន ប៊ីស្ហប សូមថ្លែងអំណរគុណដល់លោកជំទាវ ប្រាក់ ចន្ថា និង ឯកឧត្តម ម៉ៅ សម្បត្តិ មកពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលធ្វើជាគណៈអធិបតីក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត និង ថ្នាក់ជាតិលើរបាយការណ៍នេះ។ លោក វ៉េង ហៀង និង តាំង សុភ័ក្រ្ត មកពីនាយកដ្ឋានពលកម្មកុមារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានរៀបចំ កិច្ចពិគ្រោះយោបល់ និង បានរួមចំណែកជួយជ្រោមជ្រែងកិច្ចការ ដ៏មានតម្លៃឯទៀត។ លោក ស្ទីវ ហ្គោឡេ ( Steve Gourlay ) និង មីឡេត ហ្គោដាត ( Milete Godard ) ដែលបានផ្តល់ របាយការណ៍សិក្សាស្រាវជ្រាវ និងយោបល់ លោក ម៉ាយខល វ៉ាយល៍ ( Michael Wild ) ដែលផ្តល់រូបថតមួយចំនួន និង លោក សំរឹត សុផា លោក ជឹម ចរណៃ និងលោក សុក សូមិត្ត ដែលបានផ្តល់ការបកប្រែលើឯកសារនេះ។

អ្នកពិគ្រោះយោបល់ក៏សូមថ្លែងអំណរគុណផងដែរដល់អតីតបុគ្គលិក និង បុគ្គលិកបច្ចុប្បន្នរបស់អង្គការ ILO-IPEC ចំពោះការណែនាំ ការផ្តល់យោបល់ និង ការជួយគាំទ្រដ៏ថ្លៃថ្លាមាន៖ លោក អ៊ុក ស៊ីសុវណ្ណ ស៊ឹមរីន ស៊ីង ( Simrin Singh ) ខេត ជេឌ័រ ហ្វីស្ជើរ( Keith Jeddere-Fisher ) ន័រជីងខាម ម៉ុងហ្គោលម៉ា ( Norjinlkham Mongolmaa ) លោក សៅ កុសល លោកហ៊ុន សាវុឌ្ឍ លោក អោម សុវណ្ណារុធ លោក អ៊ុន វុទ្ធីនិង អ្នកស្រី ហេង សុថាវី។

ថវិការសម្រាប់បោះពុម្ពរបាយការណ៍នេះត្រូវបានផ្តល់ដោយក្រសួងការងារសហរដ្ឋអាមេរិកក្រោមគំរោងCMB/08/50/USA។

របាយការណ៍នេះមិនឆ្លុះបញ្ចាំងពីទស្សនៈឬគោលនយោបាយរបស់ក្រសួងការងារសហរដ្ឋអាមេរិក ឬក៏ឈ្មោះពាណិជ្ជកម្ម ផលិតផលពាណិជ្ជកម្ម ឬ ក៏អង្គភាព បញ្ជាក់ពីការគាំទ្រដោយរដ្ឋាភិបាលសហរដ្ឋអាមេរិកទេ ។

ការពិពណ៌នានៅក្នុងឯកសារបោះពុម្ពដោយអង្គការ ILO ដែលស្របជាមួយការអនុវត្តរបស់អង្គការសហប្រជាជាតិ និងការបង្ហាញនូវឯកសារនៅទីនេះមិនបញ្ជាក់ពីទស្សនៈរបស់អង្គការពលកម្មអន្តរជាតិទាក់ទងនឹងស្ថានភាពច្បាប់នៃប្រទេសណាមួយតំបន់ ឬ ក៏ដែនដី ឬ ក៏អាជ្ញាធរ ឬ ទាក់ទងនឹងការកំណត់ព្រំដែនរបស់ខ្លួនទេ។

ការទទួលខុសត្រូវលើទស្សនៈដែលបរិយាយនៅក្នុងឯកសារដែលចុះហត្ថលេខានេះការសិក្សានិងការរួមចំណែកផ្សេងៗទៀតគឺជាទស្សនៈរបស់អ្នកនិពន្ធហើយការបោះពុម្ពផ្សាយនូវទស្សនៈទាំងនេះមិនមែនជាទស្សនៈរបស់អង្គការ ILO ទេ។

សេចក្តីយោងទៅលើឈ្មោះរបស់ក្រុមហ៊ុន និង ផលិតផលដំណើរការពាណិជ្ជកម្ម មិនមានការបញ្ជាក់ពីការព្រមព្រៀងដោយអង្គការ ILO ហើយការដែលមិនបានលើកឡើងពីឈ្មោះ ក្រុមហ៊ុន ផលិតផល ពាណិជ្ជកម្ម ឬក៏ដំណើរការណាមួយនោះក៏ពុំមែនជាសញ្ញាថាគ្មានការឯកភាពដែរ។

ឯកសារបោះពុម្ពនិងជាសារអេឡិចត្រូនិចអាចរកបានតាមរយៈអ្នកលក់សៀវភៅមួយផ្នែកធំ ឬ ការិយាល័យអង្គការ ILO នៅក្នុងស្រុក ក្នុងប្រទេសមួយចំនួន ឬ ក៏ទាក់ទងដោយផ្ទាល់ជាមួយផ្នែកផ្សព្វផ្សាយរបស់អង្គការ ILO ការិយាល័យអង្គការ ILO, CH-1211 Geneva 22, Switzerland។ សៀវភៅគំរូឬក៏បញ្ជីនៃការបោះពុម្ពថ្មីៗ គឺអាចរកបានដោយមិនគិតថ្លៃពីអាស័យដ្ឋាន ខាងលើឬក៏តាមរយៈអ៊ីម៉ែលៈ pubvente@ilo.org ឬក៏ចូលទៅមើល website:www.ilo.org/publns.

**សូមចូលទៅមើល website: www.ilo.org/ipec**

រូបថតរក្សាសិទ្ធិដោយអង្គការ ILO 2014
បោះពុម្ពនៅកម្ពុជា

រូបថតរចនាដោយ Graphic Roots, Cambodia

# មាតិកា

ទំព័រ


៦ បុព្វកថា

៩ អក្សរកាត់

១១ សេចក្តីផ្តើម

១៥ ១- ការបង្កើតយន្តការសម្របសម្រួលពីថ្នាក់ជាតិដល់ថ្នាក់សហគមន៍ ដើម្បីលុបបំបាត់ពលកម្មកុមារនៅកម្ពុជា

២៧ ២- ប្រយុទ្ធប្រឆាំងពលកម្មកុមារជាមួយអ្នកត្រួតពិនិត្យពលកម្មកុមារ នៅសហគមន៍

៣៧ ៣- ការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលគ្រួសារ និងការផ្តល់សិទ្ធិ អំណាចដល់ស្ត្រីតាមរយៈក្រុមសន្សំ និងការបង្កើតប្រាក់ចំណូល

៤៣ ៤- ការលុបបំបាត់ពលកម្មកុមារប្រកបដោយជោគជ័យ ពីវិស័យផលិតកម្មអំបិលនៅកម្ពុជា

៥៣ ៥- ការបង្កើតផែនការសកម្មភាពទូលំទូលាយតាម វិស័យដើម្បីបញ្ចប់ពលកម្មកុមារ

# អារម្ភកថា

ចាប់ពីឆ្នាំ ២០០៤ កម្ពុជា នៅតែមានអត្រាពលកម្មកុមារខ្ពស់បំផុតមួយនៅក្នុងពិភពលោក ហើយក៏មានការចាប់អារម្មណ៍ច្រើនបំផុតដែរក្នុងការផ្តល់ការគាំទ្រហិរញ្ញវត្ថុ ដែលជួយឱ្យប្រទេសរបស់យើងធ្វើបានកាន់តែប្រសើរឡើងច្រើនអំពីស្ថានភាពនេះ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងមោះមុតពីសំណាក់មនុស្សរាប់រយនាក់ ចាប់តាំងពីគណៈរដ្ឋមន្ត្រីរហូតដល់ថ្នាក់ភូមិ ហើយដោយមានការគាំទ្របច្ចេកទេសពីកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារនៃអង្គការពលកម្មអន្តរជាតិ ( ILO-IPEC ) និងការគាំទ្រហិរញ្ញវត្ថុពីក្រសួងការងារនៃសហរដ្ឋអាមេរិក ( USDOL ) ដែលមានទឹកប្រាក់ចំនួន ៩,០៦ លានដុល្លារអាមេរិក សំរាប់ដំណាក់កាលទី១ និងទី២ (២០០៤-២០១២) ភាគីពាក់ព័ន្ធទាំងអស់បានសម្រេចសមិទ្ធផលយ៉ាងធំធេងក្នុងការលុបបំបាត់ពលកម្មកុមារនៅកម្ពុជា។

ទី១ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតផែនការសកម្មភាពជាតិ ច្បាប់ និងយន្តការអនុវត្តនានា ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ។ ទី២ រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក្រៅរដ្ឋាភិបាល បានបង្កើតនីតិវិធីដកហូតកុមារពីពលកម្ម សម្របសម្រួលកិច្ចខិតខំប្រឹងប្រែង និងពិនិត្យតាមដានទៅលើភាពជោគជ័យរបស់ពួកគេ ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ។ ទី៣ មូលហេតុ និងផលវិបាកនៃពលកម្មកុមារ និងវិធីបញ្ឈប់ពលកម្មកុមារនាពេលបច្ចុប្បន្នត្រូវបានគេយល់ដឹងយ៉ាងទូលំទូលាយនៅគ្រប់ស្រទាប់នៃសង្គម។ ទី៤ គំនិតផ្តួចផ្តើមនានា ដើម្បីទប់ស្កាត់ពលកម្មកុមារ បច្ចុប្បន្ននេះបានក្លាយទៅជាការងារស្នូលរបស់ស្ថាប័នជាច្រើនក្នុងរដ្ឋាភិបាល សហជីព ក្រុមហ៊ុនឯកជន ភ្នាក់ងារអនុវត្តច្បាប់ ស្ថាប័នសាសនា អង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិលនានាជាដើម។ ហើយភាគីពាក់ព័ន្ធទាំងអស់នេះ ជួបគ្នាជាទៀងទាត់ដើម្បីរាយការណ៍ពីការងាររបស់គេ និងជួយគ្នាដោះស្រាយបញ្ហា។

តាំងពីឆ្នាំ២០០៤មក កុមារជាង ៣១.០០០ នាក់ ត្រូវបានដកហូត ឬទប់ស្កាត់ពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ហើយត្រូវបានផ្តល់ការឧបត្ថម្ភគាំទ្រផ្នែកហិរញ្ញវត្ថុ សម្ភារៈ និង គាំទ្រផ្នែកសង្គមក្នុងខណៈដែលពួកគេកំពុងរៀន ឬចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈនានា។ លើសពីនេះទៀត ដើម្បីជួយដល់ឪពុកម្តាយកុមារឱ្យមានលទ្ធភាពទ្រទ្រង់គ្រួសារដោយពុំចាំបាច់ឱ្យកូនធ្វើការក្រុមជួយខ្លួនឯងជាច្រើនត្រូវបានបង្កើតឡើងដែលផ្តល់ឱកាសឱ្យឪពុកម្តាយកុមារជាង ៦.៤០០ នាក់ បានសន្សំប្រាក់ ខ្ចីប្រាក់និងបានរៀនពីជំនាញបង្កើតប្រាក់ចំណូលថ្មីៗជាច្រើនទៀត។

គំនិតផ្តួចផ្តើមទាំងនេះ បានជួយលើកកម្ពស់ការយល់ដឹងសាធារណៈថាពលកម្មកុមារគឺប្រឆាំងនឹងច្បាប់ ហើយវាប៉ះពាល់ដល់សុខភាព និងឱកាសអភិវឌ្ឍន៍នានារបស់កុមារ។

របាយការណ៍នេះ បានសង្ខេបការអនុវត្តល្អ៥យ៉ាង ក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ។ អង្គការ ILO-IPEC មានភារៈកិច្ចរៀបចំបោះពុម្ពឯកសារនេះ ដែលត្រូវបានបង្កើតឡើងដោយមានការពិគ្រោះយោបល់ទូលំទូលាយ ជាមួយអ្នកជំនាញការផ្នែកពលកម្មកុមារថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីឱ្យគំនិតផ្តួចផ្តើមល្អៗត្រូវបានអនុវត្តបន្តក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ៖

- គណៈកម្មាធិការអន្តរក្រសួងពីថ្នាក់ជាតិដល់ថ្នាក់ភូមិដែលសម្របសម្រួល និងជំរុញ កិច្ចខិតខំប្រឹងប្រែងលើការអនុវត្តការងារទាំងឡាយស្តីពីពលកម្មកុមារ។
- នីតិវិធីនានាដើម្បីដកហូតកុមារពីពលកម្ម ការទប់ស្កាត់កុមារមិនឱ្យធ្លាក់ក្នុងពលកម្មកុមារ និងជួយពួកគេឱ្យបញ្ចប់ការសិក្សាយ៉ាងតិចត្រឹមថ្នាក់ទី៩ ឬទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។

- គំនិតផ្តួចផ្តើមនានា ដែលបានលុបបំបាត់ពលកម្មកុមារ យ៉ាងមានប្រសិទ្ធិភាពក្នុងឧស្សាហកម្មដែលមានទម្រង់ធ្ងន់ធ្ងរបំផុតមួយនៅកម្ពុជា គឺ ស្រែអំបិល។
- ក្រុមជួយខ្លួនឯងដែលធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូល និងការសន្សំប្រាក់របស់ឪពុកម្តាយនៃពលករកុមារ ដើម្បីកុំឱ្យពួកគេបញ្ជូនកូនរបស់ខ្លួនទៅធ្វើការរកប្រាក់ដើម្បីជួយទ្រទ្រង់គ្រួសារទៀត និង
- ការបង្កើតផែនការតាមវិស័យ ហើយមានការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធទាំងអស់ ដើម្បីប្រាកដថាផែនការអាចទៅធ្វើបាន ហើយភាគីពាក់ព័ន្ធទាំងឡាយនឹងអនុវត្តផែនការនោះ។

ការអនុវត្តល្អទាំងប្រាំនេះ គ្រាន់តែជាផ្នែកមួយនៃការអនុវត្តល្អជាច្រើន ដែលត្រូវបានបង្កើតឡើងដោយប្រតិបត្តិករនានាក្នុងផ្នែកពលកម្មកុមារនៅកម្ពុជាពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១២។ ការអនុវត្តល្អទាំងនេះត្រូវបានជ្រើសរើសពីព្រោះវាពាក់ព័ន្ធនឹងគំនិតផ្តួចផ្តើមគន្លឹះនានាដើម្បីទប់ស្កាត់ពលកម្មកុមារ និងមានព័ត៌មានគ្រប់គ្រាន់ដើម្បីពន្យល់ ហើយត្រូវបានទទួលស្គាល់ពេញទំហឹងដោយមនុស្សរាប់រយនាក់ដែលធ្វើការក្នុងផ្នែកពលកម្មកុមារ។

# អក្សរកាត់

| | |
|---|---|
| **CAMFEBA** | សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| **CFAs** | សមាគមជលផលសហគមន៍ (កម្ពុជា) |
| **CNCC** | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ |
| **CSNACL** | បណ្តាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារ |
| **DoCL** | នាយកដ្ឋានពលកម្មកុមារ (កម្ពុជា) |
| **DoLA** | នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (កម្ពុជា) |
| **FiA** | រដ្ឋបាលជលផល (កម្ពុជា) |
| **ILO** | អង្គការពលកម្មអន្តរជាតិ |
| **IPEC** | កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ |
| **ITUCL** | គណៈកម្មាធិការអន្តរសហជីពទទួលបន្ទុកពលកម្មកុមារ |
| **MAFF** | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| **MLVT** | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **NGO-CRC** | សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ (កម្ពុជា) |
| **NPA-ECLF** | ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលកម្ពុជា |
| **NPA-WFCL** | ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ |
| **NSC-CL** | អនុគណៈកម្មាធិការជាតិពលកម្មកុមារ |
| **PCCL** | គណៈកម្មាធិការពលកម្មកុមារខេត្ត |
| **PDLVT** | មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត |
| **TBSP** | គម្រោងគាំទ្រកម្មវិធីមានពេលកំណត់ |
| **USDOL** | ក្រសួងការងារនៃសហរដ្ឋអាមេរិក |
| **WEDGE** | គម្រោងលើកកម្ពស់ការអភិវឌ្ឍមុខរបររបស់ស្ត្រី និងសមភាពយេនឌ័រ |

# សេចក្តីផ្តើម

របាយការណ៍នេះ ផ្តល់ព័ត៌មានអំពីការអនុវត្តល្អប្រាំយ៉ាង ដែលអ្នកធ្វើការផ្នែកពលកម្មកុមារទាំងឡាយនៅកម្ពុជាបានបង្កើតឡើង ដើម្បីបញ្ឈប់ពលកម្មកុមារ ធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព និងឱកាសសំរាប់ពលករកុមារ និងគ្រួសាររបស់ពួកគេ ហើយធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងទាំងនេះមាននិរន្តរភាពសំរាប់រយៈពេលវែង។

អង្គការ ILO-IPEC នៅកម្ពុជាមានភារៈកិច្ចធ្វើរបាយការណ៍នេះ ដើម្បីផ្តល់ព័ត៌មានឱ្យអ្នកធ្វើការផ្នែកពលកម្មកុមារទាំងឡាយបន្តប្រតិបត្តិការអនុវត្តល្អៗ ទាំងនេះនៅតំបន់ផ្សេងៗនៅកម្ពុជា និងនៅប្រទេសផ្សេងៗទៀត ដែលមានអត្រាភាពក្រីក្រ និងអត្រាពលកម្មកុមារខ្ពស់។

អង្គការ ILO-IPEC យល់ឃើញថាការចងក្រងជាឯកសារនូវការអនុវត្តល្អក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ ឱ្យក្លាយទៅជាសកម្មភាពបញ្ចប់គម្រោងយ៉ាងសំខាន់ នៅក្នុងប្រទេសនានាដែលកំពុងអនុវត្តគម្រោងរបស់អង្គការ ILO-IPEC ពីព្រោះវាជានាថាព័ត៌មានស្តីពីចំណុចខ្លាំង និងចំណុចខ្សោយនៃគំនិតផ្តួចផ្តើមនានាពីលើកមុន ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មាន និងធ្វើឱ្យគំនិតផ្តួចផ្តើមនានានៅពេលអនាគតមានភាពកាន់តែប្រសើរឡើង។

អង្គការ ILO-IPEC កំណត់ការអនុវត្តល្អមួយថា ជាការអនុវត្តដែលសម្រេចជោគជ័យក្នុងវិធីសាស្ត្រខ្លះ លើការប្រយុទ្ធប្រឆាំងពលកម្មកុមារ និងដែលចាត់ទុកថា មានតម្លៃដើម្បីអនុវត្តបន្តក្នុងតំបន់ឯទៀតនៃប្រទេស និងក្នុងប្រទេសឯទៀតដែលមានលក្ខខ័ណ្ឌស្រដៀងគ្នា។ ដូច្នេះ ការអនុវត្តល្អគឺជាគំនិតផ្តួចផ្តើមមួយទោះជាតូច ឬធំគឺ៖

- ❖ មាននិរន្តរភាព ក្រមសីលធម៌ និងមានភាពពាក់ព័ន្ធ
- ❖ អាចត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធិផល
- ❖ អាចត្រូវបានសាកល្បង និងបង្ហាញថាមានដំណើរការល្អ
- ❖ ផ្តល់គោលការណ៍ណែនាំពីរបៀបខិតខំប្រឹងប្រែងដើម្បីបញ្ឈប់ពលកម្មកុមារ ដែលអាចមានប្រសិទ្ធិភាពកាន់ខ្លាំងថែមទៀត
- ❖ បង្កើតគំនិតថ្មីៗ អំពីវិធីបញ្ឈប់ពលកម្មកុមារ។

ការអនុវត្តល្អទាំងប្រាំ ដែលបានលើកឡើង ក្នុងរបាយការណ៍នេះ គឺបានផ្តោតទៅលើ៖

- ❖ គណៈកម្មាធិការអន្តរក្រសួងពីថ្នាក់ជាតិ ដល់ថ្នាក់ភូមិដែលសម្របសម្រួលអ្នកទាំងឡាយ ដែលធ្វើការផ្នែកពលកម្មកុមារ ដើម្បីឱ្យពួកគេចែករំលែក ព័ត៌មានបំពេញកង្វះខាត និងជៀសវាងការត្រួតជាន់គ្នា ជួយគ្នាដោះស្រាយបញ្ហា ធ្វើសហប្រតិបត្តិការ និងបង្កើតកិច្ចខិតខំប្រឹងប្រែងទៅវិញទៅមក។
- ❖ បង្ហាញនីតិវិធីដើម្បី ដកហូតកុមារពីពលកម្មទប់ស្កាត់ពួកគេមិនឱ្យចូលក្នុងពលកម្មកុមារ និងផ្តល់ការគាំទ្រហិរញ្ញវត្ថុ សម្ភារៈ និងគាំទ្រផ្នែកសង្គមដល់ពួកគេដើម្បីឱ្យពួកគេអាចបញ្ចប់ការសិក្សា ឬការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។
- ❖ វិធីដែលដៃគូរបស់អង្គការ ILO-IPEC និងទីប្រឹក្សាបច្ចេកទេស នៅគ្រប់កំរិតបានសហការណ៍គ្នាដើម្បីលុបបំបាត់ពលកម្មកុមារ[1] យ៉ាងមានប្រសិទ្ធិភាពនូវទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅកម្ពុជាមួយ គឺវិស័យស្រែអំបិលនៅខេត្តកែប និងខេត្តកំពត។

---

1 ពាក្យ "ប្រកបដោយប្រសិទ្ធិភាព" ត្រូវបានប្រើប្រាស់ដោយហេតុថាជាមួយនឹងភាពក្រីក្រនៅជនបទមានកំរិតខ្ពស់ និងកង្វះសំណាញ់សុវត្ថិភាពសង្គម របស់កម្ពុជានៅពេលដែលមានគ្រោះអាសន្ននានា ដូចជាការបណ្តេញចេញ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការបាត់បង់ជីវិតអ្នកផ្គត់ផ្គង់គ្រួសារ ឬការចំណាយខ្ពស់ទៅលើការតស៊ូព្យាបាលជម្ងឺ នៅពេលនោះកសិករដែលពឹងផ្អែកតែលើកសិកម្មអាចបាត់បង់ដីធ្លី និងប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ពួកគេ ហើយពួកគេក៏បង្ខំចិត្តធ្វើចំណាកស្រុកទៅកន្លែងដូចជាស្រែអំបិល ដើម្បីអាចរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ បើទោះបីជា និយោជក មន្ត្រីអប់រំ អ្នកដឹកនាំសហគមន៍ សហជីពបានប្តេជ្ញាចិត្តយ៉ាងម៉ឺងមាត់ទាំងអស់គ្នា ក្នុងការលុបបំបាត់ពលកម្មកុមារក្នុងវិស័យ ផលិតកម្មអំបិលក៏ដោយ ក៏នៅតែមានឪពុកម្តាយកុមារមួយចំនួនតូចនៅតែឱ្យកូនៗរបស់ពួកគេធ្វើការក្នុងស្រែអំបិលដដែល ពោលគឺនៅមុនពេលដែលពួកគេត្រូវបានពន្យល់បញ្ចុះបញ្ចូលឱ្យដកហូតកុមារទាំងនោះ ចេញពីការងារនេះ។

- ❖ ការបង្កើត និងការធ្វើឱ្យដំណើរការក្រុមជួយខ្លួនឯង ចំពោះឪពុកម្តាយពលករកុមារមានលទ្ធភាពបង្កើនប្រាក់ចំណូលថែមទៀត និងសន្សំប្រាក់គ្រប់គ្រាន់ដើម្បីឱ្យពួកគេមិនចាំបាច់ប្រើកូនឱ្យទៅធ្វើការទៀតទេ។
- ❖ បង្កើតផែនការតាមវិស័យ ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ ដែលត្រូវបានធ្វើឡើងដោយការពិគ្រោះយោបល់យ៉ាងទូលំទូលាយជាមួយភាគី ពាក់ព័ន្ធទាំងអស់ដើម្បីធានាថាផែនការនោះ អាចធ្វើទៅបានហើយភាគីពាក់ព័ន្ធនឹងអនុវត្តវា។

ការអនុវត្តល្អទាំងប្រាំនេះ ត្រូវបានជ្រើសរើសពីការអនុវត្តល្អៗជាច្រើនដែលបង្កើតដោយ ដៃគូពាក់ព័ន្ធនិងបុគ្គលិករបស់អង្គការ ILO-IPEC ពីព្រោះការអនុវត្តល្អទាំងប្រាំនេះជាគំនិតផ្តួចផ្តើមកំរិតទូលំទូលាយ ដោយមានសារៈសំខាន់ជាក់លាក់ មានព័ត៌មានគ្រប់គ្រាន់ ដើម្បីពន្យល់ពីវិធីប្រតិបត្តិការ មានភស្តុតាងបង្ហាញពីផលវិជ្ជមាន ហើយការជ្រើសរើសការអនុវត្តល្អទាំងប្រាំនេះ ត្រូវបានព្រមព្រៀងគ្នាដោយដៃគូរបស់អង្គការ ILO-IPEC ជាច្រើនរយនាក់នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់។

ការអនុវត្តល្អនីមួយៗ ក្នុងរបាយការណ៍នេះ ត្រូវបានបង្ហាញក្នុងទម្រង់ដូចគ្នាគឺ៖ អ្វីដែលជាបំណងនៃការអនុវត្តល្អប៉ងប្រាថ្នាសម្រេចឱ្យបាន អ្វីដែលជាវិធីនៃការអនុវត្តល្អ ត្រូវបានធ្វើឡើង អ្វីដែលជាបញ្ហាប្រឈមអាចកើតឡើងក្នុងពេលកំពុងប្រតិបត្តិការអនុវត្តល្អ អ្វីដែលជារបៀបនៃការឆ្លើយតបនូវបញ្ហាប្រឈមជា សក្តានុពលទាំងនោះ និងល័ក្ខខ័ណ្ឌទាំងឡាយ ដើម្បីធានានិរន្តរភាពនៃការអនុវត្តល្អ។

របាយការណ៍នេះ ត្រូវបានធ្វើឡើងនៅពេលបញ្ចប់គម្រោងគាំទ្រមានពេលកំណត់ដំណាក់កាលទី ២ (TBSP Phase II) របស់អង្គការ ILO-IPEC ដែលចាប់ផ្តើមពីឆ្នាំ២០០៨ ដល់ដំណាច់ឆ្នាំ២០១២ ដែលត្រូវបានផ្តល់មូលនិធិ ដោយក្រសួងការងារនៃសហរដ្ឋអាមេរិកនូវទឹកប្រាក់ចំនួន ៤,៣១ លានដុល្លារអាមេរិក។

ខាងក្រោមនេះ គឺជាគោលបំណងទាំងបួន នៃគម្រោងគាំទ្រមានពេលកំណត់ដំណាក់កាលទី ២ (TBSP Phase II) របស់អង្គការ ILO-IPEC គឺ៖

- ❖ ការបង្កើតគោលនយោបាយ និងក្របខ័ណ្ឌគតិយុត្តិថ្នាក់ជាតិ ដើម្បីសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់រដ្ឋាភិបាលដែលកាត់បន្ថយពលកម្មកុមារមកត្រឹម៨% នៅឆ្នាំ២០១៥ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារនៅឆ្នាំ២០១៦។
- ❖ ការកសាងចំណេះដឹងដល់ដៃគូ និងភាគីពាក់ព័ន្ធនានាពីវិធីប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ។
- ❖ ការធ្វើឱ្យប្រសើរឡើង នូវសមត្ថភាពសហជីព និងរដ្ឋាភិបាល ក៏ដូចជាដៃគូឯទៀត របស់អង្គការ ILO-IPEC ដើម្បីឆ្លើយតបការកេងប្រវ័ញ្ចពលកម្មកុមារ និង
- ❖ ការធ្វើសាកល្បងនូវគំនិតផ្តួចផ្តើមជាគោលដៅ ដែលអាចត្រូវបានបន្តអនុវត្តទូទាំងកម្ពុជា ដើម្បីសម្រេចឱ្យបាននូវវិធីសាស្ត្រប្រកបដោយប្រសិទ្ធិភាព និងមាននិរន្តរភាព ក្នុងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចពលកម្មកុមារ ឬទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។

ក្នុងចន្លោះឆ្នាំ២០០៨ ដល់២០១២ គម្រោងគាំទ្រមានពេលកំណត់ដំណាក់កាលទី ២ (TBSP Phase II) របស់អង្គការ ILO-IPEC ត្រូវបានអនុវត្តក្នុង១៥ខេត្តនៅកម្ពុជា ដែលក្នុងនោះមាន ៨ខេត្ត បានអនុវត្តសកម្មភាពដោយផ្ទាល់ ។ ចំនួនកុមារត្រូវដកហូត ឬត្រូវទប់ស្កាត់ពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារមាន ១២.០០០ នាក់។ ក្នុងចំណោមនេះ មានកុមារ ១១.០០០ នាក់ ត្រូវបានកំណត់ជាក្រុមគោលដៅ ដើម្បីដកហូត និងទប់ស្កាត់ តាមរយៈការផ្តល់ការអប់រំ រហូតដល់ថ្នាក់ទី ៩ ឬ សេវាបណ្តុះបណ្តាលជំនាញ ប្រសិនបើអាយុ លើស ១៥ឆ្នាំ។ ចំណែកឯកុមារ ១.០០០ នាក់ ត្រូវបានកំណត់ជាក្រុមគោលដៅតាមរយៈការផ្តល់សេវាមិនមែនជាការអប់រំ។

ក្នុងរយៈពេលជាង ៤ឆ្នាំ នៃ TBSP Phase II មានកុមារសរុបចំនួន ១២.៩៥១ នាក់ ត្រូវបានដកហូត និងត្រូវបានទប់ស្កាត់ ពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដោយបានទទួលសេវាអប់រំ ការបណ្តុះបណ្តាល និងសេវាមិនមែនអប់រំ ដែលក្នុងនោះមានកុមារ ១១.៧៤៤ នាក់ ត្រូវបានដកហូត និង ១.២០៧ នាក់ត្រូវបានទប់ស្កាត់។

ថ្វីបើការអនុវត្តល្អទាំងប្រាំ នៅក្នុងរបាយការណ៍នេះ ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយក្នុង TBSP Phase II ក៏ដោយ ក៏ជាមូលដ្ឋានគ្រឹះ របស់វាត្រូវបានចាក់ឫសជាច្រើនឆ្នាំមកហើយ។ បើក្រឡេកមើលទៅឆ្នាំ១៩៩៧ វិញ អង្គការ ILO-IPEC កម្ពុជាបានធ្វើការសិក្សាស្រាវជ្រាវ ដើម្បីយល់ដឹងអំពីពលកម្មកុមារនៅកម្ពុជា ហើយដោយសារតែមានព័ត៌មាននេះ ទើបធ្វើឱ្យមានគំនិតផ្តួចផ្តើមធ្វើគម្រោងសាកល្បង ធ្វើការវាយតម្លៃ ធ្វើការពង្រីក និងធ្វើការអនុវត្តបន្ត ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ ក្នុងវិស័យទាំងឡាយដែលចាត់ទុកថាជាទម្រង់ធ្ងន់ធ្ងរ ឬការងារប្រកបដោយគ្រោះថ្នាក់នៃពលកម្មកុមារ និងកន្លែងដែលជួលកុមារក្នុងចំនួនច្រើនឱ្យធ្វើការ។ ឧទាហរណ៍ដូចជា ការងាររើសអេតចាយ ការងារឡេឥដ្ឋ ការងារវាយថ្ម ការសំណង់ ការងារចំការកៅស៊ូ ការងារនេសាទ និងការងារកែច្នៃផលិតផលនេសាទ។

វិធីសាស្ត្រដែលការសិក្សាស្រាវជ្រាវ និងការពិគ្រោះយោបល់ស្តីពីការអនុវត្តល្អបានធ្វើឡើង ដើម្បីបង្ហាញក្នុងរបាយការណ៍នេះគឺ៖

បុគ្គលិក អង្គការ ILO-IPEC និងភាគីពាក់ព័ន្ធសំខាន់ៗ បានរកឃើញនូវគំនិតផ្តួចផ្តើម ១៤ ដែលត្រូវបានអនុវត្តក្នុងអំឡុងពេលគម្រោង TBSP Phase II ដែលពួកគេជឿថាជាការអនុវត្តល្អ ក្នុងការប្រយុទ្ធប្រឆាំងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដែលការងារទាំងនោះរួមមាន៖

- ការអនុវត្តវិធីសាស្ត្រ លុបបំបាត់ពលកម្មកុមារតាមវិស័យ (វិស័យស្រែអំបិលនៅខេត្តកំពត និងវិស័យអូសរទេះនៅក្រុងប៉ោយប៉ែត ក្នុងខេត្តបន្ទាយមានជ័យ) ដោយមិនឱ្យមានទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារនិងតួនាទីរបស់វិស័យឯកជនក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- ការអនុវត្តវិធីសាស្ត្រលុបបំបាត់ពលកម្មកុមារក្នុងតំបន់ទាំងមូល (ដោយមិនឱ្យមានទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្នុងខេត្តកែបទាំងមូល)។
- ការអនុវត្ត វិធីសាស្ត្រលុបបំបាត់ពលកម្មកុមារ តាមតំបន់តូចៗ ក្នុងទីក្រុង (តំបន់តូចៗ ជាគោលដៅនៅទីក្រុងភ្នំពេញ និងសៀមរាប) ដោយមិនឱ្យមានទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- ផ្តល់ភាពអង់អាចដល់ឪពុកម្តាយ ជាពិសេសម្តាយនៃកុមារដែលធ្វើការ និងការកែលម្អការចិញ្ចឹមជីវិតរបស់ពួកគេតាមរយៈការគាំទ្រការបង្កើតប្រាក់ចំណូល។
- ការភ្ជាប់ទំនាក់ទំនងនិងការកសាងសមត្ថភាពនិយោជក និងក្រុមហ៊ុនក្នុងការឆ្លើយតបពលកម្មកុមារ។
- ការភ្ជាប់ទំនាក់ទំនង និងការកសាងសមត្ថភាពកម្មករ និងសហជីពក្នុងការឆ្លើយតបពលកម្មកុមារ។
- ការភ្ជាប់ទំនាក់ទំនង និងការកសាងសមត្ថភាពសង្គមស៊ីវិល និងបណ្តាញសង្គមស៊ីវិល ក្នុងការឆ្លើយតបពលកម្មកុមារ។
- ការកៀរគរធនធានដើម្បីលើកកម្ពស់ការយល់ដឹង និងធ្វើយុទ្ធនាការតស៊ូមតិប្រឆាំងនឹងពលកម្មកុមារតាមរយៈការប្រារព្ធទិវាពិភពលោកប្រឆាំង នឹងពលកម្មកុមាររៀងរាល់ឆ្នាំនៅថ្ងៃទី១២ ខែមិថុនា។
- ការបង្កើត និងការដាក់ឱ្យដំណើរការនូវប្រព័ន្ធត្រួតពិនិត្យតាមដាន ពលកម្មកុមារជាក់លាក់នៅកម្ពុជា សំដៅត្រួតពិនិត្យតាមដានជាប្រចាំ និងឆ្លើយតបបញ្ហាពលកម្មកុមារនៅទូទាំងប្រទេស។
- ការចលនាកៀរគរភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីបង្កើត និងអនុវត្តផែនការសកម្មភាពជាតិលើកទី១ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ សំដៅសម្រេចឱ្យបានជោគជ័យនូវគោលដៅភ្លោះរបស់ប្រទេស ស្តីពីការលុបបំបាត់ពលកម្មកុមារត្រឹមឆ្នាំ២០១៥ និង ២០១៦។
- បន្តនិរន្តរភាពនូវ សកម្មភាពប្រយុទ្ធប្រឆាំងពលកម្មកុមារនៅខេត្តកំពង់ចាម និងខេត្តព្រះសីហនុ ជាកន្លែងដែលគម្រោង TBSP Phase II ត្រូវបានបញ្ចប់អន្តរាគមន៍នៅថ្នាក់មូលដ្ឋាន។
- ការបញ្ជ្រាបការអប់រំ និងបញ្ហានានាទាក់ទិននឹងពលកម្មកុមារទៅក្នុងយុទ្ធសាស្ត្រជាតិការពារសង្គម។

- ការចូលរួម និងការកសាងសមត្ថភាពក្រុមប្រឹក្សា ឃុំ សង្កាត់ ដើម្បីដាក់បញ្ចូលបញ្ហាពលកម្មកុមារទៅក្នុងផែនវិនិយោគ និងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដើម្បីឆ្លើយតបពលកម្មកុមារនៅថ្នាក់មូលដ្ឋាន។
- ការបង្កើតនិងការអនុវត្តផែនការសកម្មភាពតាមវិស័យដើម្បីឆ្លើយតបពលកម្មកុមារក្នុងវិស័យជលផល។

ផ្អែកលើបញ្ជីនេះ អ្នកធ្វើរបាយការណ៍បានពិនិត្យផែនការគម្រោង និងរបាយការណ៍តាមដាន ត្រួតពិនិត្យ ដើម្បីឱ្យបានយល់ដឹងអំពីការងារ និងសមិទ្ធផលនៃការអនុវត្តល្អជាសក្តានុពលទាំង១៤ចំណុចខាងលើហើយត្រូវបានប្រើប្រាស់ព័ត៌មាននេះ ដើម្បីបង្កើតសំនួរសំរាប់ប្រើប្រាស់ ក្នុងក្រុមពិភាក្សាជាក់លាក់ និងការសម្ភាសន៍ជាលក្ខណៈបុគ្គល។

នៅខែកក្កដា ឆ្នាំ២០១២ អ្នកធ្វើរបាយការណ៍នេះបានចុះស្រាវជ្រាវដល់ទីកន្លែង ដោយជួបជាមួយអ្នកឯកទេសផ្នែកពលកម្មកុមារ ពលករកុមារ និងឪពុកម្តាយនៅក្រុងភ្នំពេញ ខេត្តកែប កំពត បន្ទាយមានជ័យ និងសៀមរាប ដែលជាសរុបមានមនុស្សជាង ១០០នាក់ ត្រូវបានសម្ភាសន៍។

បន្ទាប់ពីបានធ្វើការវិភាគ និងការស្រាវជ្រាវដល់ទីកន្លែង អ្នកធ្វើរបាយការណ៍ បានបង្ហាញពីលទ្ធផលសំខាន់ៗ នៃការអនុវត្តល្អ ដែលបានរកឃើញជូនដល់អ្នកឯកទេសផ្នែកពលកម្មកុមារជាង១០០នាក់ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ខេត្ត និងថ្នាក់ជាតិ។ អ្នកឯកទេសទាំងនោះរួមមានមន្ត្រីរដ្ឋាភិបាល សហជីព ក្រុមហ៊ុនឯកជន ភ្នាក់ងារអនុវត្តច្បាប់ អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងអង្គការសាសនាជាច្រើន។

ផ្អែកលើយោបល់ត្រឡប់ជាផ្លូវការ និងក្រៅផ្លូវការពីភាគីពាក់ព័ន្ធទាំងអស់ និងអ្នកឯកទេសមួយចំនួនរបស់អង្គការ ILO-IPEC អ្នកធ្វើរបាយការណ៍បានសម្រេចចិត្តជ្រើសរើស និងសំរិតសំរាំងការអនុវត្តល្អទាំងប្រាំដែលរៀបរាប់ក្នុងរបាយការណ៍នេះ។ ពង្រៀងសង្ខេបនៃការអនុវត្តល្អទាំងនេះត្រូវបានបង្ហាញ និងទទួលការឯកភាពពីតំណាងដៃគូរបស់អង្គការ ILO-IPEC នៅថ្នាក់ជាតិ និងថ្នាក់ខេត្តចំនួន ១៥០នាក់ ក្នុងសិក្ខាសាលាបញ្ចប់គម្រោង TBSP Phase II នៅខែធ្នូ ឆ្នាំ២០១២។

# ១- ការបង្កើតយន្តការសម្របសម្រួលពីថ្នាក់ជាតិដល់ថ្នាក់សហគមន៍ដើម្បីលុបបំបាត់ពលកម្មកុមារនៅកម្ពុជា



## សេចក្តីសង្ខេប

ស្ថាប័ន និងអ្នកពាក់ព័ន្ធទាំងឡាយដែលធ្វើការ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ពីថ្នាក់ជាតិដល់ថ្នាក់ភូមិនៅកម្ពុជា ចាត់ទុកថាជាការអនុវត្តល្អមួយដែលមានការជួបប្រជុំគ្នាជាទៀងទាត់ រវាងសមភាគីទាំងក្នុង និងក្រៅរដ្ឋាភិបាល។ អ្នកចូលរួមនិយាយថាកិច្ចប្រជុំទាំងនេះ មានតម្លៃណាស់ពីព្រោះគេអាចលើកកម្ពស់ការយល់ដឹង ដល់សមាជិកអំពីបញ្ហាពលកម្មកុមារ បទប្បញ្ញត្តិ និងការងារដែលស្ថាប័ន និងអង្គការផ្សេងៗទៀត កំពុងធ្វើបញ្ជូនគោលនយោបាយ និងព័ត៌មានពីអាជ្ញាធរថ្នាក់លើមកក្រោម ផ្តល់ការទទួលស្គាល់ និងការគាំទ្រជាក់ស្តែងដល់អ្នក ដែលកំពុងធ្វើកិច្ចការពារពេញដោយភាពប្រឈមនេះ។ លើសពីនេះទៀត វាជាវេទិកាផ្សព្វផ្សាយព័ត៌មានលើកកម្ពស់ ការយល់ដឹងតាមរយៈបណ្តាញនានានៃអ្នកចូលរួម ការដាក់បញ្ចូលចូលបញ្ហាពលកម្មកុមារ ទៅក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ ក្នុងចំណោមសមាជិកក្នុងការដោះស្រាយបញ្ហា និងការបំពេញការងារគ្នាទៅវិញទៅមក។

## សាវតា

ដើម្បីសម្រេចឱ្យបាននូវគោលដៅភ្លោះរបស់រដ្ឋាភិបាលកម្ពុជាក្នុងការកាត់បន្ថយពលកម្មកុមារមកត្រឹម៨%នៅឆ្នាំ២០១៥ និងបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ ២០១៦ គឺជាការងារដ៏ប្រឈមមួយ។

ទី១ ពលកម្មកុមារគឺជាបញ្ហាដ៏សំខាន់។ ក្នុងឆ្នាំ២០០៩ មានកុមារប្រហែល ៣០០.០០០ នាក់ អាយុពី ១០ ដល់ ១៧ ឆ្នាំ ស្ថិតនៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្ម កុមារ ឬស្ថិតក្នុងហានិភ័យខ្ពស់ក្នុងការអិលចូលទៅក្នុង ពលកម្មកុមារ។ ទី២ ដើម្បីបញ្ឈប់កុមារទាំងនេះពីការងារ និងផ្តល់ការអប់រំ ឬការបណ្តុះបណ្តាលដល់ពួកគេ និងជួយឪពុកម្តាយរបស់



ពួកគេឱ្យរកប្រាក់គ្រប់គ្រាន់ ដើម្បីទ្រទ្រង់គ្រួសារដោយពុំចាំបាច់ឱ្យកូនរបស់ពួកគេធ្វើការ គឺត្រូវការថវិកាប្រមាណពី ៧០ ទៅ៩០លានដុល្លារអាមេរិក[2] ។

ការដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ក៏ត្រូវចំណាយពេលច្រើនផងដែរ ពីព្រោះកន្លែងធ្វើការនៅឆ្ងាយៗដូចជាករណីការនេសាទ ការវាយថ្ម ការរុករករ៉ែ ការងារស្រែអំបិល ការងារចំការ ។ល។ ឬវាទាមទារឱ្យមានការខិតខំប្រឹងប្រែងច្រើន ដើម្បីស្វែងរក និងដកហូតពលករកុមារ ពីព្រោះពួកគេខ្លះទៀត ធ្វើការនៅតាមកន្លែងលាក់កំបាំង ដូចជាករណីអ្នកបំរើការតាមផ្ទះ ឬក្នុងហាងបិទជិត ឬពួកគេខ្លះទៀតធ្វើបំលាស់ទីចុះឡើង ដោយសារតែពួកគេជាអ្នករើសអេតចាយ លក់វត្ថុអនុស្សាវរីយ៍តាមផ្លូវ ឬជាអ្នកសុំទាន ។

បញ្ហាប្រឈមទីបួន សំរាប់អ្នកធ្វើការផ្នែកពលកម្មកុមារនៅថ្នាក់សហគមន៍គឺ ត្រូវធ្វើការជាច្រើនម៉ោង ។ អាជ្ញាធរមូលដ្ឋាន និងអ្នកធ្វើការនៅមូលដ្ឋានជាច្រើនបានដាក់ការងារកុមារ ជាអាទិភាពចំបងនៃការងារប្រចាំថ្ងៃរបស់ពួកគេ ហើយជួនកាលពួកគេត្រូវធ្វើការទាំងយប់ និងនៅចុងសប្តាហ៍ទៀតផង ពីព្រោះជាពេលដែលកុមារ និងគ្រួសារមានពេលទំនេរនៅផ្ទះអាចជួបបាន ។ ពួកគេមិនមានប្រាក់ឧបត្ថម្ភសំរាប់ការងារលើសម៉ោងទេ ហើយការងារនៅតាមសហគមន៍ខ្លះ ពួកគេត្រូវចំណាយលុយផ្ទាល់ខ្លួនថែមទៀតទៅលើសាំងម៉ូតូ និងអាហារនៅពេលដែលប្រាក់ឧបត្ថម្ភមិនគ្រប់គ្រាន់ ។

ដោយសារការងារបញ្ចប់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារមានភាពប្រឈម និងត្រូវការកិច្ចខិតខំប្រឹងប្រែងកាន់តែច្រើនដើម្បីសម្រេចឱ្យបានគោលដៅរបស់រដ្ឋាភិបាល ក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ ២០១៦ អ្នកដែលធ្វើការងារផ្នែកពលកម្មកុមារ ត្រូវការយន្តការសម្របសម្រួលមួយដែលអាចឱ្យពួកគេជួបប្រជុំគ្នាទៀងទាត់ ដើម្បីចែករំលែកព័ត៌មាន ដោះស្រាយបញ្ហា និងផ្តល់ការគាំទ្រគ្នាទៅវិញទៅមក ។

## តើការអនុវត្តល្អនេះត្រូវបានប្រតិបត្តិដូចម្តេច ?

យន្តការសម្របសម្រួលល្អមួយ គឺកិច្ចប្រជុំទៀងទាត់ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលកំពុងធ្វើការងារលុបបំបាត់ពលកម្មកុមារពីគណៈរដ្ឋមន្ត្រីរហូតដល់ថ្នាក់ភូមិ ។

មានកត្តាសំខាន់ពីរ ដែលភាគីពាក់ព័ន្ធ បង្ហាញថាបានរួមចំណែកដល់ជោគជ័យនៃការអនុវត្តល្អនេះ គឺទី១ ការយកចិត្តទុកដាក់របស់អាជ្ញាធរថ្នាក់ជាតិ ដែលបានធ្វើឱ្យបញ្ហាពលកម្មកុមារក្លាយជាអាទិភាពចំបង សំរាប់ស្ថាប័នជាច្រើនទាំងក្នុងនិងក្រៅរដ្ឋាភិបាល និងទី២ ការសម្របសម្រួលប្រកបដោយប្រសិទ្ធិភាពរបស់ក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។

### អាជ្ញាធរថ្នាក់ជាតិ និងក្របខ័ណ្ឌជាតិធ្វើឱ្យការលុបបំបាត់ពលកម្មកុមារក្លាយជាអាទិភាពមួយ

ក្របខ័ណ្ឌសំខាន់ៗ ៣ ដែលធ្វើឱ្យការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក្លាយជាការងារអាទិភាពជាចំបង នៅកម្ពុជា ។ ក្របខ័ណ្ឌទាំងនោះគឺ ផែនការសកម្មភាពជាតិស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ឆ្នាំ២០០៨-២០១២ ផែនការសកម្មភាពជាតិប្រឆាំងការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទឆ្នាំ ២០០៦-២០១០ និងផែនការជាតិស្តីពីការអប់រំសំរាប់ទាំងអស់គ្នាឆ្នាំ ២០០៣-២០១៥ ។

---

2 របាយការណ៍ស្តីពីការយល់ដឹងអំពីការងារកុមារ (UCW) ឆ្នាំ ២០០៩ ។ ឆ្ពោះទៅរកការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរពលកម្មកុមារឆ្នាំ២០១៦ ៖ ការវាយតម្លៃតម្រូវការធនធាន ។ កម្រងរបាយការណ៍កម្មវិធីប្រចាំប្រទេស (Rome, UCW). អាចរកបាននៅ: http://www.ucw-project.org/attachment/child_labour_Cambodiall20110627_163036.pdf.



ផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ស្របគ្នាជាមួយគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា និងផែនការជាតិអភិវឌ្ឍន៍សង្គម ដែលផែនការទាំងពីរនេះប្តេជ្ញាថាកាត់បន្ថយពលកម្មកុមារមកត្រឹម ៨% នៅឆ្នាំ ២០១៥។ ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ក៏បានសន្យាសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល ក្រោមអនុសញ្ញារបស់អង្គការពលកម្មអន្តរជាតិ (ILO) លេខ១៣៨ ដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារត្រឹមឆ្នាំ ២០១៦។

ផែនការសកម្មភាពជាតិស្តីពី ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ លើកកម្ពស់វិធីសាស្ត្រចំរុះពហុវិស័យ ដើម្បីកាត់បន្ថយពលកម្មកុមារ ដែលចូលរួមគ្រប់ភាគីពាក់ព័ន្ធទាំងអស់តាមរយៈសកម្មភាពក្នុងវិស័យសំខាន់ៗ ៨ ដែលរួមមាន៖(១)ការសិក្សានិងស្រាវជ្រាវ(ដើម្បីបង្កើតព័ត៌មានដែលត្រូវការដើម្បីតម្រង់ទិសគោលនយោបាយ និងលើកកម្ពស់ការយល់ដឹង)។(២)ការអភិវឌ្ឍស្ថាប័ននិងគោលនយោបាយ (ដើម្បីពង្រឹងក្របខ័ណ្ឌគោលនយោបាយ និងសមត្ថភាពស្ថាប័នដើម្បីអនុវត្តគោលនយោបាយ)។(៣) ការតាក់តែងបទប្បញ្ញត្តិ និងការពង្រឹងការអនុវត្តច្បាប់ (ដើម្បីពង្រឹងក្របខ័ណ្ឌគតិយុត្តិ និងសមត្ថភាពជាតិ ក្នុងការអនុវត្តច្បាប់)។(៤) ការតស៊ូមតិ ការកសាងបណ្តាញ និងចលនាប្រមូលផ្តុំសង្គម (ដើម្បីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកជាអវិជ្ជមាននៃពលកម្មកុមារ និងការប្តេជ្ញាចិត្តកំរិតជាតិរបស់កម្ពុជាដើម្បីឆ្លើយតបបញ្ហានេះ)។ (៥) អប់រំ (ដើម្បីផ្តល់ជំរើសដែលអាចសម្រេចបានចំពោះពលកម្មកុមារ)។ (៦) ការទប់ស្កាត់ (ដើម្បីឆ្លើយតបទាំងកត្តាផ្គត់ផ្គង់ និងតម្រូវការដែលបណ្តាលឱ្យកុមារធ្លាក់ក្នុង ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ)។(៧)ការការពារ(ដើម្បីការពារពលករកុមារអាយុពី ១៥-១៧ឆ្នាំ ឱ្យចាកផុតពីកន្លែងធ្វើការប្រកបដោយគ្រោះថ្នាក់) (៨) ដកហូត និងស្តារនីតិសម្បទា (ដើម្បីដកហូតកុមារពីការងារប្រកបដោយគ្រោះថ្នាក់ ឬការងារកេងប្រវ័ញ្ច ហើយជួយសម្រួលឱ្យពួកគេធ្វើសមាហរណកម្មទៅក្នុងសង្គមវិញ)។

ផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ (NPA-WFCL) ឆ្នាំ ២០០៨-២០១២ ក៏ត្រូវបានអនុម័តដោយអង្គការនិយោជក និងសហជីព អង្គការមិនមែនរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានាដើម្បីធ្វើជាមគ្គុទេសក៍សំរាប់ការងាររបស់ពួកគេ និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋាភិបាល ក្នុងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

## ការសម្របសម្រួលដោយក្រសួង និងមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ដោយមានការណែនាំពីឯកឧត្តម រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងនាយកដ្ឋានពលកម្មកុមារ ត្រួតពិនិត្យការងារទាំងអស់ស្តីពីបញ្ហាពលកម្មកុមារ នៅកម្ពុជា ដែលរួមមាន៖

- ការបង្កើតគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពលកម្មកុមារ។
- អនុវត្តគោលនយោបាយ រាជរដ្ឋាភិបាល កម្ពុជា អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងពលកម្មកុមារជាពិសេសទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- ពិនិត្យតាមដានការអនុវត្ត ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ និងអនុសញ្ញាអន្តរជាតិស្តីពីពលកម្មកុមារ។
- សហការ សម្របសម្រួល និងវាយតម្លៃការងារជាមួយក្រសួង ស្ថាប័ន អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សហជីព និងនិយោជកជាដៃគូ ដើម្បីឆ្លើយ

តបបញ្ហានានាពាក់ព័ន្ធ នឹងពលកម្មកុមារនិងអង្គការសាសនាជាច្រើន។

❖ អន្តរាគមន៍លើបញ្ហានានាពាក់ព័ន្ធ នឹងពលកម្មកុមារ។

❖ រៀបចំយុទ្ធនាការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងប្រចាំឆ្នាំនៅថ្នាក់ជាតិនិងថ្នាក់មូលដ្ឋានពាក់ព័ន្ធនឹងទិវាពិភពលោកប្រយុទ្ធប្រឆាំងពលកម្មកុមារថ្ងៃទី១២ មិថុនា ការបង្កើតនិងផ្តល់ធនធានដល់ពលករកុមារនិងគ្រួសារកុមារ និង

❖ ធ្វើការសម្របសម្រួល និងចូលរួមការប្រជុំតាមកំរិតទទួលខុសត្រូវរបស់បុគ្គលិករបស់ស្ថាប័ន អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល សហជីព និងនិយោជកជាដៃគូ ភ្នាក់ងារពង្រឹងច្បាប់ និងអង្គការសាសនាដើម្បីឆ្លើយតបបញ្ហានានាពាក់ព័ន្ធនឹងពលកម្មកុមារ ។



## គណៈកម្មាធិការថ្នាក់ជាតិដើម្បីលុបបំបាត់ពលកម្មកុមារ

### *អនុគណៈកម្មាធិការជាតិពលកម្មកុមារ (NSC-CL)*

អនុគណៈកម្មាធិការជាតិពលកម្មកុមារ ជាអាជ្ញាធរថ្នាក់ខ្ពស់បំផុតនៃរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកពលកម្មកុមារ ហើយជាអនុគណៈកម្មាធិការមួយក្នុងចំណោមអនុគណៈកម្មាធិការបួន នៅក្រោមក្រុមប្រឹក្សាជាតិដើម្បីកុមារ ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី និងមានតំណាងមកពីក្រសួងទាំងអស់ជាសមាជិក ដើម្បីជានាការសម្របសម្រួល ការអនុវត្ត ការពិនិត្យតាមដាន និងការវាយតំលៃគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធនឹងសិទ្ធិកុមារ (សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានកិច្ចការពារ និងសិទ្ធិចូលរួមក្នុងសង្គមកម្ពុជា)។



ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំប្រជុំ និងគាំទ្រអនុគណៈកម្មាធិការជាតិពលកម្មកុមារ។រដ្ឋលេខាធិការនៃក្រសួងការងារធ្វើជាប្រធាន នៃអនុគណៈកម្មាធិការជាតិពលកម្មកុមារ ចំណែកឯនាយកដ្ឋានពលកម្មកុមារ ធ្វើជាលេខាធិការដ្ឋាននៃអនុគណៈកម្មាធិការនេះ។ សមាជិករបស់អនុគណៈកម្មាធិការជាតិពលកម្មកុមារ រួមមានស្ថាប័នរដ្ឋាភិបាលទាំងអស់ដែលត្រូវបានរំពឹងថា មានតួនាទីសំខាន់ក្នុងការចូលរួមលុបបំបាត់ពលកម្មកុមារគឺ៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងយុត្តិធម៌ ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងកិច្ចការនារី ។

អនុគណៈកម្មាធិការជាតិពលកម្មកុមារក៏មានតំណាងចូលរួមមកពីអង្គការមិនមែនរដ្ឋាភិបាលនានា ដែលដើរតួនាទីសំខាន់ក្នុងការលុបបំបាត់ ពលកម្មកុមារផងដែរគឺ៖ គណៈកម្មាធិការអន្តរសហជីព លុបបំបាត់ពលកម្មកុមារ បណ្តាញសង្គមស៊ីវិលប្រឆាំង ពលកម្មកុមារ សហព័ន្ធនិយោជក និងសមាគមអាជីវកម្មនៅកម្ពុជា និងគណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលទទួលបន្ទុកសិទ្ធិកុមារ ដែលជាតំណាងឱ្យអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលជាង៣០ ដែលធ្វើការដើម្បីកែលម្អល័ក្ខខ័ណ្ឌនានាសំរាប់កុមារ។

អនុគណៈកម្មាធិការជាតិពលកម្មកុមារ បានបង្កើតផែនការសកម្មភាពជាតិស្តីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ចំណែកឯសមាជិកធ្វើជាជនបង្គោល ផ្នែកពលកម្មកុមារក្នុងស្ថាប័ន និងអង្គការរបស់ខ្លួន ដើម្បីលើកកម្ពស់ ការយល់ដឹង និងបញ្ជ្រាបការងារ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្ម





កុមារ។ អនុគណៈកម្មាធិការនេះក៏ធ្វើការពិនិត្យឡើងវិញ និង អនុម័តលើកម្មវិធីពលកម្មកុមារ ដែលស្នើឡើងដោយរដ្ឋាភិបាល ឬទីភ្នាក់ងារឯកជន និងពិនិត្យតាមដានលទ្ធផលទាំងឡាយនៃការអនុវត្តគំរោងកម្មវិធី។

### *បណ្តាញសង្គមស៊ីវិល ប្រឆាំងពលកម្មកុមារ ( CSNACL )*

ដើម្បីធ្វើប្រតិបត្តិការនៅថ្នាក់ជាតិ ក៏ដូចជានៅថ្នាក់ខេត្តតាំងពីឆ្នាំ ២០០៦ មកបណ្តាញសង្គមស៊ីវិលប្រឆាំងពលកម្មកុមារ ត្រូវបានបង្កើតឡើងដោយសារមិនមានស្ថាប័នសម្របសម្រួលណាមួយសំរាប់អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលទាំងអស់ដែលធ្វើការពាក់ព័ន្ធបញ្ហាកុមារ ដែលអាចដើរតួនាទី ក្នុងការបញ្ចប់ ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ គោលដៅនៃបណ្តាញនេះ គឺដើម្បីលើកទឹកចិត្តដល់អង្គការសង្គមស៊ីវិលជាច្រើនទៀត មិនមែនអង្គការក្រៅរដ្ឋាភិបាលទេក្នុងការរួមចំណែក ឆ្លើយតបពលកម្មកុមារក្នុងកម្មវិធីការងាររបស់ពួកគេ និងសម្របសម្រួលការងារនេះឱ្យបានល្អជាមួយស្ថាប័ន និងភ្នាក់ងារផ្សេងៗទៀត ដែលធ្វើការក្នុងវិស័យនេះ។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំ ប្រចាំត្រីមាស សមាជិកទាំងអស់ បានចែករំលែក ព័ត៌មាន អំពីកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងបញ្ហាប្រឈមនានារបស់ពួកគេ។ បណ្តាញសង្គមស៊ីវិលប្រឆាំងពលកម្មកុមារ ក៏បានផ្តល់វគ្គបណ្តុះបណ្តាល និងឯកសារលើកកម្ពស់ ការយល់ដឹងសំរាប់អង្គការសមាជិករបស់ខ្លួន ដើម្បីឱ្យពួកគេបញ្ជ្រាបពលកម្ម កុមារទៅក្នុងការងារនៃអង្គការរបស់ពួកគេ។ សមាជិកដែលមានការប្តេជ្ញាចិត្តខ្ពស់របស់បណ្តាញសង្គមស៊ីវិល ប្រឆាំងពលកម្មកុមារ គឺជាអង្គការដែលបាន និងកំពុងអនុវត្តកម្មវិធី សកម្មភាពរបស់អង្គការ ILO-IPEC ពីឆ្នាំ២០០៨-២០១២។

តាំងពីបណ្តាញសង្គមស៊ីវិលប្រឆាំងពលកម្មកុមារ ត្រូវបានបង្កើតឡើង បណ្តាញនេះបានសម្របសម្រួលកិច្ចសហការក្នុងចំណោមសម្ព័ន្ធអង្គការជាច្រើនដែលរួមមាន អង្គការនិយោជក និងសហជីពកម្មករ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ អ្នកអប់រំនានា និងសិស្ស និស្សិតទាំងឡាយ។

### *សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ( CAMFEBA )*

នៅថ្នាក់ជាតិ សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ដែលតំណាងឱ្យនិយោជកនាំមុខគេនៅកម្ពុជា ក៏ដូចជាសមាគមពាណិជ្ជកម្មឯកទេសមួយចំនួនមានគណៈកម្មាធិការពលកម្មកុមារមួយ ដែលជួបប្រជុំគ្នាទៀងទាត់ប្រចាំត្រីមាស ដើម្បីពិនិត្យមើលទៅ លើគំនិតផ្តួចផ្តើមនានាទាក់ទិននឹងពលកម្មកុមារ។ ចាប់តាំងពីឆ្នាំ២០០៤ នៅពេលដែលសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា បានធ្វើឱ្យពលកម្មកុមារក្លាយជាគំនិតផ្តួចផ្តើមនៃការទទួលខុសត្រូវសង្គមរបស់សាជីវកម្មមក សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា បានធ្វើការអនុវត្តគំនិតផ្តួចផ្តើមជាច្រើនដើម្បីបញ្ចប់ពលកម្មកុមារ ដែលទាំងនេះរួមមាន៖ ការបណ្តុះបណ្តាលជនបង្គោលផ្នែកពលកម្មកុមារ នៅភ្នំពេញ និងនៅ៦ខេត្តដែលធ្វើការប្រជុំ លើកកម្ពស់ការយល់ដឹងដល់និយោជកនៅថ្នាក់ខេត្ត និងថ្នាក់ក្រោមៗទៀត។ លើកកម្ពស់ការយល់ដឹងដល់និយោជក និងសាធារណៈជនតាមរយៈការផ្សាយតាមទូរទស្សន៍និងតាមព្រឹត្តប័ត្រស្តីពីពលកម្មកុមារបង្កើតការប្តេជ្ញាចិត្ត ប្រយុទ្ធប្រឆាំងពលកម្មកុមារ សំរាប់ពាណិជ្ជកម្មផ្ទាល់ ការបោះពុម្ពផ្សាយពីពលកម្មកុមារ លើសៀវភៅសរសេរសំរាប់សមាជិកសហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជា ដើម្បីឱ្យពួកគេយកទៅ ផ្តល់ឱ្យកូនចៅកម្មកររបស់ពួកគេ

ដែលក្នុងសៀវភៅនោះ មានទំព័រមួយចំនួន ត្រូវបានសរសេរព័ត៌មានគន្លឹះសំខាន់ៗ ដែលគួរយល់ដឹងអំពីពលកម្មកុមារ។ សហព័ន្ធនិយោជកនិងសមាគមពាណិជ្ជកម្មកម្ពុជាបានលើកទឹកចិត្តនិយោជកឱ្យសហការជាមួយសហជីពនានា ដើម្បីលើកកម្ពស់ការយល់ដឹងដល់កម្មករអំពីពលកម្មកុមារ និងបានដកស្រង់គោលការណ៍ណែនាំរបស់អង្គការ ILO-IPEC ទីក្រុងហ្សឺណែវសំរាប់និយោជក ដើម្បីជួយឱ្យពួកគេអាចបង្កើតគោលនយោបាយមានប្រសិទ្ធិភាព ក្នុងការទប់ស្កាត់ពលកម្មកុមារក្នុងអាជីវកម្មរបស់ខ្លួន និងក្រុមហ៊ុនផ្គត់ផ្គង់ពលកររបស់ពួកគេ ហើយក៏ណែនាំឱ្យក្រុមហ៊ុនមានគំនិតផ្តួចផ្តើមលើការទទួលខុសត្រូវសង្គមពាក់ព័ន្ធនឹងពលកម្មកុមារ។



### *គណៈកម្មាធិការអន្តរសហជីពកម្ពុជាលុបបំបាត់ពលកម្មកុមារ (ITUCL)*

គណៈកម្មាធិការអន្តរសហជីពកម្ពុជា លុបបំបាត់ពលកម្មកុមារ ដែលត្រូវបានបង្កើតនៅឆ្នាំ២០០៤ គឺជាអង្គការដែលមានអ្នកតំណាងចូលរួមមកពីសហជីពផ្សេងៗគ្នាជាច្រើន។ ដោយមានការផ្តល់មូលនិធិពីអង្គការ ILO-IPEC គណៈកម្មាធិការអន្តរសហជីពកម្ពុជាលុបបំបាត់ពលកម្មកុមារ បានជួលអ្នកសម្របសម្រួលម្នាក់ឱ្យផ្តល់វគ្គបណ្តុះបណ្តាល លើកកម្ពស់ការយល់ដឹងដល់មេដឹកនាំសហជីពនៅថ្នាក់ខេត្ត។ ដោយមានកិច្ចសហប្រតិបត្តិការល្អពីនិយោជក ជាលទ្ធផលមេដឹកនាំសហជីពបានធ្វើការផ្សព្វផ្សាយ លើកកម្ពស់ការយល់ដឹងដល់កម្មករនៅក្នុងសហគ្រាស ដើម្បីបញ្ឈប់ការបញ្ជូនកូនរបស់គេទៅធ្វើការ និងប្រឆាំងពលកម្មកុមារនៅក្នុងគ្រួសារ និងក្នុងសហគមន៍។

កតិកាសញ្ញារបស់ គណៈកម្មាធិការ អន្តរសហជីពកម្ពុជាលុបបំបាត់ពលកម្មកុមារ ក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារបានផ្តល់ការជំរុញ និងណែនាំសហជីពដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ ដោយលើកកម្ពស់ និងការពារសិទ្ធិកុមារកម្ពុជា។ នៅខេត្តកែប និងកំពត សហជីពមូលដ្ឋានបានអប់រំយ៉ាងសកម្ម ដល់ពលករអំពីផលប៉ះពាល់អវិជ្ជមាននៃពលកម្មកុមារ ហើយបានជួយកុមារ និងគ្រួសាររបស់កុមារឱ្យទទួលបាននូវធនធានចាំបាច់ ដើម្បីឱ្យកុមារឈប់ធ្វើការ ហើយចុះឈ្មោះចូលរៀនក្នុងសាលា ឬចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈបានពេញលេញ។

## អនុគណៈកម្មាធិការថ្នាក់ជាតិដើម្បីលុបបំបាត់ពលកម្មកុមារ

### *គណៈកម្មាធិការពលកម្មកុមារខេត្ត (PCCL)*

គណៈកម្មាធិការពលកម្មកុមារខេត្ត ដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំផែនការ ការអនុវត្ត ការបង្កើតគោលនយោបាយ និងការសម្របសម្រួលនៅថ្នាក់ខេត្ត។ គណៈកម្មាធិការពលកម្មកុមារខេត្ត ដឹកនាំដោយអភិបាល ឬអភិបាលរងខេត្ត ហើយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ធ្វើជាលេខាធិការដ្ឋាននៃ គណៈកម្មាធិការពលកម្មកុមារខេត្ត។ ក្នុងដំណាក់កាលទី២ TBP SP មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបានអនុវត្តការងារប្រចាំថ្ងៃ និងមើលខុសត្រូវកម្មវិធីសកម្មភាពរបស់អង្គការ ILO-IPEC នៅក្នុងខេត្ត និងសម្របសម្រួលការគ្រប់គ្រងទូទៅ និងការចាត់ចែងថវិកា។

សមាជិកនៃគណៈកម្មាធិការពលកម្មកុមារខេត្ត មានលក្ខណៈខុសៗ គ្នាបន្តិចបន្តួចពីខេត្តមួយទៅខេត្តមួយ ប៉ុន្តែជាទូទៅរួមមានដូចខាងក្រោម៖



❖ អភិបាល ឬអភិបាលរងខេត្ត ប្រធានក្រុមប្រឹក្សាឃុំ សមាជិកគណៈកម្មាធិការស្ត្រីនិងកុមារឃុំនគរបាលឃុំ អភិបាលស្រុក មន្ត្រីសុខាភិបាលស្រុក។

❖ អ្នកតំណាងមកពីមន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរកិច្ចការនារី មន្ទីរព័ត៌មាន មន្ទីរផែនការ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

❖ អ្នកតំណាងមកពីបណ្តាញសង្គមស៊ីវិលប្រឆាំងពលកម្មកុមារ សមាគមនិយោជក សហព័ន្ធសហជីព នគរបាល និងយោធា។

ក្នុងអំឡុងពេលកិច្ចប្រជុំប្រចាំត្រីមាស នៃគណៈកម្មាធិការពលកម្មកុមារខេត្ត សមាជិកទាំងអស់រាយការណ៍ ពីការងាររបស់ខ្លួន និងសុំមតិយោបល់ពីសមាជិកផ្សេងៗទៀត អំពីវិធីដោះស្រាយបញ្ហាប្រឈមរបស់ខ្លួន។ ឧទាហរណ៍ ប្រសិនបើសមាជិកណាមួយមានការលំបាកក្នុងការសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ដើម្បីដំឡើងក្តារផ្សព្វផ្សាយព័ត៌មានប្រឆាំងពលកម្មកុមារ បញ្ហានេះ អាចត្រូវបានលើកឡើងក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការពលកម្មកុមារខេត្ត ហើយអភិបាលខេត្តអាចណែនាំអាជ្ញាធរមូលដ្ឋានឱ្យយល់ព្រម។

សកម្មភាពដ៏សំខាន់មួយ របស់គណៈកម្មាធិការពលកម្មកុមារខេត្ត ដែលចូលរួមពីសមាជិកមួយចំនួន គឺការរៀបចំយុទ្ធនាការផ្សព្វផ្សាយប្រចាំឆ្នាំធំមួយ ក្នុងសហគមន៍មូលដ្ឋាន ដើម្បីលើកកម្ពស់ការយល់ដឹងអំពី ពលកម្មកុមារ និងថ្លែងអំណរគុណដល់ប្រជាជនមូលដ្ឋានជាច្រើន ដែលកំពុងខិតខំធ្វើការយ៉ាងលំបាកដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ។ យុទ្ធនាការនេះត្រូវបានរៀបចំដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដោយមានការជួយជ្រោមជ្រែងពីមន្ទីរព័ត៌មាន អ្នកអប់រំ និងស្ថាប័នដទៃទៀត ហើយមនុស្សរាប់រយនាក់ត្រូវបានអញ្ជើញឱ្យចូលរួម។ នៅក្នុងព្រឹត្តិការណ៍នេះ អតីតពលករកុមារច្រៀងចំរៀង និងសំដែងរឿងកំប្លែងដែលពួកគេបានរៀនក្នុងសាលារដ្ឋ និងសាលាក្រៅប្រព័ន្ធ។ កុមារ ក៏អាចប្រកួតប្រជែងគ្នាផងដែរ ក្នុងការឆ្លើយសំណួរដើម្បីឈ្នះរង្វាន់ស្តីពីចំណេះដឹង ព័ត៌មានទាក់ទិននឹងពលកម្មកុមារ។ ក្នុងអំឡុងព្រឹត្តិការណ៍ទាំងនេះ ប្រសិនបើគណៈ កម្មាធិការស្វែងរកអ្នកឧបត្ថម្ភគាំទ្រកុមារ ក្នុងមូលដ្ឋានបានជោគជ័យពេលនោះកុមារក្រីក្រខ្លះ នឹងទទួលបានការឧបត្ថម្ភសម្ភារៈសិក្សាសំរាប់រយៈពេលពេញមួយឆ្នាំ។ រីឯឪពុកម្តាយរបស់កុមារក៏អាចទទួលបានអង្ករមួយបាវ ហើយប្រសិនបើអ្នកឧបត្ថម្ភទាំងនោះ មានចិត្តសប្បុរសធម៌ថែមទៀតនោះ សិស្សជំទង់ដែលរៀនពូកែ ក៏អាចទទួលបានកង់មួយគ្រឿង សំរាប់ធ្វើដំណើរទៅរៀន ដែលមានចំងាយ ៥ ឬ ១០គីឡូម៉ែត្រ ទៅកាន់អនុវិទ្យាល័យ ឬវិទ្យាល័យផងដែរ។

### *គណៈកម្មាធិការអនុវត្តកម្មវិធីសកម្មភាព (APIC)*

ក្នុងដំណាក់កាលទី២ នៃ TBP SP គណៈកម្មាធិការយ៉ាងសំខាន់លំដាប់ទីពីរ នៅថ្នាក់ខេត្ត គឺគណៈកម្មាធិការអនុវត្តកម្មវិធីសកម្មភាព ILO-IPEC ដែលជា ចលករនាំឱ្យមានការជួបប្រជុំគ្នាពីភាគីពាក់ព័ន្ធនានា ដែលរួមមានស្ថាប័ននានារបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលសង្គមស៊ីវិល និងអង្គការសមាជិកដែលអនុវត្តកម្មវិធីសកម្មភាពរបស់អង្គការ ILO-IPEC ក៏ដូចជាអ្នកត្រួតពិនិត្យ ពលកម្មកុមារ នៅសហគមន៍ នៅកន្លែងធ្វើការ និងនៅតាមសាលារៀនជាដើម។ កិច្ចប្រជុំរបស់គណៈកម្មាធិការអនុវត្តកម្មវិធីសកម្មភាព ត្រូវបានធ្វើឡើងរៀងរាល់ពីរខែម្តង និង អាចញឹកញាប់ជាងនេះបើចាំបាច់ ដែលត្រូវកោះប្រជុំដោយប្រធានមន្ទីរការងារបណ្តុះបណ្តាល និងវិជ្ជាជីវៈខេត្ត។ ក្នុងអំឡុងកិច្ចប្រជុំទាំងនេះ សមាជិកទាំងអស់រាយការណ៍ពីការងាររីកចំរើន និងបញ្ហាប្រឈមរបស់ខ្លួន និងស្នើសុំមតិ យោបល់ពីសមាជិកឯទៀតអំពីវិធីសាស្ត្រ ឆ្លើយតបបញ្ហាប្រឈមនានា។ វគ្គបណ្តុះបណ្តាលផ្សេងៗទៀត ក៏ត្រូវបានផ្តល់ដោយគណៈកម្មាធិការនេះផងដែរ ដូចជាវគ្គរៀនសូត្រ ពីការធ្វើរបាយការណ៍វឌ្ឍនភាព ផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុការប្រើប្រព័ន្ធត្រួតពិនិត្យតាមដាន និងរាយការណ៍ពីអ្នកទទួលផលដោយផ្ទាល់ ការគ្រប់គ្រងគម្រោង ការសរសេរ សំណើរគម្រោងវគ្គបណ្តុះបណ្តាល អំពីពលកម្មកុមារ និង បុព្វហេតុនិងផលវិបាកនៃពលកម្មកុមារ អនុសញ្ញាលេខ ១៣៨ និងលេខ១៨២ នៃអង្គការពលកម្មអន្តរជាតិ ច្បាប់ការងារ និងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារ ការត្រួតពិនិត្យពលកម្មកុមារ និងការបញ្ជ្រាបយេនឌ័រ។ល។



***គណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ (CCWC)***

យន្តការសម្របសម្រួលពាក់ព័ន្ធថ្មីមួយទៀត នៅថ្នាក់ក្រោមជាតិ គឺគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ ដែលទទួលខុសត្រូវលើស្ត្រី និងកុមារនៅថ្នាក់ឃុំ និងភូមិ។ សមាជិកគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ មានទាំងប្រធានមណ្ឌលសុខភាព នាយកសាលា ប្រធានភូមិ និងនគរបាលឃុំ។



ការអភិវឌ្ឍសមត្ថភាពគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ឃុំ គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរយៈពេលវែង របស់រដ្ឋាភិបាលសំដៅធ្វើវិមជ្ឈការ និងវិសហមជ្ឈការអំណាចពីរដ្ឋាភិបាលថ្នាក់ជាតិ។ ចាប់តាំងពីឆ្នាំ ២០០២ កម្ពុជាបានបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ ហើយប៉ុន្មានឆ្នាំបន្តបន្ទាប់មកនេះ បរិក្ខា មធ្យោបាយការងារ សមត្ថភាពជំនាញគ្រប់គ្រងរដ្ឋបាល និងការទទួលខុសត្រូវរបស់ពួកគេក៏ត្រូវបានពង្រឹងជាបន្តបន្ទាប់ផងដែរ។ នៅទូទាំងប្រទេសកម្ពុជាមាន ១.៦៣៣ ឃុំ សង្កាត់ ដែលមានទំហំប្រជាពលរដ្ឋខុសៗ គ្នាចាប់ពី ៣.០០០នាក់ ដល់ ៩.០០០នាក់ និងមានពី៣ដល់៣០ភូមិ។

ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់ឃុំសង្កាត់ គឺជាអាទិភាពចំបងរបស់ទីភ្នាក់ងារផ្តល់ជំនួយនានា នៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍សមត្ថភាពត្រូវបានកំណត់គោលដៅ ជាពិសេសលើគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ ពីព្រោះតួនាទីគណៈកម្មាធិការនេះ គឺត្រួតពិនិត្យកម្មវិធីសុខុមាលភាព (ឧ. ដើម្បីកែលម្អសុខភាពមាតា និងទារកអាហារូបត្ថម្ភ បង្កើនការចូលរៀនរបស់កុមារីដល់មធ្យមសិក្សា និងធ្វើឱ្យប្រសើរឡើងនូវទឹកស្អាត និងអនាម័យនៅមូលដ្ឋាន)។

ការងារជាមូលដ្ឋាន ដើម្បីអាចឱ្យគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ សង្កាត់ ទទួលខុសត្រូវជាចំបងលើ ពលកម្មកុមារត្រូវបានដាក់ចុះតាមរយៈកម្មវិធីអភិវឌ្ឍន៍សមត្ថភាព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលប្រតិបត្តិការដោយនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាននៃក្រសួងមហាផ្ទៃ។ ក្នុងភាពជាដៃគូជាមួយអង្គការ ILO-IPEC នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន បានបង្កើតកម្មវិធីបណ្តុះបណ្តាលមួយសំរាប់សមាជិកក្រុមប្រឹក្សាឃុំសាកល្បង៣៩ឃុំ ស្តីពីវិធីបញ្ជ្រាបបញ្ហាពលកម្មកុមារទៅក្នុងផែនការ និងថវិកាឃុំ។ នៅឆ្នាំ ២០១៣ នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន រំពឹងថានឹងពង្រីកការបណ្តុះបណ្តាលដូចគ្នាពីពលកម្មកុមារដល់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងសមាជិកគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៅគ្រប់ឃុំទូទាំងប្រទេសកម្ពុជា។



## អ្វីដែលការអនុវត្តល្អនេះ សំរេចបាន និងភស្តុតាងចំពោះលទ្ធផលនេះ

នៅក្នុងអំឡុងពេលសំភាសន៍ ដែលបានធ្វើឡើង សំរាប់របាយការណ៍ ស្តីពីការអនុវត្តល្អនេះ សមាជិកក្រុមពិភាក្សាមួយចំនួននៅខេត្តកែប និងកំពត និងសៀមរាបបានរៀបរាប់ពីអត្ថប្រយោជន៍ខាងក្រោម សំរាប់ការចូលរួម ក្នុងគណៈកម្មាធិការដែលលើកឡើងខាងលើ។ អត្ថប្រយោជន៍ទាំងនេះក៏ត្រូវបានឯកភាពផងដែរ នៅពេលដែលត្រូវបានលើកឡើងក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត និងថ្នាក់ជាតិក្នុងក្រុមពិភាក្សា ដែលបានធ្វើឡើងសំរាប់ការសិក្សាស្តីពីការបង្កើតបរិយាកាសគាំទ្រ/អំណោយផលនៅខេត្តកែប និងកំពត[3] និងក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីការវាយតម្លៃគម្រោងសម្រាប់ដំណាក់កាលទី២៖




- បង្កើនការយល់ដឹងរបស់សមាជិកគណៈកម្មាធិការអំពីបញ្ហាពលកម្មកុមារ និងតាមរយៈនេះពួកគេមានការប្តេជ្ញាចិត្ត និងមានប្រសិទ្ធិភាពក្នុងការបញ្ចប់ពលកម្មកុមារ។
- បង្កើនការយល់ដឹង របស់សមាជិកគណៈកម្មាធិការអំពីវិធីដែលស្ថាប័ន និងអង្គការដទៃទៀត កំពុងធ្វើការដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- លើកទឹកចិត្តអ្នកចូលរួម ឱ្យបញ្ជ្រាបពលកម្មកុមារទៅក្នុងផែនការការងាររបស់ពួកគេ និងបែងចែក ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុដើម្បីបញ្ចប់ពលកម្មកុមារ។
- សម្របសម្រួលកិច្ចសហការ ក្នុងចំណោមភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ និងស្វែងរកធនធានដើម្បីជួយពលករកុមារ និងគ្រួសារពួកគេដើម្បីកុមារអាចឈប់ធ្វើការ និងចូលរៀនក្នុងសាលា ឬវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ទទួលមតិយោបល់ពីភាគីពាក់ព័ន្ធ អំពីវិធីដោះស្រាយបញ្ហាដែលខ្លួនកំពុងជួបប្រទះក្នុងកិច្ចខិតខំប្រឹងប្រែងបញ្ឈប់ពលកម្មកុមារ។
- បង្កើតទំនាក់ទំនងល្អជាមួយអ្នកត្រួតពិនិត្យពលកម្មកុមារឯទៀត ដើម្បីអាចចាត់វិធានការឆាប់រហ័សនៅពេលរកឃើញសហគ្រាសមួយកំពុងជួលកុមារ ឬនៅពេលកុមារដែលត្រូវបានដកហូត មិនបានមកសាលារៀន ឬចូលរួមវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយដែលគេជឿថាកុមារនោះត្រឡប់ទៅធ្វើការម្តងទៀត។
- ទទួលចំណេះដឹងអំពីកម្មវិធី និងសេវាដែលអាចជួយគ្រួសារ ដែលចង់ដកហូតកូនរបស់ខ្លួនចេញពីពលកម្ម។
- ផ្តល់ការទទួលស្គាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់ជនណាដែលខិតខំធ្វើការ ដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។
- សម្របសម្រួលកិច្ចសហការ និងសម្របសម្រួលល្អ ក្នុងចំណោមស្ថាប័នជាច្រើននៃរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនៅ ខេត្តកំពតក្នុងការលុបបំបាត់ពលកម្មកុមារពីវិស័យផលិតអំបិល និងការកាត់បន្ថយពលកម្មកុមារយ៉ាងច្រើន នូវទម្រង់ធ្ងន់ធ្ងរដទៃទៀតនៅខេត្តកែប។

## បញ្ហាប្រឈមនានា និងមេរៀនបទពិសោធន៍ក្នុងដំណើរការនៃការអនុវត្តល្អនេះ

### មិនមានផ្តល់ប្រាក់លើកទឹកចិត្តសម្រាប់ការងារពេលយប់ និងចុងសប្តាហ៍ និងមិនមានប្រាក់ឧបត្ថម្ភគ្រប់គ្រាន់សម្រាប់ថ្លៃសាំង និងអាហារ

ក្នុងក្រុមពិភាក្សាមួយចំនួន ដែលធ្វើឡើងសំរាប់របាយការណ៍

3 ILO-IPEC. 2013. ការសិក្សាទៅលើបរិយាកាសគាំទ្រ/អំណោយផលដើម្បីកាត់បន្ថយពលកម្មកុមារក្នុងវិស័យស្រែអំបិលនៅខេត្តកំពត និងជាទូទៅនៅខេត្តកែប (Phnom Penh, ILO). អាចរកបាននៅ: www.ilo.org/ipecinfo/product/download.do?type=document&id=22115.



## ល័ក្ខខ័ណ្ឌគន្លឹះសំរាប់បន្តអនុវត្ត និងធ្វើឱ្យមាននិរន្តរភាព ចំពោះការអនុវត្តល្អនេះ

អនុសាសន៍ខាងក្រោមនេះត្រូវបានធ្វើឡើង ក្នុងក្រុមពិភាក្សា និងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ខេត្ត និងថ្នាក់ជាតិដែលធ្វើឡើង សំរាប់ការសិក្សាស្តីពីការអនុវត្តល្អនេះ។ អនុសាសន៍ដែលធ្វើឡើង ក្នុងក្រុមពិភាក្សាសំរាប់ការសិក្សាអំពីការបង្កើតបរិយាកាសគាំទ្រនៅខេត្តកែប និងកំពត[4] ក៏ដូចជាក្នុងសិក្ខាសាលាភាគីពាក់ព័ន្ធលើការ វាយតម្លៃបញ្ចប់គម្រោង ៖

- ❖ បង្កើតគោលនយោបាយនានា និង បទប្បញ្ញត្តិ (ប្រកាស) សំរាប់គ្រប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ដែលធ្វើវាឱ្យកាន់តែច្បាស់លាស់ សំរាប់និយោជក ឳពុកម្តាយ និងអ្នកឯទៀតដែលចែងថាជនណាមានអាយុតិចជាង ១៨ ឆ្នាំត្រូវហាមឃាត់មិនឱ្យធ្វើការប្រកបដោយគ្រោះថ្នាក់ (ប្រកាសស្តីពីវិស័យស្រែអំបិលត្រូវបានចាត់ទុកថា ជាឧទាហរណ៍ល្អ)។

ស្តីពីការអនុវត្តល្អនេះ អ្នកត្រួតពិនិត្យពលកម្មកុមារ ក្នុងសហគមន៍ បានត្អូញត្អែរថា ពួកគេមិនបានទទួលប្រាក់លើកទឹកចិត្តបន្ថែមសំរាប់ធ្វើការនៅពេលយប់ ឬនៅចុងសប្តាហ៍ ដែលអាចឱ្យពួកគេបានជួបឳពុកម្តាយ និងពលករកុមារ។ ពួកគេក៏ត្អូញត្អែរទៀតថា ប្រាក់ឧបត្ថម្ភសំរាប់សាំងម៉ូតូ និងអាហារក៏មិនគ្រប់គ្រាន់ដែរ។

### មានឃុំមួយចំនួនតូចបានបញ្ជ្រាបពលកម្មកុមារក្នុងផែនការ និងថវិកាឃុំ

ថ្វីបើ ការបណ្តុះបណ្តាលត្រូវបានផ្តល់ឱ្យ សមាជិកក្រុមប្រឹក្សាឃុំ ដើម្បីជួយឱ្យពួកគេដាក់បញ្ចូលគំនិតផ្តួចផ្តើមនានាអំពីពលកម្មកុមារទៅក្នុងផែនការ និងថវិកាឃុំ និងបែងចែកថវិកាសំរាប់ការងារនេះក៏ដោយ ក៏បុគ្គលិករដ្ឋបាលមូលដ្ឋានខេត្ត បានរាយការណ៍ថាមាន ឃុំមួយចំនួនតូចប៉ុណ្ណោះដែលបានធ្វើ។ ការបែងចែកថវិកាដល់គណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារឃុំគឺសំខាន់សំរាប់ផ្នែកគាំពារមាតា និងទារក និងអំពើហិង្សាក្នុងគ្រួសារ។ រដ្ឋាភិបាលបែងចែកថវិកាតិចតួច ឬគ្មានសោះចំពោះគំនិតផ្តួចផ្តើមប្រយុទ្ធប្រឆាំងពលកម្មកុមារហើយផែនការនិងថវិកាឃុំជាទូទៅផ្តល់អាទិភាពទៅលើហេដ្ឋារចនាសម្ព័ន្ធ។



- ❖ មានផែនការសកម្មភាពច្បាស់លាស់ ដោយមានគោលដៅអាចវាស់វែងបានពីថ្នាក់ខេត្ត ដល់ថ្នាក់សហគមន៍។
- ❖ ផ្តល់វគ្គបណ្តុះបណ្តាលម្តងម្កាលអំពីព័ត៌មានសំខាន់ៗលើពលកម្មកុមារ ពីព្រោះអ្នកតំណាង ដែលបានតែងតាំងឱ្យចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលពលកម្មកុមារបានប្តូរការងារ ហើយអ្នកជំនួស ត្រូវការការបណ្តុះបណ្តាល។



---

4 ILO-IPEC. 2013. ការសិក្សាពីបរិយាកាសគាំទ្រ/អំណោយផលដើម្បីកាត់បន្ថយពលកម្មកុមារ,... (2013), op cit.

❖ រៀបចំប្រជុំគណៈកម្មាធិការសម្របសម្រួលទៀងទាត់ ហើយធ្វើឱ្យប្រាកដថាអ្នកចូលរួមទាំងអស់ទំនាក់ទំនង ផ្តល់ព័ត៌មានឱ្យគ្នាទៅវិញទៅមកបានច្បាស់លាស់ ដើម្បីឱ្យពួកគេអាចសម្របសម្រួលការងារ និងជួយបំពេញឱ្យគ្នាទៅវិញទៅមក លើកិច្ចខិតខំប្រឹងប្រែងរួមទាំងឡាយ។

❖ ផ្តល់ការតភ្ជាប់រវាងគ្រប់បណ្តាញនៃភាគីពាក់ព័ន្ធទាំងអស់ពីថ្នាក់ជាតិដល់ថ្នាក់សហគមន៍។

❖ ផ្តល់ថវិកាគ្រប់គ្រាន់ និងអភិវឌ្ឍន៍សមត្ថភាពសមាជិកគណៈកម្មាធិការ ទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំពីព្រោះពួកគេជាជំរើសល្អមួយសំរាប់ការត្រួតពិនិត្យពលកម្មកុមារនៅថ្នាក់សហគមន៍។ អ្នកភូមិមានការគោរពមនុស្សដែលបានទទួលការបោះឆ្នោតជ្រើសតាំង ជាក្រុមប្រឹក្សាឃុំ ហើយបើសមាជិកក្រុមប្រឹក្សាឃុំធ្វើការមិនល្អ អ្នកបោះឆ្នោតនឹងមិនបោះឆ្នោតគាំទ្រឱ្យពួកគេទៀតទេ។ សមាជិក គណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារនៃក្រុមប្រឹក្សាឃុំ ក៏នឹងដើរតួនាទី កាន់តែសំខាន់ក្នុងការបង្កើតសំណាញ់សុវត្ថិភាពសង្គមរបស់រដ្ឋាភិបាល (ជាឧទាហរណ៍ ការជួយចុះបញ្ជីគ្រួសារក្រីក្រដើម្បីទទួលបានសេវាសុខភាពដោយឥតគិតថ្លៃ)។

❖ បញ្ជ្រាបពលកម្មកុមារក្នុងផែនការឃុំ និងខេត្តដើម្បីឱ្យមានការផ្តល់ថវិកាគ្រប់គ្រាន់។

❖ ផ្តល់ប្រាក់ឧបត្ថម្ភការងារ លើសម៉ោងដល់បុគ្គលិករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានធ្វើការលើពលកម្មកុមារនៅពេលយប់ និងចុងសប្តាហ៍ ហើយត្រូវផ្តល់ប្រាក់ឧបត្ថម្ភសំរាប់សាំងម៉ូតូ និងអាហារឱ្យបានគ្រប់គ្រាន់។



❖ ផ្តល់ប្រាក់ឧបត្ថម្ភ ដើម្បីទូទាត់ការចំណាយរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលពលកម្មកុមារ។

❖ ជ្រើសរើសអាចារ្យពុទ្ធសាសនា អ៊ីស្លាមសាសនា និងគ្រីស្តសាសនា បញ្ចូលក្នុងគណៈកម្មាធិការពលកម្មកុមារថ្នាក់ឃុំ និងខេត្ត។ ក្នុងករណីព្រះសង្ឃពុទ្ធសាសនាគួរស្នើក្រសួងធម្មការ និងសាសនា ដើម្បីឱ្យសង្ក្រាជវត្ត ឬគ្រូសូត្រស្តាំ/ឆ្វេង ចូលរួមកៀរគរធនធានលើកកម្ពស់ការយល់ដឹង និងសម្តែងធម៌ទេសនាអំពីការប្រយុទ្ធប្រឆាំងពលកម្មកុមារ។

❖ បង្កើតក្លឹបពលកម្មកុមារនៅក្នុងភូមិសំរាប់អតីតពលករកុមារ។

❖ ដើម្បីផ្តល់សិទ្ធិអំណាច ក៏ដូចជាការដោះស្រាយបញ្ហាឱ្យមានប្រសិទ្ធភាព គួរមានមន្ត្រីថ្នាក់ខ្ពស់ចូលរួមដឹកនាំគណៈកម្មាធិការសម្របសម្រួលពលកម្មកុមារ។

❖ បញ្ចូលអតីតពលករកុមារទៅជាសមាជិកគណៈកម្មាធិការសម្របសម្រួលពលកម្មកុមារ។



# ២- ប្រយុទ្ធប្រឆាំងពលកម្មកុមារជាមួយអ្នកត្រួតពិនិត្យ ពលកម្មកុមារ នៅសហគមន៍



# សេចក្ដីសង្ខេប

ប្រព័ន្ធត្រួតពិនិត្យកម្រិតសហគមន៍ដែលអង្គការ ILO-IPEC និងដៃគូទាំងឡាយបានបង្កើតឡើងនៅកម្ពុជា សម្រាប់ការលុបបំបាត់ពលកម្មកុមារ គឺត្រូវបានគេទទួលស្គាល់យ៉ាងទូលំទូលាយថាជាការអនុវត្តល្អមួយ ពីព្រោះមានមនុស្សជាច្រើនបានចូលរួមក្នុងសកម្មភាពនេះ ដូចជាមន្ត្រីអធិការកិច្ចការងារ នាយកសាលា គ្រូបង្រៀន មេឃុំ ប្រធានភូមិ សមាជិកគណៈកម្មការស្ត្រី និងកុមារឃុំ អ្នកដឹកនាំសាសនានានា បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើការតាមសហគមន៍ ប្រធានសហជីព និយោជក និងនគរបាល ដែលអ្នកទាំងនោះមានការទទួលខុសត្រូវជាច្រើន ដែលអាចរាប់បញ្ចូលក្នុងការលើកកម្ពស់សុខុមាលភាពកុមារក្រីក្រ។ ប្រសិនបើមនុស្សទាំងនេះត្រូវបានបណ្ដុះបណ្ដាល ត្រឹមត្រូវអំពីតួនាទីរបស់ពួកគេក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ ហើយមានការគាំទ្រដោយការងារគ្រប់គ្រងល្អ ការសម្របសម្រួលល្អ មានធនធានគ្រប់គ្រាន់នោះ ការងាររបស់ពួកគេដើម្បីបញ្ចប់ពលកម្មកុមារអាចមានប្រសិទ្ធភាពខ្ពស់ និងមាននិរន្តរភាពយូរអង្វែងទៀតផង។

# សាវតា

ឧបករណ៍ដ៏សំខាន់សម្រាប់ការ ដកហូតកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ គឺការត្រួតពិនិត្យ។ ដំណាក់កាលដំបូងនៃការងារនេះគឺការកំណត់មុខសញ្ញាកុមារ ដែលកំពុងស្ថិតក្នុងទម្រង់ធ្ងន់ធ្ងរ ឬស្ថិតក្នុងហានិភ័យនៃការធ្លាក់ចូលទៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ព្រមទាំងធ្វើការប៉ាន់ប្រមាណលើការគាំទ្រអ្វីខ្លះដែលពួកគេ និងក្រុមគ្រួសាររបស់ពួកគេត្រូវការដើម្បីឱ្យកុមារទាំងនោះឈប់ធ្វើការ ហើយទទួលបានការអប់រំគ្រប់គ្រាន់ ឬទទួលបានការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈត្រឹមត្រូវ។ បន្ទាប់មក ក្រោយពីការបញ្ចុះបញ្ចូលឪពុកម្ដាយដើម្បីឱ្យដកហូតកូនៗ របស់ពួកគេពីពលកម្មការចុះទៅពិនិត្យសាកសួរ គឺចាំបាច់ណាស់ដែលយ៉ាងហោចឱ្យបាន៦ខែ ដើម្បីធានាថាកុមារ និងឪពុកម្ដាយរបស់ពួកគេទទួលបានជំនួយគាំទ្រដូចដែលបានសន្យា ហើយកុមារទាំងនោះនៅបន្តការសិក្សា និងមិនវិលត្រឡប់ទៅធ្វើការវិញទេ។ ការចុះពិនិត្យសាកសួរទាំងនេះគឺជួយដោះស្រាយផងដែរនូវបញ្ហានានារបស់កុមារ ឬឪពុកម្ដាយដែលអាចរុញច្រានឱ្យកុមារវិលត្រឡប់ទៅធ្វើការងារវិញ។ទោះបីជាការត្រួតពិនិត្យពលកម្មកុមារត្រូវបានគេទទួលស្គាល់ជាទូទៅថាជាឧបករណ៍ដ៏សំខាន់មួយសម្រាប់បញ្ចប់ពលកម្មកុមារក៏ដោយ តែបញ្ហាត្រង់ថា តើត្រូវធ្វើដូចម្ដេចដើម្បីឱ្យការងារនេះមានដំណើរការត្រឹមត្រូវ និងនិរន្តរភាពនៅពេលដែលថវិកាមានកំរិត។

# វិធីដែលការអនុវត្តល្អនេះត្រូវបានប្រតិបត្តិ

## អ្នកត្រួតពិនិត្យពលកម្មកុមារផ្លូវការនៅកម្រិតសហគមន៍

ប្រព័ន្ធរបស់កម្ពុជាសម្រាប់ការបញ្ចប់ពលកម្មកុមារ ដែលបានវិវត្តជាង១០ឆ្នាំមកនេះ ចំពោះការងារពាក់ព័ន្ធលើបញ្ហាពលកម្មកុមារនៅកម្ពុជា គឺត្រូវបានផ្ដោតជាសំខាន់នៅថ្នាក់ភូមិ និងថ្នាក់ឃុំ ហើយប្រើប្រាស់ការត្រួតពិនិត្យទាំងផ្លូវការ និងមិនផ្លូវការ[5] មួយចំនួន។ អ្នកត្រួតពិនិត្យពលកម្មកុមារនៅថ្នាក់ភូមិ និងឃុំ រួមមានប្រធានឃុំ ឬសមាជិកក្រុមប្រឹក្សាឃុំ ជាអ្នកត្រួតពិនិត្យពលកម្មកុមារនៅសហគមន៍ ហើយគ្រូបង្រៀនជាអ្នកត្រួតពិនិត្យពលកម្មកុមារនៅតាមសាលា។អ្នកត្រួតពិនិត្យពលកម្មកុមារទាំងពីរប្រភេទនេះ ត្រូវបានបណ្ដុះបណ្ដាលអំពីតួនាទីវិធីសាស្ត្រ ត្រួតពិនិត្យពិនិត្យពលកម្មកុមារ និងលើកកម្ពស់ការយល់ដឹងដោយអង្គការ ILO-IPEC។



5 ឃុំ សង្កាត់ គឺជារដ្ឋបាលថ្នាក់ក្រោមជាតិរបស់រដ្ឋាភិបាលកម្ពុជា ដែលចាប់តាំងពីឆ្នាំ២០០៣មក ត្រូវបានបង្កើនការទទួលខុសត្រូវលើការងារអភិបាលកិច្ច នៅកម្រិតសហគមន៍។ មានឃុំ សង្កាត់ ១.៦៣៣ នៅក្នុង២៣ខេត្ត រាជធានីនៅកម្ពុជា ហើយឃុំ សង្កាត់មានទំហំប្រជាពលរដ្ឋខុសៗគ្នាប្រមាណពី ៣.០០០ ទៅ ៩.០០០ នាក់។ វាអាស្រ័យលើចំនួនភូមិនៅក្នុងឃុំ សង្កាត់ ដែលខ្លះមានពីរបីភូមិពោលគឺពី៣ទៅ៣០ភូមិ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបោះឆ្នោតរៀងរាល់៥ឆ្នាំម្ដង ហើយការបោះឆ្នោតចុងក្រោយបំផុតនេះគឺនៅឆ្នាំ២០១២។

មន្ត្រីត្រួតពិនិត្យពលកម្មកុមារ ថ្នាក់សហគមន៍សំខាន់មួយទៀតគឺមន្ត្រីត្រួតពិនិត្យការងារដែលធ្វើការត្រួតពិនិត្យពលកម្មកុមារនៅតាមទីកន្លែងការងារ។ មន្ត្រីត្រួតពិនិត្យកន្លែងការងារទាំងនេះ គឺជាមន្ត្រីអធិការកិច្ចការងារដែលធ្វើការនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដើម្បីធានាថាគ្រឹះស្ថានអាជីវកម្មដែលបានចុះបញ្ជីជាផ្លូវការគោរពទៅតាមច្បាប់ការងារ និងបទប្បញ្ញត្តិនានា (ប្រកាស) ដែលបច្ចុប្បន្នមានដូចជាការទប់ស្កាត់ពលកម្មកុមារជាដើម។ មន្ត្រីទាំងនេះមានអំណាចនាំគរបាលទៅធ្វើអន្តរាគមន៍ និងផាកពិន័យចំពោះនិយោជកទាំងឡាយណាដែលរំលោភបំពានច្បាប់ការងារ។

ការបណ្តុះបណ្តាលដែលអង្គការ ILO-IPEC បានធ្វើឡើងសម្រាប់ការត្រួតពិនិត្យ ពលកម្មកុមារទាំងនោះ រួមមាន៖ ផលវិបាកជាអវិជ្ជមាននានានៃពលកម្មកុមារ ចំពោះកុមារនៅពេលបច្ចុប្បន្ន និងអនាគត សម្រាប់ជីវិតរបស់ពួកគេ អនុសញ្ញានានារបស់អង្គការ ILO ស្តីពីពលកម្មកុមារដែលរាជរដ្ឋាភិបាលបានចុះហត្ថលេខា ច្បាប់ និងបទប្បញ្ញត្តិនានា ច្បាប់ពាក់ព័ន្ធនឹងការចុះឈ្មោះចូលរៀន និងប្រភេទជំនួយផ្សេងៗទៀតដែលអាចត្រូវផ្តល់ដល់កុមារ និងឪពុកម្តាយរបស់គេ ប្រសិនបើកុមារឈប់ធ្វើការ ហើយចុះឈ្មោះចូលរៀនពេញម៉ោង ឬវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ហើយរក្សាការចូលរួមរៀនសូត្រទៀងទាត់។

## អ្នកត្រួតពិនិត្យពលកម្មកុមារក្រៅផ្លូវការនៅកម្រិតសហគមន៍

បើទោះបីជាមិនត្រូវបានចាត់តាំង ឱ្យធ្វើការជាផ្លូវការក៏ដោយ ក៏នាយកសាលា សមាជិកគណៈកម្មការស្ត្រី និងកុមារឃុំ អ្នកដឹកនាំសាសនាបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលនៅសហគមន៍ អ្នកដឹកនាំសហជីព និយោជក និងប៉ូលីសជាញឹកញយគាំទ្រដល់ការងារត្រួតពិនិត្យពលកម្ម កុមាររបស់អ្នកត្រួតពិនិត្យពលកម្មកុមារនៅតាមសហគមន៍ និងតាមសាលារៀន។ ឆ្លងកាត់ពេលវេលាកន្លងទៅ ខណៈដែលសហគមន៍មានការយល់ដឹង និងមានឆន្ទៈចូលរួមបញ្ចប់ពលកម្មកុមាររីកចំរើនឡើង សមាជិកសហគមន៍ទាំងនោះក៏អាចក្លាយជាផ្នែកមួយនៃប្រព័ន្ធត្រួតពិនិត្យពលកម្មកុមារផងដែរ ពីព្រោះថាពួកគេអាចរាយការណ៍ពីករណី ពលកម្មកុមារដល់អ្នកត្រួតពិនិត្យសហគមន៍ ហើយអាចជួយប្រមូលកៀរគរធនធានក្នុងសហគមន៍ដើម្បីផ្តល់លទ្ធភាពដល់កុមារឱ្យឈប់ធ្វើការ។

ខ្សែបន្ទាត់រាយការណ៍សម្រាប់ ការត្រួតពិនិត្យពលកម្មកុមារនៅកម្រិតខុសៗគ្នាគឺមានបង្ហាញខាងក្រោម។ បើទោះបីជាខ្សែបន្ទាត់នេះ បានបង្ហាញពីឋានានុក្រមយ៉ាងនេះក្តី ក៏ការរាយការណ៍ពីឧប្បទ្ទវហេតុនៃពលកម្មកុមារ អាចចាប់ផ្តើមនៅកម្រិតណាមួយនៃកម្រិតទាំងនេះបាន។

**ថ្នាក់ខេត្ត**
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត
- (អធិការកិច្ចការងារ/មន្ត្រីត្រួតពិនិត្យតាមកន្លែងការងារ)

**ថ្នាក់ឃុំ**
- មេឃុំ ឬជំទប់ឃុំ
- (គណៈកម្មាធិការស្ត្រី និងកុមារឃុំ នាយកសាលា នគរបាល បណ្តាញសង្គមស៊ីវិលប្រឆាំងពលកម្មកុមារ និងអង្គការមិនមែនរដ្ឋាភិបាលនានា ។ល។

**ថ្នាក់ភូមិ**
- ប្រធានភូមិ ឬអនុប្រធានភូមិ
- សមាជិកសហគមន៍

## ការកំណត់មុខសញ្ញាកុមារដែលត្រូវដកហូត និងទប់ស្កាត់ពីទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ជំហានដំបូងនៃការត្រួតពិនិត្យ អ្នកត្រួតពិនិត្យតាមសហគមន៍ និងតាមសាលារៀន ជួយដល់មន្ត្រីចុះសិក្សាអង្កេតមកពីមន្ទីរផែនការខេត្តដើម្បីកំណត់រកទីកន្លែងណា ដែលមានកុមារចំនួនច្រើនបំផុតកំពុងធ្វើការក្នុងទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ។ អ្នកត្រួតពិនិត្យតាមសហគមន៍ទាំងនោះធ្វើការចងក្រងព័ត៌មាន រៀបចំបញ្ជីឈ្មោះកុមារជាក់លាក់ដែលឪពុកម្តាយរបស់ពួកគេនឹងត្រូវផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកូនៗ របស់ពួកគេអាចត្រូវបានដកហូតពីពលកម្មទាំងស្រុង ហើយឱ្យចូលរួមតែក្នុងការអប់រំ ឬការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប៉ុណ្ណោះ ។

## ការបញ្ចុះបញ្ចូលឪពុកម្តាយឱ្យដកហូតកូនៗ របស់ពួកគេពីពលកម្ម និងការប៉ាន់ប្រមាណតម្រូវការរបស់កុមារ

នៅពេលធ្វើបញ្ជីឈ្មោះកុមារដែលត្រូវផ្តល់ការឧបត្ថម្ភគាំទ្ររួចហើយ អ្នកត្រួតពិនិត្យសហគមន៍ និងប្រធានភូមិ ដែលជា

អ្នកស្គាល់សមាជិកសហគមន៍ច្បាស់លាស់ ចុះពិនិត្យសាកសួរឪពុកម្តាយ ដែលមានកូនកំពុងធ្វើការ ដើម្បីពន្យល់ពីមូលហេតុដែលពួកគេគួរដកហូតកូនៗរបស់គេពីពលកម្ម ហើយចុះឈ្មោះចូលរៀនក្នុងសាលាពេញម៉ោង ឬវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ និងពន្យល់ពីជំនួយគាំទ្រអ្វីខ្លះដែលពួកគេអាចទទួលបាន ប្រសិនបើកូនៗរបស់ពួកគេឈប់ធ្វើការ ហើយចូលរៀនបានជាប់លាប់។ ការប៉ាន់ប្រមាណនេះប្រើប្រាស់និយមន័យពលកម្មកុមារដូចខាងក្រោម៖

"ការដកហូត"ប្រើសំរាប់កុមារដែលមានអាយុក្រោម១២ឆ្នាំដែលកំពុងធ្វើការក្នុងទម្រង់ណាមួយនៃពលកម្ម កុមារក្រោមអាយុ១៥ឆ្នាំ ដែលកំពុងធ្វើការក្នុងទម្រង់ពលកម្មណាមួយប្រកបដោយគ្រោះថ្នាក់ និងកុមារក្រោមអាយុ១៨ឆ្នាំ ដែលកំពុងធ្វើការក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្ម។ កុមារទាំងនេះត្រូវតែដកហូតពីការងារទាំងស្រុង ហើយត្រូវចុះឈ្មោះចូលរៀនក្នុងសាលា ឬវគ្គបណ្តុះបណ្តាលផ្សេងៗ។

"ការទប់ស្កាត់" ប្រើសំរាប់កុមារដែលមិនទាន់បានចូលរួមក្នុងកម្លាំងការងារ ប៉ុន្តែមិនបានចូលរៀនក្នុងសាលា ឬការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈណាមួយ ក៏ដូចជាប្រើសំរាប់កុមារ ដែលមានការរៀនសូត្រខ្សោយ ហើយងាយបោះបង់ការរៀនសូត្រនិងងាយចូលរួមក្នុងកម្លាំងការងារ។ កុមារទាំងពីរប្រភេទនេះត្រូវចុះឈ្មោះចូលរៀន ក្នុងសាលា ឬកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈណាមួយ ឬក៏ត្រូវទទួលជំនួយបន្ថែម ដើម្បីធានាថា កុមារនឹងមិនបោះបង់ការរៀនសូត្រ ឬបោះបង់ការរៀនជំនាញវិជ្ជាជីវៈនោះឡើយ ។

"ការការពារ" សំដៅលើកុមារដែលមានអាយុស្ថិតក្នុងចន្លោះពី១៥ ទៅ១៨ឆ្នាំ ដែលកំពុងធ្វើការប្រកបដោយគ្រោះថ្នាក់ និងគួរទទួលបានកិច្ចការពារសុវត្ថិភាព និងការគាំពារសុខភាពគ្រប់គ្រាន់ ដើម្បីពួកគេអាចស្ថិតក្នុងទីតាំងការងារបន្តទៀត ប៉ុន្តែមិនបន្តស្ថិតក្នុងការងារប្រកបដោយគ្រោះថ្នាក់ ដូចមានចែងដោយច្បាប់ជាតិ និងអន្តរជាតិឡើយ។



## ការប៉ាន់ប្រមាណលើការតម្រូវការអប់រំ

ប្រសិនបើឪពុកម្តាយយល់ព្រមបញ្ឈប់កូនៗ របស់ពួកគេពីការងារ អ្នកត្រួតពិនិត្យពលកម្មកុមារក្នុងសហគមន៍ធ្វើការប៉ាន់ប្រមាណ ដើម្បីស្វែងយល់ពីតម្រូវការរបស់គ្រួសារដើម្បីជួយដកហូតកុមារពីពលកម្មទាំងស្រុង ហើយចុះឈ្មោះចូលរៀនពេញម៉ោងក្នុងប្រព័ន្ធ ឬក្នុងវគ្គបណ្តុះបណ្តាលជំនាញផ្សេងៗ។ ការប៉ាន់ប្រមាណនេះ ជាបឋម ពិចារណាលើកម្រិតអប់រំរបស់កុមារដោយប្រៀបធៀប នឹងមិត្តភក្តិរបស់ពួកគេ។ ប្រសិនបើកុមារបានបោះបង់សាលារយៈពេលមួយឆ្នាំឬច្រើនជាងនេះ និងមានអាយុច្រើនជាងមិត្តរួមថ្នាក់ឯទៀតដែលរៀននៅកម្រិតដូចគ្នា ពលករកុមារត្រូវតែបានទទួលការអប់រំបំប៉នក្រៅប្រព័ន្ធរហូតដល់មួយឆ្នាំ ដែលនឹងជួយបង្កើនលទ្ធភាពដល់ពួកគេឱ្យរៀនទាន់កម្មវិធីសិក្សាក្នុងឆ្នាំ ដែលពួកគេបានបោះបង់ចោល។ ទោះជាយ៉ាងនេះក្តី ប្រសិនបើកុមារមានអាយុច្រើនជាង ១៥ឆ្នាំ ហើយមិនចង់ចូលរៀនក្នុងប្រព័ន្ធអប់រំ អ្នកត្រួតពិនិត្យពលកម្មកុមារក្នុងសហគមន៍នឹងរៀបចំឱ្យមានការចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជំនួសវិញ។



## ជំនួយឧបត្ថម្ភដល់កុមារដែលបានចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំ ឬវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ

ប្រសិនបើអតីតពលករកុមារចុះឈ្មោះចូលរៀនជាទៀងទាត់ក្នុងប្រព័ន្ធអប់រំ ហើយត្រូវការឯកសណ្ឋានសាលា ពួកគេនឹងទទួលបានឯកសណ្ឋាននោះ។ កុមារនឹងទទួលបានជាបន្តបន្ទាប់នូវបរិក្ខាសម្រាប់រៀនសូត្រដូចជា សៀវភៅសរសេរ ប៊ិច ខ្មៅដៃ ។ល។ គ្រួសាររបស់គេអាចទទួលបានជំនួយឧបត្ថម្ភផ្សេងៗទៀតផងដែរ។ ឧទាហរណ៍ និយោជកមួយចំនួនក្នុងវិស័យចំការកៅស៊ូ និងផលិតកម្មអំបិល បានផ្តល់អង្ករជារៀងរាល់ខែ ដល់កម្មករទាំងឡាយណាដែលជួយឱ្យកូនៗ របស់ពួកគេឈប់ធ្វើការ និងបង្កលក្ខណៈឱ្យកុមារបានរៀនសូត្រក្នុងសាលា ឬចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។ មានអង្គការមិនមែនរដ្ឋាភិបាលមួយ នៅក្នុងវិស័យផលិតកម្មអំបិល បានផ្តល់រថយន្តដើម្បីដឹកជញ្ជូនកូនៗរបស់កម្មករដែលត្រូវធ្វើដំណើរឆ្ងាយទៅមកសាលា។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ផ្តល់អាហារមួយពេលដល់កុមារក្រីក្រមុនពេលចូលរៀន ហើយនៅមានឧបការីជនក្នុងមូលដ្ឋានមួយចំនួនផ្តល់ទោចក្រយាន(កង់)ដល់កុមារជំទង់ៗដើម្បីឱ្យពួកគេអាចធ្វើដំណើរទៅរៀននៅសាលាមធ្យមសិក្សា ឬចូលរៀនវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈដែលស្ថិតនៅឆ្ងាយ។

ក្រោយពីបានធ្វើកិច្ចព្រមព្រៀងជាមួយឪពុកម្តាយ និងកុមាររួចហើយ ឈ្មោះកុមារទាំងនោះ នឹងត្រូវបានបញ្ជូនទៅប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ដែលបុគ្គលិករបស់គាត់នឹងចុះឈ្មោះកុមារ ទៅក្នុងប្រព័ន្ធត្រួតពិនិត្យតាមកុំព្យូទ័រសំរាប់ប្រើប្រាស់ ដើម្បីធានាថាកុមារ និងឪពុកម្តាយរបស់គេ នឹងទទួលបានផលប្រយោជន៍ដូចដែលបានសន្យា ហើយបន្តមកទៀត នឹងមានការត្រួតពិនិត្យជាប្រចាំ។ នៅក្នុងសហគមន៍មួយចំនួន អ្នកត្រួតពិនិត្យពលកម្មកុមារ ក្នុងសហគមន៍ បានធ្វើកិច្ចព្រមព្រៀងជាលាយល័ក្ខណ៍អក្សរដោយរៀបរាប់ពីការជួយគាំទ្រជាក់លាក់ដល់កុមារ និងឪពុកម្តាយដែលនឹងទទួលបានគាំទ្រ ហើយបន្ទាប់មក ទាំងអ្នកត្រួតពិនិត្យពលកម្មកុមារនៅសហគមន៍ និងឪពុកម្តាយចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនៅលើឯកសារនោះ។

នៅពេលកុមារចុះឈ្មោះចូលរៀននៅសាលា អ្នកត្រួតពិនិត្យពលកម្មកុមារនៅសាលា ជាទូទៅជាគ្រូបង្រៀន គឺជួយលុបបំបាត់ឧបសគ្គនានាដល់ការចុះឈ្មោះចូលរៀន ដូចជាឪពុកម្តាយមិនមានឯកសារផ្លូវការនានា ដែលតម្រូវឱ្យមានសម្រាប់ធ្វើការចុះឈ្មោះចូលរៀន មានដូចជាសំបុត្រកំណើតកំណត់ហេតុទាំងឡាយពីសាលាមុនៗ ឬសៀវភៅគ្រួសារដែលបញ្ជាក់ពីទីលំនៅរបស់គ្រួសារក្នុងភូមិជាដើម។ អ្នកត្រួតពិនិត្យពលកម្មកុមារនៅតាមសាលាស្នើដល់អ្នកគ្រប់គ្រងសាលានិងគ្រូប្រចាំថ្នាក់ផងដែរ មិនឱ្យទារថ្លៃផ្លូវការ ឬក្រៅផ្លូវការណាមួយពីកុមារឡើយ។ ថ្លៃទាំងនោះរួមមាន ថ្លៃចុះឈ្មោះចូលរៀនសម្រាប់កុមារ ដែលមិនមានឯកសារត្រឹមត្រូវ ថ្លៃថតចម្លងសៀវភៅមេរៀន ថ្លៃរៀនក្រៅម៉ោងបន្ថែម ដើម្បីបង្រៀននូវមេរៀនសំខាន់ៗ ដែលមិនបានបង្រៀនក្នុងម៉ោងថ្នាក់រៀន។ ក្នុងសាលាមួយចំនួន គ្រូមិនតម្រូវឱ្យបង់ប្រាក់ជាផ្លូវការ ឬក្រៅផ្លូវការទាំងនេះទេ ឬយ៉ាងហោចណាស់តម្រូវឱ្យសិស្សក្រីក្របង់ប្រាក់តិចតួចប៉ុណ្ណោះ។

## ការបង្កើនប្រាក់ចំណូលរបស់ឪពុកម្តាយតាមរយៈក្រុមជួយខ្លួនឯង

ដើម្បីជួយឪពុកម្តាយរបស់ពលករកុមារទាំងឡាយ ឱ្យមានលទ្ធភាពបង្កើនប្រាក់ចំណូលរបស់គេ ដើម្បីពុំចាំបាច់ឱ្យកូនៗរបស់គេធ្វើការ អ្នកត្រួតពិនិត្យសហគមន៍នឹងជួយឪពុកម្តាយទាំងនោះ ឱ្យបានចូលរួមក្រុមជួយខ្លួនឯង ប្រសិនបើមានក្រុមនេះក្នុងសហគមន៍។ ក្រុមជួយខ្លួនឯងទាំងនោះផ្តល់លទ្ធភាពដល់ឪពុកម្តាយដើម្បី៖ សន្សំប្រាក់ ទទួលបានការប្រាក់ពីប្រាក់សន្សំរបស់ពួកគេ ខ្ចីប្រាក់ចំនួនតិចតួចណាមួយ (៥ទៅ២០ដុល្លារអាមេរិក) សម្រាប់គោលបំណងសកម្មភាពបង្កើនប្រាក់ចំណូល ឬក៏សម្រាប់គោលបំណងផ្សេងៗទៀត ខ្ចីដោយមិនចាំបាច់បង់ ការប្រាក់នៅពេលមានធុរៈអាសន្នក្នុងគ្រួសារ និងការចូលរួមក្នុងការបណ្តុះបណ្តាលជំនាញដែលបានផ្តល់ដើម្បីលើកកម្ពស់ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ អាចចាប់ផ្តើមមុខរបរធុនតូច ឬរកប្រាក់ចំណូលបន្ថែម។ វគ្គបណ្តុះបណ្តាល ពីកម្មវិធីបង្កើនប្រាក់ចំណូលមានការចិញ្ចឹមមាន់ ត្រី ជ្រូក ការបណ្តុះផ្សិត ឬការធ្វើសិប្បកម្ម ឬកែច្នៃម្ហូបអាហារដូចជានំបញ្ចុក បង្អែមដើម្បីលក់នៅទីផ្សារជាដើម។



### ការងារផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹង អ្នកត្រួតពិនិត្យពលកម្មកុមារ

ស្របពេលជាមួយនឹងការត្រួតពិនិត្យពលកម្មកុមារ ដើម្បីដកហូតកុមារពីពលកម្ម មន្ត្រីត្រួតពិនិត្យនៅតាមកន្លែងការងារ នៅតាមសាលា និងនៅតាមសហគមន៍ទាំងឡាយ ក៏បានធ្វើការលើកកម្ពស់ ការយល់ដឹងអំពីពលកម្មកុមារផងដែរ។ ប្រធានភូមិជួយរៀបចំប្រជុំនៅកម្រិតសហគមន៍ដែលប្រធានឃុំនឹងពន្យល់ពីមូលហេតុ និងអត្ថប្រយោជន៍ ដើម្បីបញ្ចប់ពលកម្មកុមារ ហើយជាពិសេសទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ មន្ត្រីត្រួតពិនិត្យនៅតាមកន្លែងការងារ ជួយលើកកម្ពស់ការយល់ដឹងដល់និយោជកទាំងឡាយ នៅពេលគាត់រកឃើញកុមារណាម្នាក់នៅក្នុងកន្លែងធ្វើការនោះ រីឯអ្នកឃ្លាំមើលនៅតាមសាលារៀបចំឱ្យមានកិច្ចប្រជុំស្តីពី ការលើកកម្ពស់ការយល់ដឹងដល់គ្រូបង្រៀនទាំងឡាយ ដើម្បីឱ្យពួកគេមានការយល់ដឹងពីបញ្ហាពលកម្មកុមារ។ នៅពេលដែលមនុស្សទូទាំងសហគមន៍យល់ជ្រួតជ្រាបពីបញ្ហាពលកម្មកុមារ ពួកគេអាចជួយកំណត់រកពលករកុមារ និងរាយការណ៍ពីពលករកុមារទាំងនោះទៅអ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍។



### ការបន្តពិនិត្យផ្ទៀងផ្ទាត់លើកុមារដែលបានទទួលអត្ថប្រយោជន៍

យ៉ាងហោចណាស់នៅរៀងរាល់បីខែម្តង ក្រោយពីកុមារបានចុះឈ្មោះទទួលផលប្រយោជន៍រួចហើយ អ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ និងប្រធានភូមិចុះពិនិត្យសាកសួរគ្រួសារ ហើយប្រសិនបើចាំបាច់ ត្រូវពិនិត្យផ្ទៀងផ្ទាត់ជាមួយសាច់ញាតិ ឬអ្នកជិតខាងដើម្បីធ្វើឱ្យប្រាកដថាកុមារមិនធ្វើការងារទៀតទេ។ អ្នកត្រួតពិនិត្យពលកម្មកុមារនៅតាមសាលាត្រូវផ្ទៀងផ្ទាត់ផង ដែរលើកំណត់ហេតុវត្តមានរបស់កុមារដែលបានទទួលផលប្រយោជន៍ ដើម្បីធ្វើឱ្យប្រាកដថាពួកគេមិនមានអវត្តមានច្រើនពេកទេឬក៏មានបញ្ហាផ្សេងៗដែលចាំបាច់ត្រូវដោះស្រាយ។ ប្រសិនបើកំណត់ហេតុវត្តមានរបស់កុមារ បង្ហាញថាកុមារមានអវត្តមានលើសពី២៥%នៃថ្ងៃរៀន អ្នកត្រួតពិនិត្យនៅតាមសាលា នឹងផ្តល់ដំណឹងនេះ ដល់អ្នកត្រួតពិនិត្យ តាមសហគមន៍ផ្សេងទៀតដែលមានតួនាទីត្រូវចុះពិនិត្យសាកសួរដល់គ្រួសារ ដើម្បីចង់ដឹងពីមូលហេតុដែលកុមារខកខានមិនបានចូលរៀនច្រើនលើកពេក។សួរថាតើកុមារមានបញ្ហាជាមួយគ្រូ ឬថាតើគ្រួសារមានវិបត្តិណាមួយដែលបណ្តាលឱ្យ កុមារត្រឡប់មកធ្វើការរកប្រាក់ចំណូលជាបន្ទាន់វិញ។ ប្រសិនបើអាចធ្វើទៅបាន អ្នកត្រួតពិនិត្យតាមសហគមន៍នឹងជួយគ្រួសារកុមារក្នុងការដោះស្រាយបញ្ហានោះ។

## អ្វីដែលការអនុវត្តល្អនេះសម្រេចបាន និងភស្តុតាងចំពោះសមិទ្ធផលនេះ

នៅក្នុងការធ្វើសម្ភាសន៍ ជាមួយក្រុមផ្តល់ព័ត៌មានអំពីការ

អនុវត្តល្អ មន្ត្រី ដែលកំពុងធ្វើការលើបញ្ហាពលកម្មកុមារនៅថ្នាក់ក្រោមជាតិបានកំណត់ឃើញថា អ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ គឺជាមនុស្សសំខាន់បំផុតសម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។បណ្ដាអ្នកចូលរួមសិក្ខាសាលាថ្នាក់ខេត្ត និងថ្នាក់ជាតិដើម្បីពិនិត្យឡើងវិញពីការអនុវត្តល្អបានឯកភាពផងដែរថា ការត្រួតពិនិត្យពលកម្មកុមារនៅកម្រិតសហគមន៍ដោយប្រភេទផ្សេងៗ គ្នានៃអ្នកត្រួតពិនិត្យជាផ្លូវការ និងមិនផ្លូវការ គឺជាការអនុវត្តល្អមួយ។



នៅក្នុងការសិក្សាពីការបង្កើតបរិយាកាសគាំទ្រ/អំណោយផល[6] ដែលបានធ្វើឡើងនៅខេត្តកែប និងខេត្តកំពត អតីតពលករកុមារ និងឪពុកម្ដាយរបស់ពួកគេ មួយចំនួនបានដាក់ពិន្ទុទៅលើអ្នកត្រួតពិនិត្យនៅតាមសាលា និងតាមសហគមន៍ ថាជាមនុស្សសំខាន់បំផុតក្នុងការជួយដល់ពួកគេ។ នៅក្នុងចំណោមអ្នកត្រួតពិនិត្យពលកម្មកុមារ ជាផ្លូវការ អ្នកត្រួតពិនិត្យតាមសហគមន៍ត្រូវបានចំណាត់ថ្នាក់ ជាមនុស្សមានឥទ្ធិពលបំផុតក្នុងការដកហូតកុមារពីពលកម្ម ក្នុងខណៈដែលអ្នកត្រួតពិនិត្យនៅតាមសាលា និងមន្ត្រីអធិការកិច្ចការងារត្រូវបានផ្ដល់ចំណាត់ថ្នាក់សំខាន់ទីពីរ និងទីបី។ មន្ត្រីដទៃទៀតដែលដើរតួនាទីតិចតួច ប៉ុន្តែមាន តួនាទីដ៏សំខាន់ក្នុងការជួយកុមារឱ្យឈប់ធ្វើការពេញម៉ោង ឬពាក់កណ្ដាលពេល គឺមានទៅតាមកម្រិត ឥទ្ធិពលដូចជាមេដឹកនាំសហជីព និយោជក និងបណ្ដាអ្នកដឹកនាំបណ្ដាញសង្គមស៊ីវិលប្រឆាំងនឹងពលកម្មកុមារជាដើម។

## បញ្ហាប្រឈម/មេរៀនបទពិសោធន៍ក្នុងដំណើរការប្រតិបត្តិនៃការអនុវត្តល្អនេះ

### កត្តាដែលធ្វើឱ្យប្រសិទ្ធភាពការងារមានកំរិតរបស់មន្ត្រីត្រួតពិនិត្យនៅតាមកន្លែងការងារ

- មន្ត្រីអធិការកិច្ចការងារត្រូវបានអនុញ្ញាតឱ្យត្រួតពិនិត្យតែទៅលើសហគ្រាសក្នុងប្រព័ន្ធប៉ុណ្ណោះ ដែលមានចំនួនភាគតិច នៃបណ្ដាសហគ្រាសសរុបទាំងអស់។ មានចំនួនសហគ្រាសកម្ពុជាប្រហែល ៩៥% មិនបានចុះបញ្ជីជាផ្លូវការទេ ហើយមិនស្ថិតនៅក្នុងដែនអធិការកិច្ចការងារឡើយ។

- មន្ត្រីអធិការកិច្ចការងារ នៅតាមខេត្តនីមួយៗមានចំនួនតិចតួចប៉ុណ្ណោះ ហើយពួកគេមិនមានលទ្ធភាពធ្វើអធិការកិច្ចការងារលើសហគ្រាសដែលបានចុះបញ្ជីជាផ្លូវការទាំងនោះបានទាំងអស់ទេ។ ដូច្នេះ ដើម្បីជួយឱ្យការងាររបស់មន្ត្រីអធិការកិច្ចលើទីតាំងការងារកាន់តែមានប្រសិទ្ធភាពថែមទៀតនោះ គឺត្រូវឱ្យមានការជួលមន្ត្រីត្រួតពិនិត្យការងារ នៅទីតាំងការងារបន្ថែមទៀត ហើយពួកគេចាំបាច់ត្រូវមានអំណាចដើម្បីត្រួតពិនិត្យសហគ្រាសណាមួយ ដែលមានការសង្ស័យលើពលកម្មកុមារ ដោយមិនគ្រាន់តែត្រួតពិនិត្យ លើសហគ្រាសក្នុងប្រព័ន្ធប៉ុណ្ណោះទេ។

- នៅពេលមន្ត្រីអធិការកិច្ចការងារទៅធ្វើការនៅកន្លែងផ្សេងទៀត អ្នកជំនួសពួកគេចាំបាច់ត្រូវទទួលបានការបណ្ដុះបណ្ដាលពីបញ្ហាពលកម្មកុមារ ការលើកកម្ពស់ការយល់ដឹង និងការអនុវត្តជាដើម។

- មន្ត្រីអធិការកិច្ចការងារនិយាយថា ពួកគេត្រូវការឯកសារបោះពុម្ពដែលអាចទុកចិត្តបាន ដើម្បីលើកកម្ពស់ការយល់ដឹងដល់និយោជកទាំងឡាយទាក់ទិននឹងពលកម្ម

6 Ibid., ឧបសម្ព័ន្ធ៧

កុមារ។ ឯកសារទាំងនោះគួរពន្យល់ពីផលវិបាកជាអវិជ្ជមានរយៈពេលខ្លី និងរយៈពេលវែងនៃពលកម្មកុមារចំពោះកុមារ និងកម្ពុជាទាំងមូល ច្បាប់ និងបទប្បញ្ញត្តិនានាដែលទាក់ទងនឹងពលកម្មកុមារនិងអត្ថប្រយោជន៍នៃការទទួលបានការអប់រំនៅសាលារៀន។ មន្ត្រីអធិការកិច្ចការងារបានបញ្ជាក់បង្ហាញផងដែរថា ឯកសារបោះពុម្ពទាំងនោះស្តីពីបទប្បញ្ញត្តិនានា (ប្រកាស) ដែលហាមឃាត់ពលកម្មកុមារនៅក្នុងវិស័យជាក់លាក់ គឺមានតម្លៃ ជាពិសេសក្នុងការបញ្ចុះបញ្ចូលនិយោជកទាំងឡាយកុំឱ្យជួលកុមារ។

❖ មន្ត្រីអធិការកិច្ចការងារមានការលំបាកដើម្បីកំណត់រកកុមារ ដែលកំពុងធ្វើការក្នុងទីកន្លែងលាក់កំបាំងមួយចំនួនដូចជា ការងារតាមផ្ទះ មុខរបរបណ្តោះអាសន្នដូចជាការងារកសិកម្មតាមរដូវកាល ការងាររើសអេតចាយ ឬការដើរសុំទានជាដើម។ មន្ត្រីអធិការកិច្ចការងារអាចប្រឈមនឹងហានិភ័យផងដែរ ប្រសិនបើពួកគេចុះពិនិត្យសាកសួរដល់គេហដ្ឋានណាមួយ ដែលមានការសង្ស័យថាមានពលករកុមារ ពីព្រោះថាមានគេហដ្ឋានមួយចំនួនមានសត្វឆ្កែដ៏កាចសាហាវសម្រាប់ចាំយាម។

## កត្តាដែលធ្វើឱ្យប្រសិទ្ធភាពការងារមានកំរិតរបស់អ្នកត្រួតពិនិត្យពលកម្មកុមារនៅតាមសហគមន៍

❖ ការត្រួតពិនិត្យពលកម្មកុមារ អាចទាមទារពេលវេលាច្រើនសមត្ថភាព និងការទទួលខុសត្រូវរបស់អ្នកត្រួតពិនិត្យ។ ជាតួយ៉ាង អ្នកត្រួតពិនិត្យពលកម្មកុមារទទួលខុសត្រូវចំពោះ ការធ្វើសេចក្តីសម្រេចចិត្តទាក់ទិននឹងការដកហូត ការទប់ស្កាត់ ឬការគាំពារកុមារដែលកំពុងធ្វើការ ការប៉ាន់ប្រមាណ លើតម្រូវការសេដ្ឋកិច្ច សង្គម និងតម្រូវការ ការអប់រំ ការបញ្ជូនបន្តដល់អ្នកផ្តល់សេវាសង្គមនានា និងការផ្តល់ប្រឹក្សាយោបល់ និងដំបូន្មានដល់និយោជក ឪពុកម្តាយ និងកុមារ។ល។ ការងារត្រួតពិនិត្យនេះ គឺជាបន្ទុកបន្ថែមដល់ភារកិច្ចស្នូលរបស់មន្ត្រីត្រួតពិនិត្យតាមសហគមន៍ ដែលជាប្រធានក្រុមឃុំ ឬសមាជិកក្រុមប្រឹក្សាឃុំ។

❖ ការជានាភាពត្រឹមត្រូវលើការបញ្ចូល ទិន្នន័យប្រកបដោយគុណភាពទៅក្នុងប្រព័ន្ធបញ្ជីកត់ត្រាការត្រួតពិនិត្យ និងការវិភាគទិន្នន័យនោះ ដើម្បីកំណត់រកដោះស្រាយបញ្ហានានា គឺទាមទារឱ្យមានជំនាញបច្ចេកទេសច្បាស់លាស់ ដែលអ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ទាំងនោះអាចមិនមាន។

❖ មន្ត្រីពាក់ព័ន្ធ ក្នុងការត្រួតពិនិត្យពលកម្មកុមារមួយចំនួន ជឿជាក់ថាពួកគេគួរតែទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ការងារបន្ថែមដែលពួកគេធ្វើនៅពេលយប់ និងចុងសប្តាហ៍។ អ្នកត្រួតពិនិត្យពលកម្មកុមារមួយចំនួនទៀតនិយាយថា ដោយសារពួកគេត្រូវធ្វើដំណើរក្នុងរយៈចម្ងាយឆ្ងាយ ទៅកាន់ទីតាំងពលកម្មកុមារនានា ដូច្នេះប្រាក់ឧបត្ថម្ភប្រចាំខែរបស់ពួកគេសម្រាប់ថ្លៃប្រេងសាំងម៉ូតូ និងអាហារ គឺមិនគ្រប់គ្រាន់ទេ។



## ល័ក្ខខ័ណ្ឌគន្លឹះសំរាប់បន្តអនុវត្ត និងធ្វើឱ្យមាននិរន្តរភាពចំពោះការអនុវត្តល្អនេះ

❖ ការត្រួតពិនិត្យដោយហ្មត់ចត់លើកុមារ ដែលកំពុងទទួលផលប្រយោជន៍ គួរគប្បីធ្វើឡើងយ៉ាងហោចណាស់នៅរៀងរាល់បីខែម្តង ដើម្បីធានាថាកុមារ និងឪពុកម្តាយរបស់ពួកគេទទួលជំនួយឧបត្ថម្ភដូច ដែលបានសន្យាដល់ពួកគេ និងដើម្បីធានាថាកុមារ គឺបន្តស្ថិតក្នុងសាលា ឬវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈ និងមិនបានចាប់ផ្តើមធ្វើការសាជាថ្មីទៀតឡើយ។ ប្រសិនបើនៅពេលពិនិត្យផ្ទៀងផ្ទាត់លើកំណត់ហេតុវត្តមាន របស់កុមារអ្នកត្រួតពិនិត្យ នៅតាមសាលារកឃើញថាវត្តមានរបស់កុមារទាបជាង៧៥% អ្នកត្រួតពិនិត្យនៅតាមសាលាគប្បីផ្តល់ដំណឹងនេះ ដល់អ្នកត្រួតពិនិត្យតាមសហគមន៍ ដើម្បីចុះ



ពិនិត្យ សាកសួររកឱ្យឃើញពីមូលហេតុដែលកុមារមិនបានចូលរៀនសាលា ឬការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងអាចត្រូវធ្វើអ្វីបានដើម្បីដោះស្រាយបញ្ហានេះ។

❖ ការជ្រើសរើសដោយឥតព្រៀងទុកចំនួន ៥% នៃកំណត់ហេតុត្រួតពិនិត្យគប្បីផ្ទៀងផ្ទាត់ម្តងម្កាល តាមរយៈការចុះពិនិត្យសាកសួរដល់កុមារ និងគ្រួសាររបស់ពួកគេដើម្បីធ្វើឱ្យប្រាកដថាកំណត់ហេតុទាំងនោះមានភាពត្រឹមត្រូវ។

❖ គួរមានអ្នកជំនាញបច្ចេកទេស ដើម្បីជួយដោះស្រាយបញ្ហាដែលសមាជិកសហគមន៍មានជាមួយនឹងប្រព័ន្ធចុះបញ្ជីកំណត់ហេតុក្នុងម៉ាស៊ីនកុំព្យូទ័រ។

❖ ផ្តល់ប្រាក់កម្រៃប្រចាំខែ ដល់អ្នកត្រួតពិនិត្យនៅតាមសាលា និងសហគមន៍ដើម្បីទូទាត់ការងារបន្ថែមដែលពួកគេធ្វើការនៅពេលយប់ និងចុងសប្តាហ៍ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ឪពុកម្តាយ និងការចុះធ្វើការត្រួតពិនិត្យសាកសួរ ។

❖ រៀបចំកិច្ចប្រជុំទៀងទាត់រៀងរាល់ពីរខែម្តង ឬញឹកញាប់ជាងនេះ ដើម្បីអញ្ជើញអ្នកត្រួតពិនិត្យតាមសហគមន៍ទាំងផ្លូវការ និងមិនផ្លូវការឱ្យចូលរួម ដើម្បីពួកគេអាចចែករំលែកព័ត៌មាន និងជួយដោះស្រាយបញ្ហាគ្នាទៅវិញទៅមក ។

❖ រៀបចំឱ្យមានកិច្ចសន្យា ជាលាយល័ក្ខអក្សរមួយច្បាប់សម្រាប់ឪពុកម្តាយ និងពលករកុមារដោយបញ្ជាក់ពីអត្ថប្រយោជន៍នានាដែលកុមារ និងគ្រួសារនឹងទទួលបាន។ ទាំងឪពុកម្តាយ និងអ្នកត្រួតពិនិត្យ តាមសហគមន៍ គួរចុះហត្ថលេខា ឬផ្តិតស្នាមមេដៃនៅលើកិច្ចសន្យានេះ។

❖ គួរធានាឱ្យមានថវិកា ដើម្បីផ្តល់ការបណ្តុះបណ្តាលសម្រាប់អ្នកត្រួតពិនិត្យថ្មីៗ ដែលជំនួសអ្នកចាស់។



# ៣- ការធ្វើឱ្យប្រសើរឡើងនូវប្រាក់ចំណូលគ្រួសារ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីតាមរយៈក្រុមសន្សំ និងការបង្កើតប្រាក់ចំណូល



## សេចក្តីសង្ខេប

ការជួយឪពុកម្តាយកុមារ ដើម្បីកែលំអការរកប្រាក់ចំណូលឱ្យបានប្រសើរឡើង ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយថាជាផ្នែកមួយដ៏មានសារៈសំខាន់ ដើម្បីបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។ របាយការណ៍ការអនុវត្តល្អនេះ បង្ហាញថាក្រុមជួយខ្លួនឯង អាចជួយឪពុកម្តាយរបស់អតីតពលករកុមារឱ្យមានភាពប្រសើរឡើងក្នុងការរកប្រាក់ចំណូលហើយឈប់ពឹងផ្អែកលើកម្លាំងពលកម្មរបស់កូន។ក្រុមជួយខ្លួនឯងទាំងនេះអាចជួយដល់សមាជិកក្រុម ក្នុងការដាក់ប្រាក់សន្សំបង្កើនការប្រាក់លើប្រាក់សន្សំ កម្ចីខ្នាតតូចដើម្បីជាទុនបង្កើតមុខរបរខ្នាតតូច ការផ្តល់កម្ចីក្នុងគ្រាអាសន្នដោយមិនយកការប្រាក់ និងសំរាប់ជួយផ្គត់ផ្គង់ដល់ការបណ្តុះបណ្តាលអំពីការចាត់ចែងហិរញ្ញវត្ថុ ការបង្កើតនិងប្រតិបត្តិការមុខរបរខ្នាតតូច និងជំនាញបង្កើតប្រាក់ចំណូលនានាបន្ថែមទៀត។

## សាវតា

តាមការសិក្សានានានៅកម្ពុជា[7] បានបង្ហាញថា កុមារបោះបង់ការសិក្សាហើយចាប់ផ្តើមធ្វើការ ដោយសារតែហេតុផលមួយចំនួនគឺ៖ ឪពុកម្តាយ និងកុមារមិនបានយល់ដឹងអំពីច្បាប់ដែលហាមឃាត់កុមារមិនឱ្យធ្វើការងារ និងតម្រូវឱ្យពួកគេចូលរៀនរហូតដល់អាយុយ៉ាងតិច១៥ឆ្នាំ ឪពុកម្តាយមិនមានលទ្ធភាព

---

7 ILO IPEC. ២០០៨ ការសិក្សាតាមវិស័យអំពីកុមារក្នុងវិស័យនេសាទ ផលិតកម្មអំបិល លីសែង រើសសំរាម/អេតចាយ បំរើតាមហាង សុំទាន និងបំរើតាមផ្ទះនៅខេត្តកំពត កម្ពុជា (ភ្នំពេញ ILO); ILO IPEC ២០០៨។ ការសិក្សាតាមវិស័យអំពីកុមារក្នុងវិស័យនេសាទផលិតកម្មអំបិល បំរើតាមហាងសិប្បកម្មបំបែកថ្ម និងបំរើតាមផ្ទះនៅកែប។

ដើម្បីចំណាយលើការរៀនសូត្ររបស់កូន រួមមាន (សំលៀកបំពាក់ជាឯកសណ្ឋានសិស្ស ស្បែកជើង សៀវភៅ សម្ភារៈសិក្សា និងការបង់ថ្លៃសិក្សាទាំងផ្លូវការ និងក្រៅផ្លូវការផ្សេងៗទៀត) ជាពិសេសទៅទៀត ប្រសិនបើពួកគេមានកូនពីរបីនាក់កំពុងរៀន ហើយឪពុកម្តាយដែលមានការអប់រំតិចតួចតែងគិតថាការរៀនត្រឹម បឋមសិក្សា ឬក៏តិចទាបជាងនេះគឺគ្រប់គ្រាន់ហើយ ជាពិសេសកុមារីដែលរំពឹងថាត្រូវរៀបការតាំងពីក្មេង។ទោះជាយ៉ាងណាឪពុកម្តាយរបស់ពលករកុមារ និងអ្នកដែលធ្វើការងារដើម្បីលុបបំបាត់ពលកម្មកុមារនិយាយថាមូលហេតុសំខាន់បំផុត នៃពលកម្មកុមារ គឺបណ្តាលមកពីភាពក្រីក្រ[8]។ ឪពុកម្តាយមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ទេ ប្រសិនបើគ្មានការជួយរកចំណូល បន្ថែមពីកូនៗរបស់ពួកគេទេនោះ។

ប្រជាពលរដ្ឋកម្ពុជារស់នៅតាមតំបន់ជនបទ ៩០% ក្រីក្រដែលភាគច្រើនជាកសិករ ពឹងផ្អែកជាសំខាន់លើផ្ទៃដីបង្កបង្កើតផលទំហំមួយហិកតា ឬតិចជាងនេះ។ ដោយសារខ្វះប្រព័ន្ធស្រោចស្រពកសិករបង្កបង្កើតផល(ធ្វើស្រែ)បានតែម្តងក្នុង១ឆ្នាំ ហើយប្រឈមមុខខ្ពស់ជាមួយនឹងគ្រោះធម្មជាតិផ្សេងៗ ដូចជារាំងស្ងួត និងគ្រោះទឹកជំនន់ ។

នៅពេលដែលធ្វើស្រែចំការបរាជ័យ កសិករត្រូវរកលុយដើម្បីទិញស្បៀងអាហារសំរាប់ផ្គត់ផ្គង់គ្រួសារ ហើយប្រសិនបើឪពុកម្តាយមិនអាចរកប្រាក់ចំណូលបានគ្រប់គ្រាន់ទេ ពួកគាត់ក៏ប្រើកូនៗរបស់ពួកគាត់ឱ្យទៅធ្វើការរកកំរៃផងដែរ។ ការងារទាំងនោះជារឿយៗឋិតនៅក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារព្រោះថាការងារប្រភេទនេះប្រជាពលរដ្ឋក្រីក្រនិងកូនៗរបស់ពួកគេអាចងាយស្រួលស្វែងរកបានធ្វើ។ ឧទាហរណ៍មានដូចជា ការងារលើសែង អូសរទេះដឹកឥវ៉ាន់ឆ្លងដែន រើសអេតចាយ ប្រមូលផលអំបិល ចៀរជ័រកៅស៊ូ ផលិតឥដ្ឋ នេសាទត្រី ធ្វើត្រីប្រហុកត្រីងៀត ស៊ីឈ្នួលបំរើតាមផ្ទះ លក់ផ្កា លក់កាសែតតាមវត្តសាល ភោជនីយដ្ឋាន និងតាមភ្លើងស្តុបនៃដងផ្លូវនានា។

វត្តមានពលកម្មកុមារមានកំរិតខ្ពស់ ជាពិសេសក្នុងគ្រួសារដែលគ្មានដីធ្លី គ្រួសារចំណាកស្រុកដែលបានលក់ដីសំរាប់ចំណាយលើការព្យាបាលជំងឺជាបន្ទាន់ ឬដើម្បីសងបំណុលគេ។ ប្រសិនបើគ្រួសារមានការផ្លាស់ទីញឹកញាប់ ជាទូទៅធ្វើឱ្យមានការរំខាន ដល់ការរៀនសូត្ររបស់កុមារដែលនាំឱ្យពួកគេបោះបង់សាលា ហើយចាប់ផ្តើមធ្វើការវិញ។

ដោយសារតែប្រជាជនក្រីក្រ ជាពិសេសអ្នកដែលងាយរងគ្រោះចំពោះវិបត្តិសេដ្ឋកិច្ច បានរុញច្រានកូនៗ របស់ពួកគេឱ្យធ្វើការងារដូច្នេះការជួយឪពុកម្តាយរបស់ពួកគេឱ្យមានលទ្ធភាពរកប្រាក់ចំណូលបានកាន់តែប្រសើរ គឺជាការចាំបាច់មួយក្នុងការបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

## វិធីដែលការអនុវត្តល្អនេះប្រតិបត្តិ

របាយការណ៍នេះ នឹងបង្ហាញថាឪពុកម្តាយរបស់អតីតពលករកុមារ ក៏ដូចជាអ្នកធ្វើការងារដើម្បីបញ្ចប់ពលកម្មកុមារនៅក្នុងសហគមន៍ភាគច្រើនយល់ថា ក្រុមជួយខ្លួនឯងគឺជាការអនុវត្តល្អមួយ។ សកម្មភាពរបស់ក្រុមជួយខ្លួនឯងមានលក្ខណៈខុសៗគ្នា ប៉ុន្តែជាទូទៅគឺមានការដាក់ប្រាក់សន្សំ និងកម្ចីតិចតួច។ សមាជិកដាក់ប្រាក់សន្សំជាមួយក្រុម ជាមធ្យមពី១-២ដុល្លារអាមេរិកក្នុង១ខែ ហើយជាទូទៅពួកគេត្រូវបង់ប្រចាំសប្តាហ៍។ នៅពេលដែលចំនួនប្រាក់សន្សំកើនច្រើនគួរសម សមាជិកអាចខ្ចីក្នុងចំនួនតិចតួចពី ៥-២០ដុល្លារ ហើយពួកគេត្រូវសងមកវិញ ជាមួយនឹងអត្រាការប្រាក់ប្រហែល ៣%ក្នុង១ខែ។ អត្រាការប្រាក់នេះគ្រាន់បើជាងចងការប្រាក់ឯកជន ដែលមានអត្រាការប្រាក់ហួតដល់១០%ក្នុង១ខែ។

សមាជិកក្រុមសន្សំក៏ទទួលបានការប្រាក់ ពីការដាក់ប្រាក់សន្សំរបស់ខ្លួន។ នៅដំណាច់ឆ្នាំនីមួយៗ ចំណូលពីការប្រាក់ដែលអ្នកខ្ចីបានបង់ ត្រូវបានបែងចែកដល់សមាជិកក្រុមទៅតាមចំនួនសាច់ប្រាក់ដែលពួកគេបានដាក់សន្សំ។ ក្រុមជួយខ្លួនឯងក៏បានផ្តល់កម្ចីមិនយកការប្រាក់ ដល់គ្រួសារដែលជួបគ្រោះអាសន្ន ហើយក្រុមខ្លះទៀត ក៏មានការផ្តល់ការបណ្តុះបណ្តាលអំពីការចាត់ចែងហិរញ្ញវត្ថុ ជំនាញបង្កើតប្រាក់ចំណូល ការបង្កើត និងប្រតិបត្តិការមុខរបរខ្នាតតូចផង

8 នៅក្នុងក្រុមជាក់លាក់ទាំងឡាយ ដែលបានធ្វើសំរាប់ការសិក្សានេះ នៅខែកក្កដា ២០១២ ដើម្បីពិភាក្សាគ្នាអំពីការអនុវត្តល្អទាំងឡាយក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ។ អ្នកចូលរួមបានសង្កត់ធ្ងន់អំពីតម្រូវការក្នុងការជួយឪពុកម្តាយពលករកុមារដើម្បីកែលម្អការរកប្រាក់ចំណូល។ ក្រុមជួយខ្លួនឯងគឺត្រូវបានគាំទ្រយ៉ាងខ្លាំងផងដែរពីសំណាក់អ្នកចូលរួមនៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ និងថ្នាក់ខេត្តស្តីពីការអនុវត្តល្អដែលប្រារព្ធធ្វើឡើងក្នុងខែកញ្ញា ឆ្នាំ២០១២។

ដែរ។ មិនតែប៉ុណ្ណោះ សមាជិកក្រុមក៏បានទទួលនូវការបង្កើនជំនាញ និងភាពជឿជាក់តាមរយៈការដឹកនាំក្រុម ដែលធានាថាសមាជិកក្រុមទាំងអស់បានបង់ប្រាក់សន្សំ និងសងប្រាក់កម្ចីរបស់ពួកគេមកវិញជាទៀងទាត់ ឬក្នុងតួនាទីជាអ្នកកត់បញ្ជីរបស់ក្រុមដែលកត់ត្រាចំនួនប្រាក់សន្សំ ប្រាក់កម្ចី និងការសងវិញរបស់សមាជិក។ មានលក្ខខណ្ឌមួយនៃសមាជិកភាពរបស់ក្រុមជួយខ្លួនឯង គឺថាឪពុកម្ដាយរបស់អតីតពលករកុមារត្រូវតែប្ដេជ្ញាចិត្តធានាថា កូនរបស់ខ្លួនបន្តការអប់រំ ឬចូលរួមវគ្គបណ្ដុះបណ្ដាល ជំនាញវិជ្ជាជីវៈ ហើយមិនវិលត្រឡប់ទៅធ្វើការវិញទេ ទោះបីជាការងារពាក់កណ្ដាលពេលក៏ដោយ។

## ប្រវត្តិពលកម្មកុមារពាក់ព័ន្ធនឹងក្រុមជួយខ្លួនឯងនៅកម្ពុជា

អង្គការ ILO-IPEC នៅកម្ពុជាបាននិងកំពុងជំរុញឱ្យមានការបង្កើតក្រុមជួយខ្លួនឯងតាំងពីឆ្នាំ២០០១ នៅពេលដែលក្រុមជួយខ្លួនឯង ត្រូវបានបង្កើតឡើងសំរាប់ឪពុកម្ដាយរបស់កុមារដែលត្រូវបានដកហូតចេញពីពលកម្ម ក្នុងវិស័យនេសាទ ចំការកៅស៊ូ និងផលិតកម្មអំបិល[9]។ ដោយផ្អែកលើលទ្ធផលល្អនៅក្នុងឧស្សាហកម្មទាំងនេះ រវាងពីឆ្នាំ ២០០៤ និង២០០៨ អង្គការ ILO-IPEC បានសហការជាមួយគម្រោងលើកកម្ពស់ការអភិវឌ្ឍមុខរបររបស់ស្ត្រី និងសមភាពយេនឌ័រនៃអង្គការ ILO-WEDGE ដើម្បីពង្រីកការបង្កើតក្រុមជួយខ្លួនឯង នៅក្នុងរាជធានីភ្នំពេញ និងខេត្តចំនួន៦គឺ ខេត្តកែប កំពត បន្ទាយមានជ័យ ព្រះសីហនុ កំពង់ចាម និងសៀមរាប។



គម្រោងលើកកម្ពស់ ការអភិវឌ្ឍមុខរបររបស់ស្ត្រី និងសមភាពយេនឌ័រនៃអង្គការ ILO បានគោរពតាមតាមមុខព្រួញបីផ្អែកលើអភិក្រមអភិវឌ្ឍន៍ និងសិទ្ធិជាមូលដ្ឋាន ក្នុងគោលបំណងដករបាំងវប្បធម៌សង្គម ច្បាប់ និងនយោបាយដែលប្រឈមសំរាប់សហគ្រិនភាពរបស់ស្ត្រី និងដើម្បីតស៊ូមតិឱ្យមានសមភាពយេនឌ័រនៅក្នុងសហគ្រាសឯកជន។

## ការអភិវឌ្ឍសមត្ថភាពរបស់អ្នកសម្របសម្រួលក្រុមជួយខ្លួនឯង

ដើម្បីពង្រីកការប្រើប្រាស់នៃក្រុមជួយខ្លួនឯង គម្រោងលើកកម្ពស់ ការអភិវឌ្ឍមុខរបររបស់ស្ត្រី និងសមភាពយេនឌ័រ និងគម្រោងកម្មវិធី ILO IPEC បានផ្ដល់វគ្គបណ្ដុះបណ្ដាលជាបីកំរិត។ នៅកំរិតថ្នាក់ជាតិ គឺបានបណ្ដុះបណ្ដាលគ្រូ បង្គោលដែលគ្រូបង្គោលទាំងនោះ នឹងធ្វើការបណ្ដុះបណ្ដាល បន្តដល់ដៃគូអនុវត្តគម្រោងនៅថ្នាក់ខេត្តហើយបន្ទាប់មក ពួកគាត់ នឹងបណ្ដុះបណ្ដាលបន្តដល់អ្នកត្រួតពិនិត្យពលកម្មកុមារពលកម្មកុមារ តាមសហគមន៍ អំពីរបៀបប្រតិបត្តិការក្រុមជួយខ្លួនឯង។ ជាមួយនឹងការបណ្ដុះបណ្ដាលទាំងនេះ គម្រោងកម្មវិធី ILO WEDGE ក៏បានផ្ដល់សៀវភៅណែនាំមួយក្បាលស្ដីអំពីការចាត់ចែងហិរញ្ញវត្ថុសហគ្រាសខ្នាតតូចដល់សមាជិកក្រុមជួយខ្លួនឯងផងដែរ។

នៅពេលដែលក្រុមជួយខ្លួនឯងត្រូវបានបង្កើតឡើង និងមានដំណើរការហើយ អ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍បានបន្តជួបប្រជុំជាមួយក្រុម ដើម្បីធានាថាវាមានដំណើរការល្អ និងដើម្បីសម្របសម្រួលដោះស្រាយទំនាស់ប្រសិនបើអាចកើតមាន និងក៏ដូចជា សម្របសម្រួលសមាជិកក្រុមឱ្យបានចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញ បង្កើតប្រាក់ចំណូលទាំងឡាយ ដែលផ្ដល់ដោយរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា។ ឧទាហរណ៍ដូចជា: វគ្គជំនាញចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ចិញ្ចឹមត្រី បណ្ដុះផ្សិត និងជំនាញគ្រប់គ្រងមុខរបរ/សហគ្រាសខ្នាតតូចជាដើម។

9 ILO-IPEC. 2005. បទពិសោធន៍ និងមេរៀនពីការត្រួតពិនិត្យពលកម្មកុមារក្នុងវិស័យចំការកៅស៊ូ ស្រែអំបិលនិងនេសាទនៅកម្ពុជា (ភ្នំពេញ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង ILO)។ អាចរកបាននៅ: www.ilo.org/ipecinfo/product/download.do?type=document&id=2999.

# អ្វីដែលការអនុវត្តល្អនេះ សម្រេចបានជោគជ័យ និងភស្តុតាងអំពីលទ្ធផលទាំងនោះ

## ភស្តុតាងនៃភាពជោគជ័យពីភាពជាដៃគូ រវាងគម្រោងកម្មវិធី ILO-IPEC & ILO WEDGE

ក្នុងរយៈពេលពីឆ្នាំ ២០០៤ ដល់២០០៨ មានក្រុមជួយខ្លួនឯងជាង១៦០ក្រុម ត្រូវបានបង្កើតដោយគម្រោងកម្មវិធី ILO-IPEC ក្នុងភាពជាដៃគូជាមួយគម្រោងកម្មវិធី ILO WEDGE។ ក្រុមគោលដៅសំរាប់ក្រុមជួយខ្លួនឯងនេះ គឺជាឪពុកម្តាយរបស់ អតីតពលករកុមារ ក្នុងវិស័យនេសាទ ផលិតកម្មអំបិល ចំការកៅស៊ូ លីសែង និងការងារបំរើតាមផ្ទះ ក្នុងរាជធានីភ្នំពេញ និងខេត្តទាំង៦ដូចមានរៀបរាប់ខាងលើ។



ក្នុងរបាយការណ៍មួយ ដែលសរសេរក្នុងឆ្នាំ២០១០ ដោយអង្គការ ILO-IPEC[10] អ្នកសរសេររបាយការណ៍បានកត់សំគាល់ថាក្រុមជួយខ្លួនឯងទាំងឡាយ ដែលបានបង្កើតឡើងដោយគម្រោងកម្មវិធី ILO WEDGE នៅតែអាចបន្តដំណើរការរបស់ខ្លួនអស់រយៈពេលបីឆ្នាំ ក្រោយពីការបញ្ចប់ការគាំទ្រពីគម្រោងកម្មវិធី ILO WEDGE ហើយសមាជិកខ្លះនៃក្រុមជួយខ្លួនឯងបានរីកចំរើនជាមួយនឹងចំនួនប្រាក់ ដែលបានសន្សំការផ្តល់កម្ចីដោយក្រុម និងការប្រាក់។

ស្រ្តីជាសមាជិកក្រុមជួយខ្លួនឯង ក៏បានរាយការណ៍ផងដែរថាលទ្ធភាពសន្សំប្រាក់បានជួយជ្រោមជ្រែង និងបង្កើនភាពជឿជាក់របស់ពួកគេ និងជួយពួកគេអោយដើរតួនាទីកាន់តែស៊ីជំរៅក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងគ្រួសារ។ រឿងដែលសំខាន់បំផុតនោះ គឺកុមារដែលស្ថិតក្នុងគ្រួសារសមាជិកក្រុមជួយខ្លួនឯង បានបន្តការសិក្សារបស់ពួកគេ ឬការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយមិនវិលត្រឡប់ទៅធ្វើការវិញទេ ទោះជាការងារពេញម៉ោង ឬការងារពាក់កណ្តាលពេលក៏ដោយ។

របាយការណ៍គម្រោងកម្មវិធី ILO-IPEC ២០១០ បានកត់សំគាល់ថា សមាជិកក្រុមជួយខ្លួនឯង គឺភាគច្រើនជាមនុស្សសកម្មនៅក្នុងភូមិ ក្នុងការជួយលើកកម្ពស់ការយល់ដឹងអំពីផលវិបាកអវិជ្ជមាននៃពលកម្មកុមារ និងជាអ្នករាយការណ៍ពីករណីពលកម្មកុមារទៅ អាជ្ញាធរមានសមត្ថកិច្ច។ សមាជិកក្រុមជួយខ្លួនឯងក៏បានធ្វើជាគំរូល្អមួយក្នុងសហគមន៍របស់ពួកគេដោយហេតុថា ទោះបីជាក្រីក្រក៏ដោយ ក៏ពួកគេបានជួយឱ្យកូនៗរបស់ពួកគេទៅរៀន ហើយមិនឱ្យពួកគេវិលត្រឡប់ទៅធ្វើការទៀតទេ។ របាយការណ៍នេះក៏បានចង្អុលបង្ហាញថា ដោយសារតែកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមជួយខ្លួនឯងយ៉ាងមុតមាំ ភូមិមួយចំនួន គឺគ្មានពលកម្មកុមារទាំងស្រុង ហើយក្រុមជួយខ្លួនឯងខ្លះទៀតបានទទួលប្រាក់កម្ចីពីស្ថាប័នមីក្រូហិរញ្ញវត្ថុ ផ្តល់ទៅដល់សមាជិកក្រុមបន្ថែមទៀតផង ។

## ភស្តុតាងនៃភាពជោគជ័យពី ការសិក្សាស្រាវជ្រាវរបស់អ្នកសរសេររបាយការណ៍

ការពិភាក្សាជាមួយក្រុមគោលដៅ ដោយអ្នកសិក្សាស្រាវជ្រាវនៅខេត្តកែប កំពត បន្ទាយមានជ័យ រាជធានីភ្នំពេញ និងខេត្តសៀមរាបដើម្បីកំណត់ការអនុវត្តល្អនានា និងមេរៀនជាបទពិសោធន៍ ដែលអ្នកធ្វើសំភាសន៍ជាញឹកញាប់បានពោលថាក្រុមជួយខ្លួនឯង គឺជាការអនុវត្តល្អមួយ ហើយបាននិយាយទៀតថា ដោយសារតែភាពជោគជ័យរបស់ពួកគេធ្វើឱ្យសហគមន៍ផ្សេងៗទៀតមានបំណងចង់ចូលរួមជាមួយក្រុមជួយខ្លួនឯងដែរ។

អ្នកចូលរួមក្នុងការពិគ្រោះយោបល់ថ្នាក់ខេត្ត និងថ្នាក់ជាតិ ដែលពិនិត្យមើលលទ្ធផល នៃការសិក្សាស្រាវជ្រាវស្តីពីការអនុវត្តល្អ និងមេរៀនជាបទពិសោធន៍ ក៏បាននិយាយពេញ

10 ILO-IPEC. ២០១០. ការអនុវត្តល្អពីកម្ពុជា ការបញ្ចប់ពលកម្មកុមារតាម រយៈការកាត់បន្ថយភាពក្រីក្រគ្រួសារ។ Fact Sheet (Phnom Penh, ILO).

ចិត្តខ្លាំងចំពោះក្រុមជួយខ្លួនឯង ហើយសង្កត់ធ្ងន់នូវតួនាទីរបស់ក្រុមក្នុងការជួយ ដល់សមាជិកអំពីការអភិវឌ្ឍចំណេះដឹងការចាត់ចែងហិរញ្ញវត្ថុ ជោគជ័យនៃការបើកមុខរបរខ្នាតតូច និងការលើកកម្ពស់ការយល់ដឹងទូទៅ អំពីផលវិបាកអវិជ្ជមាននៃពលកម្មកុមារ។

### ភស្តុតាងនៃភាពជោគជ័យ ពីការសិក្សាលើការបង្កើតបរិយាកាសគាំទ្រ/អំណោយផលរបស់អង្គការ ILO-IPEC

ការសិក្សាលើការបង្កើតបរិយាកាស គាំទ្រ/អំណោយផល[11] ក្រុមពិភាក្សាដែលជាឪពុកម្ដាយក្នុងភូមិសំរោង និងភូមិស្រែក្នុងខេត្តកំពត បានរៀបរាប់អំពីភាពក្រីក្រ ដែលជាមូលហេតុចំបងដែលពីមុនមកពួកគាត់ បាននាំកូនៗរបស់ពួកគាត់មកធ្វើការជាមួយពួកគេក្នុងស្រែអំបិល។ ទោះជាយ៉ាងណាចាប់តាំងពីមានការបង្កើតសកម្មភាពរកប្រាក់ចំណូល តាមរយៈក្រុមជួយខ្លួនឯងមក សមាជិកក្រុមបាននិយាយថា ពួកគេមានលទ្ធភាពអាចរកប្រាក់សមល្មម ដើម្បីផ្គត់ផ្គង់គ្រួសារដោយមិនចាំបាច់មាន ការរកចំណូលបន្ថែមពីកូនៗរបស់ពួកគេទៀតទេ។ សមាជិកក្រុមជួយខ្លួនឯងក៏បាននិយាយផងដែរថា ពួកគេតែងតែចូលរួមនិងផ្ដល់គំនិតយោបល់ បទពិសោធន៍ស្ដីពីពលកម្មកុមារ នៅពេលដែលប្រធានភូមិហៅប្រជុំដើម្បីពង្រឹងការយល់ដឹងម្ដងៗ។

នៅភូមិទួលស្រង៉ាំ ក្នុងខេត្តកែប ក្រុមគោលដៅក៏បាននិយាយជាវិជ្ជមានផងដែរអំពីក្រុមជួយខ្លួនឯងរបស់ពួកគេ ដែលជួយឱ្យសមាជិកក្រុមមានលទ្ធភាពបង្កើតមុខរបរខ្នាតតូចក្នុងការបង្កើនប្រាក់ចំណូលគ្រួសារ។ ផលប្រយោជន៍ផ្សេងៗទៀតដែលបានរាយការណ៍ដោយសមាជិកក្រុមរួមមាន ៖

- អាចខ្ចីលុយក្នុងអត្រាការប្រាក់សមរម្យ ដើម្បីទិញកង់ឱ្យកូនស្រីទៅរៀននៅអនុវិទ្យាល័យ ដែលនៅឆ្ងាយលំបាកធ្វើដំណើរដោយថ្មើជើង។
- អាចខ្ចីលុយលឿនដោយមានអត្រាការប្រាក់ សមរម្យដើម្បីបំពេញតំរូវការជាមូលដ្ឋានក្នុងការទិញ អាហារ សំលៀកបំពាក់ និងសម្ភារៈសិក្សា។

11 ILO-IPEC. 2013. ការសិក្សាពីបរិយាកាសគាំទ្រ/អំណោយផលដើម្បីកាត់បន្ថយពលកម្មកុមារ,.. (2013), op cit.

- បញ្ចុះបញ្ចូលឪពុកម្ដាយកុមារ ដទៃទៀតក្នុងសហគមន៍របស់ពួកគេ កុំឱ្យបញ្ជូនកូនទៅធ្វើការ។

## បញ្ហាប្រឈម/មេរៀនបទពិសោធន៍ ក្នុងការប្រតិបត្តិនៃការអនុវត្តល្អនេះ

- ក្រុមជួយខ្លួនឯង ដែលកំពុងដំណើរការនៅខេត្តកែប និងកំពតដែលគាំទ្រដោយគម្រោងកម្មវិធីរបស់អង្គការ ILO-IPEC បានរាយការណ៍ថា ប្រសិនបើអ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍មិនអាចបន្តសម្របសម្រួលក្រុមតទៅទៀតបាន នោះក្រុមទំនងជាឈប់ដំណើរការដែរ។ ដើម្បីឱ្យមាននិរន្តរភាពរយៈពេលវែង ក្រុមជួយខ្លួនឯងគួរប្រឹងប្រែង ធ្វើទំនាក់ទំនងរវាងក្រុមជាមួយអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុឬសមាគមសាជីវកម្ម ដែលអាចជួយបន្តគាំទ្រក្រុមបាន។
- ការចុះឈ្មោះឪពុកម្ដាយ នៃគ្រួសារចំណាកស្រុកឱ្យចូលជាសមាជិកក្រុមសន្សំ គឺជាការលំបាកដោយសារតែគ្រួសារទាំងនោះ មិនមានឫសគល់រឹងមាំនៅក្នុងសហគមន៍របស់ពួកគេ ឬមិនសូវមានទំនុកចិត្តគ្នាទៅវិញទៅមកខ្លាំង ជាហេតុធ្វើឱ្យពួកគេមានការស្ទាក់ស្ទើរក្នុងការដាក់ប្រាក់សន្សំ តាមរយៈក្រុមសន្សំ ឬក៏ធានាគ្នាក្នុងការផ្ដល់ប្រាក់កម្ចី។ ដំណោះស្រាយមួយសំរាប់បញ្ហានេះ គឺគួរតែមានអ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ ឬមេភូមិជាអ្នកថែរក្សា និងចាត់ចែងមូលនិធិសំរាប់សមាជិកក្រុម។

## លក្ខខណ្ឌគន្លឹះសំរាប់ប្រតិបត្តិតាមដោយជោគជ័យ និងនិរន្តរភាពនៃការអនុវត្តល្អនេះ

- បន្ថែមពីលើការដាក់ប្រាក់សន្សំ និងប្រើប្រាស់ប្រាក់កម្ចី ក្រុមជួយខ្លួនឯងគួរផ្ដល់ការបណ្ដុះបណ្ដាលដល់សមាជិកក្រុម អំពីការចាត់ចែងហិរញ្ញវត្ថុ ការគ្រប់គ្រងមុខរបរ/សហគ្រាសខ្នាតតូច និងវិធីសាស្ត្រដាក់ស្ដែងក្នុងការបង្កើតប្រាក់ចំណូល និងការជួយបង្កើត និងសម្របសម្រួលទីផ្សារសម្រាប់ផលិតផលនិងសេវាកម្មរបស់ពួកគាត់។

- ជ្រើសរើសអ្នកសម្របសម្រួលមានសមត្ថភាពម្នាក់និង ផ្តល់ការបណ្តុះបណ្តាល ដើម្បីអភិវឌ្ឍន៍សមត្ថភាព ជំនាញរបស់អ្នកសម្របសម្រួល ដើម្បីឱ្យគាត់អាចផ្តល់ ការបណ្តុះបណ្តាល អំពីការចាត់ចែងហិរញ្ញវត្ថុ និងការ អភិវឌ្ឍសហគ្រាសខ្នាតតូច និងទីផ្សារ។

- ទោះបីជាយ៉ាងណាសមាជិកក្រុមសន្សំត្រូវផ្តល់អាទិភាព ដល់ឪពុកម្តាយរបស់កុមារដែលត្រូវបានដកហូតចេញ ពីពលកម្ម។ អ្នកពាក់ព័ន្ធដែលបានចូលរួមក្នុងសិក្ខា សាលាបានផ្តល់យោបល់ ឱ្យអ្នកក្រៅពីក្រុមគោលដៅ បានចូលរួមផងដើម្បីអាចជួយបង្កើនប្រាក់សន្សំរបស់ ក្រុម។ឧទាហរណ៍ករណីនៅឧស្សាហកម្មផលិតអំបិល សមាជិកក្រុមជួយខ្លួនឯង បានបញ្ចូលនិយោជកស្រែ អំបិល និងសមាជិកផ្សេងៗទៀតរបស់សហគមន៍ និង ឪពុកម្តាយរបស់អតីតពលករកុមារ នៅក្នុងក្រុមជួយ ខ្លួនឯង។

- ដោយសារតែសមាជិកក្រុមជួយខ្លួនឯង អាចផ្តល់ សំលេងដ៏មានឥទ្ធិពលក្នុងការលើកកម្ពស់ ការយល់ ដឹងអំពីផលវិបាកអវិជ្ជមានទាំងឡាយនៃពលកម្មកុមារ សមាជិកក្រុមទាំងឡាយ គួរតែត្រូវបានផ្តល់ព័ត៌មាន ច្បាស់លាស់អំពីផលប៉ះពាល់ជាអវិជ្ជមាន នៃពលកម្ម កុមារ ច្បាប់និងបទប្បញ្ញត្តិផ្សេងៗ ស្តីពីពលកម្មកុមារ ផលប្រយោជន៍នៃការសិក្សា និងលទ្ធភាពជួយគាំទ្រនៅ ក្នុងសហគមន៍ ទៅដល់គ្រួសារដែលក្រីក្របំផុតដើម្បី ដកហូតកូនរបស់ពួកគេចេញពីពលកម្មកុមារនិងបញ្ជូន ពួកគេទៅសាលារៀន ឬបណ្តុះបណ្តាល វិជ្ជាជីវៈ ផ្សេងៗ។

- ការសម្របសម្រួលក្រុមជួយខ្លួនឯងទាំងនោះ គួរតែ រៀបចំផ្តល់ការគាំទ្រយ៉ាងហោចឱ្យបានមួយឆ្នាំ ដើម្បី ជួយពង្រឹងសមត្ថភាពក្រុមជួយខ្លួនឯង។

- សំរាប់ការចាប់ផ្តើមក្រុមសន្សំដំបូង គួរតែមានការគាំទ្រ ជាមូលនិធិហិរញ្ញប្រទានចំនួន ១០០ដុល្លារ ដើម្បីកុំឱ្យ ក្រុមរង់ចាំរហូតដល់ ពីរ-បីខែ ទម្រាំតែក្រុមអាចសន្សំ លុយបានគ្រប់គ្រាន់សម្រាប់ការផ្តល់ប្រាក់កម្ចីបាន ។ មូលនិធិគាំទ្រដំបូងនេះ អាចនឹងផ្តល់ឱ្យពីមូលនិធិក្រុម ប្រឹក្សាឃុំសង្កាត់ឬពីអង្គការក្រៅរដ្ឋាភិបាលណាមួយ។

- សម្របសម្រួលការផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា រវាងក្រុម ជួយខ្លួនឯងដើម្បី ឱ្យពួកគេរៀនសូត្រដកស្រង់នូវ បទពិសោធន៍ពីគ្នាទៅវិញទៅមក។

- អភិវឌ្ឍន៍សមត្ថភាពអ្នកសម្របសម្រួលក្រុមជួយខ្លួនឯង ដើម្បីវាយតម្លៃក្រុម ស្របទៅតាមសូចនាករគន្លឹះមួយ ចំនួននៃនិរន្តរភាពសង្គម។ ការសម្រេចចិត្តជាតំណាង ចក្ខុវិស័យ និងទិសដៅរួមតែមួយ ការចាត់តាំង និង ការជំនួសអ្នកដឹកនាំ សមភាពយេនឌ័រ នៅក្នុងតួនាទី ការទទួលខុសត្រូវ ការគ្រប់គ្រង និងសកម្មភាពនានា របស់ក្រុមគុណភាពទំនាក់ទំនង និងការសម្របសម្រួល ជាមួយអង្គការមិនមែនរដ្ឋាភិបាល ការពឹងពាក់/ ឯករាជ្យភាព ផុតពីការសម្របសម្រួលជាមួយអង្គការ មិនមែនរដ្ឋាភិបាល គុណភាពក្នុងការទំនាក់ទំនង និងចងបណ្តាញខាងក្រៅ និងសមត្ថភាពក្នុងការ កៀរគរធនធាន។

- ដើម្បីឱ្យមាននិរន្តរភាព ក្រុមជួយខ្លួនឯងត្រូវផ្សារភ្ជាប់ជា មួយនឹងអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នមីក្រូហិរញ្ញវត្ថុ ឬជាមួយសមាគមសាជីវកម្មជាតិណាមួយ ដែលមិន ត្រឹមតែអាចជួយសម្របសម្រួលក្រុម ឱ្យមានដំណើរ ការជាប្រចាំទេ ពោលគឺអាចជួយក្រុមឱ្យទទួលបាន ការបណ្តុះបណ្តាលជំនាញ ក្នុងការបង្កើតប្រាក់ចំណូល និងរកទីផ្សារសម្រាប់ផលិតផល និងសេវាកម្មនានាដល់ ក្រុមថែមទៀតផង។

- បង្កើតគណៈកម្មការប្រឹក្សាយោបល់មួយ ដែលអាច មានសមាសភាពចូលរួមពីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មេដឹកនាំសាសនា គ្រូបង្រៀន និងប្រធានភូមិ។ គណៈកម្មការប្រឹក្សាយោបល់នេះ អាចជួយកៀរគរ មូលនិធិហិរញ្ញប្រទាន សម្រាប់ក្រុម ដែលសមាជិក ក្រុមអាចខ្ចីបានភ្លាមនៅពេលក្រុមចាប់ផ្តើមដំណើរការ ដំបូងជួយដោះស្រាយទំនាស់ផ្សេងៗ ដែលអាចកើត មានក្នុងក្រុម ជួយរកទីផ្សារសម្រាប់ផលិតផល និង សេវាកម្មសម្រាប់សមាជិកក្រុម។

# ៤- ការលុបបំបាត់ពលកម្មកុមារប្រកបដោយជោគជ័យពីវិស័យផលិតកម្មអំបិលនៅកម្ពុជា



## សេចក្តីសង្ខេប

នៅឆ្នាំ២០១២ បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងអស់រយៈពេល ១១ឆ្នាំដោយភាគីពាក់ព័ន្ធនានា និងកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ នៃអង្គការពលកម្មអន្តរជាតិ ( ILO-IPEC ) វិស័យផលិតកម្មអំបិលនៅខេត្តកំពតនៃកម្ពុជាត្រូវបានប្រកាសជាចុងក្រោយប្រកបដោយប្រសិទ្ធភាព[12] ថា "ពុំមានពលកម្មកុមារទៀតឡើយ"។ របាយការណ៍អំពីការអនុវត្តល្អនេះ ពន្យល់អំពីមូលហេតុដែលការងារក្នុងវិស័យផលិតកម្មអំបិលមានគ្រោះថ្នាក់ដល់កុមារ និងសង្ខេបអំពីមូលហេតុដែលគំនិតផ្តួចផ្តើមមួយចំនួន របស់រាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា សហជីពនិងនិយោជក ដែលត្រូវបានចាត់ទុកថាមានសារៈសំខាន់ក្នុងការសម្រេចជោគជ័យនេះ និងផ្តល់ជាគំរូមួយសំរាប់ការដកហូតកុមារចេញពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅកម្ពុជា។

## សាវតា

ខេត្តកំពតជាខេត្តមួយនៅជាប់ឈូងសមុទ្រថៃ ជាប្រភពអំបិលដ៏សំខាន់របស់កម្ពុជា។ ឧស្សាហកម្មអំបិលបានចាប់ផ្តើមក្នុងទសវត្សរ៍ទី៦០ នៅតំបន់ឆ្នេរនេះ។ ហើយនៅឆ្នាំ

12 ពាក្យ "ប្រកបដោយប្រសិទ្ធិភាព" ត្រូវបានប្រើប្រាស់ដោយហេតុថាជាមួយនឹងភាពក្រីក្រនៅជនបទមានកំរិតខ្ពស់ និងកង្វះសំណាញ់សុវត្ថិភាពសង្គម របស់កម្ពុជានៅពេលដែលមានគ្រោះអាសន្ននានា ដូចជាការបណ្តេញចេញ គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត ការបាត់បង់ជីវិតអ្នកផ្គត់ផ្គង់គ្រួសារ ឬការចំណាយខ្ពស់ទៅលើការតស៊ូព្យាបាលជម្ងឺ នៅពេលនោះកសិករដែលពឹងផ្អែកតែលើកសិកម្មអាចបាត់បង់ដីធ្លី និងប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ពួកគេ ហើយពួកគេក៏បង្ខំចិត្តធ្វើចំណាកស្រុកទៅកន្លែងដូចជាស្រែអំបិល ដើម្បីអាចរកប្រាក់ផ្គត់ផ្គង់គ្រួសារ។ បើទោះបីជា និយោជក មន្ត្រីអប់រំ អ្នកដឹកនាំសហគមន៍ សហជីពបានប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ទាំងអស់គ្នា ក្នុងការលុបបំបាត់ពលកម្មកុមារក្នុងវិស័យ ផលិតកម្មអំបិលក៏ដោយ ក៏នៅតែមានឪពុកម្តាយកុមារមួយចំនួនតូចនៅតែឱ្យកូនៗរបស់ពួកគេធ្វើការក្នុងស្រែអំបិលដដែល ពោលគឺនៅមុនពេលដែលពួកគេត្រូវបានពន្យល់បញ្ចុះបញ្ចូលឱ្យដកហូតកុមារទាំងនោះ ចេញពីការងារនេះ។

២០១២ វាលស្រែអំបិលគ្របដណ្តប់លើផ្ទៃដីប្រហែល៥០០០ ហិកតា។ ផលិតផលប្រចាំឆ្នាំដែលភាគច្រើនបំផុតសំរាប់ទីផ្សារក្នុងស្រុកមានប្រហែលពី៨០០,០០០ដល់៩០០,០០០ តោន។

នៅកម្ពុជា អំបិលត្រូវបានផលិតក្នុងរដូវប្រាំងពីខែវិច្ឆិកាដល់ខែឧសភា។ ជំហានទី១ គឺគេបង្ហូរទឹកសមុទ្រមកក្នុងវាលស្រែដែលគេលើកភ្លឺដើម្បីរក្សាទឹកសមុទ្រទុក។ នៅក្រោមកំដៅព្រះអាទិត្យ វាលស្រែចាប់ផ្តើមរីងហួត រួចហើយអំបិលចាប់ផ្តើមឡើងក្រាម។ នៅពេលដែលក្រាមអំបិលរឹងមែនទែន ហើយទឹករីងហួតអស់ កម្មករគៀរក្រាមអំបិលជាគំនរ រួចហើយរែកវាយកទៅទុកក្នុងឃ្លាំង។ នៅទីនោះ អំបិលត្រូវបានថ្លឹង ចំណែកឯ កម្មករបានទទួលប្រាក់ឈ្នួលតាមបរិមាណ អំបិលដែលខ្លួនប្រមូលបាន។

ការងារក្នុងស្រែអំបិល ត្រូវបានចាត់ទុកជាការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារមួយក្នុងចំណោមការងារទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារទាំង១៦នៅកម្ពុជា។ ពលករកុមារចំណាយពេលថ្ងៃរបស់ខ្លួននៅក្រោមកំដៅព្រះអាទិត្យដ៏ក្តៅ ជើងរបស់ពួកគេស្ថិតក្នុងទឹកប្រៃក្តៅដែលស៊ីស្បែករបស់ពួកគេ។ នៅពេលដែលកុមារដើរដោយជើងទទេ ឬពាក់ស្បែកជើងផ្ទាត់លើក្រាមអំបិល ជើងពួកគេងាយមុត និងងាយឆ្លងមេរោគ។ គ្រោះថ្នាក់មួយទៀត សំរាប់កុមារដែលកំពុងមានការរីកធំធាត់ គឺការឈឺខ្នងដោយសារការរែកអំបិលធ្ងន់នៅលើស្មារបស់ខ្លួន។ ក្នុងបទសំភាសន៍ធ្វើឡើងដោយអង្គការ ILO-IPEC កុមារធ្វើការក្នុងស្រែអំបិលបានរាយការណ៍ថាជារឿយៗ ពួកគេមានការឈឺក្បាល ឈឺខ្នង រមាស់ស្បែក គ្រុនក្តៅ និងគ្រុនផ្តាសសាយជាដើម។



ថ្វីបើការងារក្នុងស្រែអំបិលជាការងារធ្ងន់ធ្ងរក៏ដោយ ក៏ប្រជាជនកម្ពុជាមួយចំនួននៅតែធ្វើការងារនេះដែរ ពីព្រោះពួកគេត្រូវការប្រាក់ដើម្បីចិញ្ចឹមគ្រួសារ ក៏ដូចជាដើម្បីចំណាយលើតម្រូវការរបស់គ្រួសារ ដូចជាប្រេងសាំងសំរាប់ទោចក្រយានយន្ត ឬកាណូត ធ្យូងសំរាប់ចំអិនអាហារ ប្រេងកាត និងថ្នាំសង្កូវ ។ល។ ប្រជាជននៅខេត្តកំពតដែលធ្វើការក្នុងស្រែអំបិល គឺក្រីក្រតោកយ៉ាកណាស់ ហើយពួកគេជាកសិករដែលធ្វើការបានត្រឹមតែមួយរស់បានព្រឹកខ្វះល្ងាច ដោយមិនអាចធ្វើដំណាំស្រូវគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ ជីវភាពគ្រួសារពេញមួយឆ្នាំបានទេ។ ពួកគេមានដីស្រែតូច (មួយហិកតា ឬតិចជាងនេះ) ចំណែកឯដីតាមឆ្នេរសមុទ្រមានគុណភាពអន់សំរាប់ដំណាំស្រូវឬកសិកម្ម។ពលករធ្វើការក្នុងស្រែអំបិលក៏ជាជនចំណាកស្រុកមកពីខេត្តផ្សេងៗទៀតផងដែរ ដែលមករកប្រាក់ ហើយពួកគេជ្រើសរើសធ្វើការក្នុងស្រែអំបិល ពីព្រោះពួកគេអាចរកការងារធ្វើបានយ៉ាងងាយសំរាប់រយៈពេល៥ឬ៦ខែ។



កិច្ចខិតខំប្រឹងប្រែងរបស់អង្គការ ILO IPEC និងភាគីពាក់ព័ន្ធផ្សេងៗទៀត ដូចជារាជរដ្ឋាភិបាល សង្គមស៊ីវិល សហជីព និងវិស័យឯកជន គឺដើម្បីធ្វើវិស័យស្រែអំបិលមិនមានពលកម្មកុមារ ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០១។ ហើយនៅឆ្នាំ២០១២ គឺជាឆ្នាំចុងបញ្ចប់ដែលវិស័យស្រែអំបិលត្រូវបានប្រកាសថា មិនមានពលកម្មកុមារទៀតឡើយ។ ថ្វីបើជនចំណាកស្រុកថ្មីៗ អាចនាំកូនឱ្យធ្វើការជាមួយខ្លួន ប៉ុន្តែកុមារត្រូវបានគេដកហូតចេញពីស្រែអំបិលភ្លាមៗ។ សូមអរគុណចំពោះការយល់ដឹងយ៉ាងខ្ពស់អំពីពលកម្មកុមារ និងការប្តេជ្ញាចិត្ត នៃកម្មសិទ្ធិករសហគ្រាសអំបិល និងពលករដែលបញ្ឈប់ពលកម្មកុមារ។ នៅពេលដែលគេរកឃើញកុមារធ្វើការគេបានប្រាប់ឪពុកម្តាយ ឱ្យយកកូនរបស់ខ្លួនចេញពីការដ្ឋាន

ប្រសិនបើកុមារអាយុតិចជាង១៥ឆ្នាំតែប្រសិនបើពី១៥-១៨ឆ្នាំគេប្រាប់ថាកុមារអាចធ្វើការដែលមិនប៉ះពាល់សុខភាព និងមិនរំខានការសិក្សា ឬការបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយ។

## វិធីដែលការអនុវត្តល្អនេះប្រតិបត្តិ

ចាប់តាំងពីឆ្នាំ២០០១មក មានគំនិតផ្តួចផ្តើមដែលមានការសម្របសម្រួលបានល្អមួយចំនួន ដូចដែលមានពិពណ៌នាខាងក្រោមនេះ និងបានផ្តល់ភស្តុតាងចាំបាច់មួយចំពោះការដកហូតកុមារទាំងស្រុងចេញពីការងារប្រកបដោយគ្រោះថ្នាក់ក្នុងវិស័យផលិតកម្មអំបិល ហើយវាបានផ្តល់ជាគំរូមួយនូវអភិក្រមដើម្បីបញ្ចប់ពលកម្មកុមារក្នុងវិស័យផ្សេងៗទៀត។

### ការគាំទ្រពីថ្នាក់កំពូល

អាជ្ញាធរពីរដ្ឋាភិបាលថ្នាក់កំពូល រួមទាំងនាយករដ្ឋមន្ត្រី និងគណៈរដ្ឋមន្ត្រី (ទីស្តីការគណៈរដ្ឋមន្ត្រី)ផងដែរ បានដាក់ការបញ្ចប់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារជាផ្នែកមួយនៃការងារស្នូលរបស់អាជ្ញាធរជាប់ឆ្នោត និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់តាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ភូមិ។ អំណាចកំរិតខ្ពស់នេះបានមកពីប្រភពសំខាន់ពីរគឺ៖ ផែនការសកម្មភាពជាតិស្តីពីការបញ្ចប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ និងអនុគណៈកម្មាធិការស្តីពីពលកម្មកុមារ ដែលជាផ្នែកមួយនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ តំណាងនៅក្នុងអនុគណៈកម្មាធិការស្តីពីពលកម្មកុមារ មកពីក្រសួងមួយចំនួនដែលមានតួនាទីសំខាន់ៗក្នុងការបញ្ចប់ពលកម្មកុមារ និងជាច្រើននាក់ទៀតមកពីថ្នាក់ខេត្ត។ សមាជិកអនុគណៈកម្មាធិការនេះក៏មានមកពីអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនានា សហជីពនិងវិស័យឯកជនផងដែរ។

### ការស្រាវជ្រាវ

ដើម្បីកំណត់អត្តសញ្ញាណកុមារដើម្បីដកហូតពីការងារ ឬទប់ស្កាត់កុមារ មិនឱ្យធ្លាក់ទៅក្នុងការងារឧស្សាហកម្មផលិតអំបិលនៅខេត្តកំពត ការស្រាវជ្រាវមួយត្រូវបានធ្វើឡើងដោយមន្ទីរផែនការខេត្ត ដោយរួមគ្នាជាមួយអ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ និងអ្នកឃ្លាំមើលសាលារៀន ។ គោលបំណងនៃការស្រាវជ្រាវនេះ គឺ ១) ដើម្បីកំណត់រកមុខសញ្ញាប្រមូលផ្តុំខ្ពស់នៃកុមារដែលកំពុងធ្វើការ ឬកុមារស្ថិតក្នុងហានិភ័យ នៃការឈានចូលទៅធ្វើការងារនៅក្នុងវិស័យនានា ដែលត្រូវបានចាត់ចំណាត់ថ្នាក់ក្នុងចំណោម ១៦ នៃការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅកម្ពុជា។ ២)ការវិភាគលើស្ថានភាពសង្គមសេដ្ឋកិច្ចនៃគ្រួសារពលករកុមារ ភាពប្រថុយប្រថាននឹងគ្រោះថ្នាក់ដាក់លាក់របស់ពលករកុមារ និងល័ក្ខខ័ណ្ឌក្នុងស្រុកដែលរួមចំណែកឱ្យមានពលកម្មកុមារ ៣) ផ្តល់ជាទិន្នន័យមូលដ្ឋាន សំរាប់វាស់វែងលទ្ធផលទាំងឡាយនៃកិច្ចខិតខំប្រឹងប្រែងនានាដើម្បីលុបបំបាត់ពលកម្មកុមារ។

### ផែនការសកម្មភាព

ផែនការសកម្មភាពមួយ ត្រូវបានបង្កើតឡើងដោយមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តសំរាប់វិស័យពលកម្មកុមារសំខាន់ៗ នៅខេត្តកំពត រួមទាំងវិស័យផលិតកម្មអំបិលផងដែរ។ ផែនការអាចវាស់វែងបាននេះបានកំណត់គោលដៅ ចំនួនកុមារដែលត្រូវដកហូតពីការងារ ឬត្រូវទប់ស្កាត់ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។

### បទប្បញ្ញត្តិហាមប្រាមពលកម្មកុមារ

បទប្បញ្ញត្តិ (ប្រកាសលេខ៣០៨ស្តីពីល័ក្ខខ័ណ្ឌការងារ និងល័ក្ខខ័ណ្ឌរស់នៅក្នុងសហគ្រាសផលិតអំបិល) ត្រូវបានបង្កើតឡើងដើម្បីកែលម្អល័ក្ខខ័ណ្ឌ ការងារសំរាប់មនុស្សពេញវ័យក្នុងវិស័យផលិតកម្មអំបិល ហើយក្នុងខចែងនានាក៏បានបញ្ជាក់យ៉ាងច្បាស់ដោយ ហាមដាច់ខាតមិនឱ្យជនណាដែលមានអាយុក្រោម១៥ឆ្នាំ ធ្វើការក្នុងវិស័យផលិតកម្មអំបិលនេះឡើយ ហើយប្រសិនបើជនណាមានអាយុពី១៥-១៨ឆ្នាំក៏មិនអាចឱ្យធ្វើការប្រកបដោយគ្រោះថ្នាក់ ឬរំខានដល់ការសិក្សារៀនសូត្រនៅសាលា ឬការបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយឡើយ។ បទប្បញ្ញត្តិទាំងនេះ ដែលចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្តល់សិទ្ធិអំណាចដល់ អ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ អ្នកឃ្លាំមើលតាមសាលា និងមន្ត្រីត្រួតពិនិត្យពលកម្មកុមារនៅកន្លែងធ្វើការដើម្បីលើកកម្ពស់ការយល់ដឹងដល់និយោជក ឪពុកម្តាយ និងប្រជាជនក្នុងសហគមន៍ថាកុមារ មិនអាចធ្វើការក្នុងឧស្សាហកម្មស្រែអំបិលឡើយ។



## ការលើកកម្ពស់ ការយល់ដឹងដល់ពលករកុមារនិង ឪពុកម្តាយរបស់ពួកគេ

នៅពេលដែលអ្នកស្រាវជ្រាវរកឃើញកុមារធ្វើការពាក់កណ្តាលពេលឬធ្វើការ ពេញម៉ោងក្នុងឧស្សាហកម្មអំបិលនៅខេត្តកំពត អ្នកត្រួតពិនិត្យពលកម្មកុមារតាមសហគមន៍ និងប្រធានភូមិបានចុះទៅជួបឪពុកម្តាយកុមារដើម្បីណែនាំបញ្ចុះបញ្ចូលពួកគាត់ឱ្យដកហូតកូនរបស់ពួកគេចេញពីការងារ។ក្នុងអំឡុងពេលចុះជួប ឪពុកម្តាយកុមារត្រូវបានប្រាប់អំពីច្បាប់កម្ពុជាស្តីពី ពលកម្មកុមារ និងបទប្បញ្ញត្តិនានាដែលដាក់ល័ក្ខខ័ណ្ឌតឹងតែងទៅលើការងារកុមារក្នុងវិស័យផលិតកម្មអំបិលហើយប្រាប់ថាការងារក្នុងស្រែអំបិល គឺជាការងារអាក្រក់ប៉ះពាល់ដល់សុខភាពកូនៗ របស់ពួកគេ ហើយច្បាប់កម្ពុជាតម្រូវឱ្យកុមាររៀនហូតដល់ចប់ថ្នាក់ទី៩ ឬរហូតដល់អាយុ១៥ឆ្នាំ កុមារអាចមានឱកាសការងារ និងរកប្រាក់ចំណូលបានកាន់តែច្រើន ប្រសិនបើពួកគេរៀនចប់ថ្នាក់ទី៩ ឬចប់ថ្នាក់ទី១២ កាន់តែប្រសើរ។ ពេលចុះជួបនេះក៏ប្រាប់ផងដែរអំពីជំនួយគាំទ្រផ្សេងៗ ដែលមានសំរាប់ជួយដល់កុមារ និងឪពុកម្តាយប្រសិនបើកុមារឈប់ធ្វើការទាំងស្រុង ហើយចុះឈ្មោះរៀនពេញម៉ោង ឬចូលរួមក្នុងវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈណាមួយ។

## អត្ថប្រយោជន៍ និងសេវាសំរាប់ពលករកុមារនិង ឪពុកម្តាយរបស់ពួកគេ

ដោយសារការស្រាវជ្រាវបង្ហាញថា ឪពុកម្តាយបញ្ជូនកូនទៅធ្វើការក្នុងស្រែអំបិលពេញម៉ោង ឬពាក់កណ្តាលពេល ពីព្រោះពួកគេត្រូវការឱ្យកូនជួយរកប្រាក់ផ្គត់ផ្គង់គ្រួសារ និងឪពុកម្តាយបានតស៊ូបង់ថ្លៃចំណាយលើការសិក្សារបស់កូន ដូច្នេះនឹងមានជំនួយឧបត្ថម្ភគាំទ្រដល់ឪពុកម្តាយកុមារ ប្រសិនបើពួកគេយល់ព្រម៖ ដកហូតកូនរបស់ពួកគេ ចេញពីការងារទាំងស្រុង ហើយទៅចុះឈ្មោះកូនរៀនពេញម៉ោងក្នុងសាលារដ្ឋ ឬសាលាក្រៅប្រព័ន្ធ ឬវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ហើយឱ្យកូនរៀនបានជាប់លាប់ ដោយមិនឱ្យត្រឡប់ទៅធ្វើការវិញទោះជាពាក់កណ្តាលពេលក្តី។ អត្ថប្រយោជន៍ និងសេវាដែលបានផ្តល់ដល់កុមារ និងឪពុកម្តាយរបស់ពួកគេ គឺខុសៗគ្នាអាស្រ័យលើតម្រូវការជាក់ស្តែង និងធនធានដែលមាន ប៉ុន្តែជាធម្មតាមាន ដូចខាងក្រោម៖



- **ការអប់រំក្នុងប្រព័ន្ធ៖** ប្រសិនបើពលករកុមារបានបោះបង់សាលាក្នុងរយៈពេលខ្លី ហើយពួកគេមិនរៀនខ្សោយជាងមិត្តភ័ក្តិក្នុងថ្នាក់ពេក អ្នកឃ្លាំមើលពលកម្មកុមារតាមសាលាជួយឱ្យកុមារចុះឈ្មោះចូលរៀន និងបានប្រាប់ឱ្យគ្រូប្រចាំថ្នាក់ មិនត្រូវយកថ្លៃឈ្នួលសិក្សាទាំងផ្លូវការ និងក្រៅផ្លូវការពីពួកគេឡើយ។ ថ្លៃសិក្សាទាំងនេះរួមមាន ការបង់ថ្លៃចុះឈ្មោះចូលរៀន ជាពិសេសកុមារដែលខ្វះខាតឯកសារចាំបាច់សំរាប់ការចុះឈ្មោះចូលរៀន(សំបុត្រកំណើតកំណត់ត្រាសិក្សាពីលើកមុនឬសៀវភៅគ្រួសារដែលបញ្ជាក់ទីលំនៅ) បង់ថ្លៃសំរាប់ថតចម្លងអត្ថបទមេរៀន និងបង់ថ្លៃរៀនបន្ថែមម៉ោង។
- **ការអប់រំក្រៅប្រព័ន្ធ៖** ប្រសិនបើកុមារបានបោះបង់សាលាយូរក្នុងរយៈពេលពីរបីឆ្នាំ ឬមិនដែលចុះឈ្មោះចូលរៀនសោះ ហើយអាចខ្សោយជាងកុមារដែលមានអាយុប្រហាក់ប្រហែលគ្នាដូច្នេះពួកគេត្រូវបានផ្តល់ការសិក្សាបំប៉នយ៉ាងតិច១ឆ្នាំក្នុង មណ្ឌលអប់រំក្រៅប្រព័ន្ធដែលសាងសង់ ជាពិសេសសំរាប់អតីតកុមារដែលធ្វើការក្នុងស្រែអំបិល។ នៅពេលកុមារទាំងនោះរៀនទាន់កុមារក្នុងវ័យដូចគ្នា ពួកគេត្រូវបានបញ្ជូនទៅចុះឈ្មោះ





ឱ្យចូលរៀនក្នុងសាលារដ្ឋវិញ តែប្រសិនបើកុមារនោះមានអាយុលើសពី១៥ ពួកគេត្រូវបានបញ្ជូនទៅចុះឈ្មោះឱ្យចូលរួមក្នុងវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈណាមួយ។

- **ការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ៖** ប្រសិនបើកុមារអាយុ១៥ឆ្នាំ ឬច្រើនជាងនេះហើយមិនចង់បន្តការសិក្សាទេ កុមារនៅខេត្តកំពតត្រូវបានជួយផ្គត់ផ្គង់ឱ្យចូលរៀនវគ្គបណ្ដុះបណ្ដាលជំនាញ វិជ្ជាជីវៈរយៈពេល៦ខែដូចជារៀនកាត់ដេររៀនធ្វើសក់រៀនកែសម្ផស្សរៀនជួសជុលគ្រឿងអេឡិចត្រូនិច ជួសជុលម៉ូតូ ឬរៀនភ្លេងប្រពៃណីខ្មែរដែលជំនាញទាំងនេះសង្ឃឹមថាមានការងារល្អនៅក្នុងខេត្តកំពត។

- **ការផ្គត់ផ្គង់ដល់កុមារដែលបានចុះឈ្មោះចូលរៀនក្នុងសាលារដ្ឋ (អប់រំក្នុងប្រព័ន្ធ)៖** ដើម្បីជួយកាត់បន្ថយការចំណាយរបស់ឪពុកម្ដាយ លើការអប់រំកូនក្នុងប្រព័ន្ធ កុមារត្រូវបានផ្ដល់ឱ្យ នូវសំលៀកបំពាក់ឯកសណ្ឋានសិស្សស្បែកជើងប្រសិនបើត្រូវការ សម្ភារៈសិក្សា (សៀវភៅមេរៀន សៀវភៅសរសេរ ប៊ិក ខ្មៅដៃ។ល។) និងក្នុងករណីខ្លះ ចែកកង់ឱ្យមួយគ្រឿងប្រសិនបើកន្លែងរស់នៅរបស់ពួកគេឆ្ងាយពីសាលា ។

- **អាហារបំប៉នបន្ថែម៖** ក្នុងឧស្សាហកម្មស្រែអំបិលនៅខេត្តកំពត និយោជកខ្លះផ្ដល់អង្ករមួយបាវរាល់ខែដល់គ្រួសារកុមារ ប្រសិនបើកុមារចូលរៀនជាប់លាប់ ឬបន្តចូលរៀនវគ្គបណ្ដុះបណ្ដាល ជំនាញវិជ្ជាជីវៈដោយមិនត្រឡប់ទៅធ្វើការវិញ។

- **ក្រុមសន្សំសំរាប់ឪពុកម្ដាយ៖** ឪពុកម្ដាយរបស់កុមារដែលត្រូវបានដកហូតពីពលកម្ម ទាំងពេញម៉ោង ឬពាក់កណ្ដាលពេល ក្នុងឧស្សាហកម្មស្រែអំបិលត្រូវបានជួយគាំទ្រឱ្យបង្កើតជាក្រុមសន្សំ ដើម្បីជួយកែលម្អលទ្ធភាពបង្កើនប្រាក់ចំណូលគ្រួសារ ដោយពុំចាំបាច់បញ្ជូនកូនៗ ទៅធ្វើការទៀតទេ។ ក្រុមសន្សំអាចឱ្យសមាជិកសន្សំប្រាក់អាចបានដោយសុវត្ថិភាព ទទួលបានអត្រាការប្រាក់ពីការសន្សំរបស់ខ្លួន អាចខ្ចីដោយមានអត្រាការប្រាក់ទាប ជាងអ្នករកស៊ីចងការប្រាក់ ឬស្ថាប័នមីក្រូហិរញ្ញវត្ថុ បង្កើនចំណេះដឹងចាត់ចែងហិរញ្ញវត្ថុ និងរៀនជំនាញ បង្កើតប្រាក់ចំណូលផ្សេងៗទៀត ដូចជាជំនាញចិញ្ចឹមមាន់ជាដើម។

## ការតាមដានត្រួតពិនិត្យពលកម្មកុមារ

ការតាមដានត្រួតពិនិត្យមើលយ៉ាងយកចិត្តទុកដាក់លើកុមារដែលត្រូវបានដកហូតពីពលកម្មពេញម៉ោង ឬពាក់កណ្ដាលពេលក្នុងឧស្សាហកម្មស្រែអំបិល នៅខេត្តកំពតត្រូវបានធានាថាកុមារ និងឪពុកម្ដាយរបស់ពួកគេបានទទួលជំនួយឧបត្ថម្ភដូចដែលអ្នកត្រួតពិនិត្យពលកម្មកុមារ តាមសហគមន៍បានសន្យា និងដើម្បីធ្វើឱ្យប្រាកដថាកុមារបានចូលរៀនបន្តជាប់លាប់ ឬចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈរបស់ខ្លួន ហើយមិនបានត្រឡប់ទៅធ្វើការវិញទេ ទោះជាពេញម៉ោង ឬពាក់កណ្ដាលពេលក៏ដោយ។ កំណត់ត្រាការតាមដានត្រួតពិនិត្យក៏ត្រូវបានចុះពិនិត្យដោយចៃដន្យខ្លះដើម្បីធានាថា ទិន្នន័យមានភាពសុក្រិត។

## សមាគមនិយោជកផលិតអំបិល

សមាគមនិយោជកមួយ ត្រូវបានបង្កើតឡើងដោយមានជំនួយពីអង្គការ ILO-IPEC ដើម្បីសម្រួលដល់ការលើកកម្ពស់ការយល់ដឹងរបស់និយោជកផលិតអំបិលអំពីពលកម្មកុមារ ពីព្រោះរាល់កិច្ចប្រជុំរបស់សមាគមនេះ មានការចូលរួមពីគ្រប់និយោជកទាំងអស់ ដែលអាចឱ្យពួកគេពិភាក្សាអំពីបញ្ហាពលកម្មកុមារនៅពេលជាមួយគ្នា ជាជាងទៅជួបនិយោជកម្នាក់ម្តងៗ។សមាគមក៏បានអនុម័តក្រមប្រតិបត្តិស្តីពីពលកម្មកុមារថ្នាក់ជាតិមួយ សំរាប់សហគ្រាសទាំងឡាយដែលជួយបង្កើនការប្តេជ្ញាចិត្តរបស់និយោជក។

## សហជីពកម្មករផលិតអំបិល

សហជីពកម្មករផលិតអំបិល ត្រូវបានបង្កើតឡើងដោយមានជំនួយពីអង្គការ ILO-IPEC ដើម្បីសម្រួលដល់ការរក្សាឱ្យកុមារនៅក្រៅការដ្ឋានស្រែអំបិលពីព្រោះ មានមេដឹកនាំសហជីពមួយចំនួន ដែលមិនត្រឹមតែបើកកិច្ចប្រជុំលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ ជាមួយកម្មករប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានការប្តេជ្ញាចិត្តបញ្ឈប់ពលកម្មកុមារ ដោយពិនិត្យឃ្លាំមើលឥតឈប់ឈរលើកុមារធ្វើការ និងផ្តល់ព័ត៌មានដល់និយោជក ប្រសិនបើមានកុមារណាម្នាក់ចាប់ផ្តើមធ្វើការ។ សហជីពនេះក៏បានអនុម័តលើការប្តេជ្ញាចិត្ត នៃសហភាពសហជីពថ្នាក់ជាតិ ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ ហើយត្រូវបិទប្រកាសយ៉ាងទូលំទូលាយតាមសហគ្រាសផលិតអំបិល និងសហគមន៍ក្បែរៗនោះ។

## កិច្ចសហប្រតិបត្តិការល្អរវាងនិយោជកផលិតអំបិល និងសហជីពកម្មករផលិតអំបិល

កិច្ចសហប្រតិបត្តិការរវាងនិយោជកផលិតអំបិល និងសហជីពកម្មករផ្តល់លទ្ធភាពសំរាប់អ្នកដឹកនាំសហជីពឱ្យបើកកិច្ចប្រជុំរយៈពេលមួយថ្ងៃ ដើម្បីលើកកម្ពស់ការយល់ដឹងដល់ពលករផលិតអំបិល ជៀសវាងកុំឱ្យពួកគេទាំងនោះយកកូនទៅធ្វើការហើយនឹងបដិសេធប្រសិនបើពលករផ្សេងៗធ្វើដូចនេះ។

## គណៈកម្មាធិការសម្របសម្រួល

នៅថ្នាក់ខេត្ត គណៈកម្មាធិការសម្របសម្រួលបានជួបប្រជុំគ្នាទៀងទាត់ជាមួយអ្នកដែលដើរតួសកម្ម ក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ ដើម្បីឱ្យពួកគេបានរាយការណ៍ពីអ្វីដែលបានធ្វើ ចែករំលែកបញ្ហា និងស្វែងរកដំណោះស្រាយរួមគ្នា។ អ្នកចូលរួមទាំងនេះមានបុគ្គលិករដ្ឋាភិបាលថ្នាក់ខេត្តមកពីមន្ទីរពាក់ព័ន្ធនានាដូចជាមន្ទីរអប់រំ មន្ទីរព័ត៌មាន មន្ទីរសុខាភិបាល មន្ទីរការងារ មន្ទីរផែនការ មន្ទីរសង្គមកិច្ច មន្ទីរកិច្ចការនារី អង្គការក្រៅរដ្ឋាភិបាល សង្គមស៊ីវិល សាសនា សមាគមនិយោជក សហជីពកម្មករ ប្រធានឃុំ ប្រធានភូមិ យោធា និងប៉ូលីស។ ម្យ៉ាងទៀត គណៈកម្មាធិការនេះ បាននាំឱ្យមានការជួបប្រជុំជាមួយ អ្នកត្រួតពិនិត្យ ពលកម្ម កុមារតាមសហគមន៍អ្នកត្រួតពិនិត្យតាមសាលារៀន និងមន្ត្រីត្រួតពិនិត្យកន្លែងការងារដើម្បីចែករំលែកបញ្ហា និងរកដំណោះស្រាយ។



## អ្វីដែលការអនុវត្តល្អនេះសម្រេចបានជោគជ័យ និងភស្តុតាងអំពីលទ្ធផលទាំងនោះ

នៅឆ្នាំ២០១២ វិស័យផលិតកម្មអំបិលនៅខេត្តកំពតត្រូវបានប្រកាសថា "គ្មានពលកម្មកុមារ" ដែលកុមារទាំងអស់ចំនួន១៧៦នាក់ (កុមារី៨៩នាក់) ដែលធ្វើការពេញម៉ោងឬពាក់កណ្តាលពេលនៅឆ្នាំ ២០១០-២០១២ ត្រូវបានដកហូតចេញពីការងារ និងត្រូវបានចុះឈ្មោះក្នុងសាលារដ្ឋ និងសាលាក្រៅប្រព័ន្ធ ឬមណ្ឌលបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ហើយមិនត្រឡប់ទៅធ្វើការវិញទេ ទោះជាពេញម៉ោងឬពាក់កណ្តាលពេលក្តី។ ហើយក៏ពុំមានកុមារណាម្នាក់ចូលធ្វើការក្នុងវិស័យស្រែអំបិលឡើយ។ វាស្ទើរតែគ្មានកុមារណាម្នាក់ធ្វើការក្នុងវិស័យផលិតកម្មអំបិលទៀតទេ ហើយលទ្ធផលទាំងនេះ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ តាមរយៈការត្រួតពិនិត្យយ៉ាងម៉ត់ចត់។



ការវាយតំលៃពីខាងក្រៅមួយ[13] ដែលធ្វើឡើងនៅខែសីហា ឆ្នាំ ២០១២បានបញ្ជាក់ថា មានចំនួនកុមារតិចតួចបំផុតកំពុងធ្វើការក្នុងស្រែអំបិលនៅឡើយ។ ការវាយតំលៃនេះដែលត្រូវផ្តល់ចម្លើយពីត្រីភាគីផ្សេងៗ គឺមាននិយោជក កម្មករ និងថ្នាក់ដឹកនាំឃុំ បានបង្ហាញថាអាចមានកុមារ១២នាក់កំពុងធ្វើការនៅឡើយ។

ករណីសិក្សាមួយ[14] ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់សហគមន៍ដើម្បីប្រយុទ្ធប្រឆាំង ពលកម្មកុមារក្នុងវិស័យផលិតកម្មអំបិលនៅឃុំត្រើយកោះក្នុងខេត្តកំពត បង្ហាញពីសមិទ្ធិផលក្នុងការជាប់ទាក់ទងទៅនឹងការអនុវត្តល្អនេះ៖

❖ ជាសរុបមានកុមារ៨៧នាក់ មកពី៣៨គ្រួសារក្នុងពីរភូមិត្រូវបានដកហូតពីការដ្ឋានស្រែអំបិល ហើយមកទល់ខែតុលា ឆ្នាំ២០១២ មិនមានកុមារណាម្នាក់ធ្វើការក្នុងស្រែអំបិលទំហំ១.០០០ ហិកតានៅឃុំត្រើយកោះទៀតឡើយ។ ឥឡូវនេះឪពុកម្តាយបានយល់ច្បាស់ពីសារៈសំខាន់ នៃការបញ្ជូនកូនខ្លួនឱ្យទៅរៀននៅសាលា និងយល់ពីផលវិបាកអវិជ្ជមានរយៈពេលខ្លី និងវែងដែលពលកម្មកុមារប៉ះពាល់ដល់សុខភាព និងឱកាសអនាគតកូនរបស់ពួកគេ។ឪពុកម្តាយ និយោជក និងកម្មករបានយល់ដឹងពីច្បាប់កម្ពុជា និងបទប្បញ្ញត្តិនានាដែលមិនអនុញ្ញាតឱ្យកុមារធ្វើការក្នុងវិស័យផលិតអំបិល ដូច្នេះ ឪពុកម្តាយ មិនឱ្យកូនធ្វើការក្នុងវិស័យនេះទៀតទេ រីឯនិយោជក និងកម្មករ ក៏ធានាថាកុមារមិនធ្វើការក្នុង ឧស្សាហកម្មផលិតអំបិលនេះទៀតឡើយ។

❖ អ្នកត្រួតពិនិត្យសហគមន៍នៅភូមិបឹងតាព្រហ្ម និយាយថាការផាកពិន័យ លើសហគ្រាសស្រែអំបិលណាមួយដែលនៅតែរឹងទទឹងក្នុងការជួលកុមារ គឺជាឧបករណ៍មួយ យ៉ាងសំខាន់ដើម្បីឱ្យមានការភ័យខ្លាច។

❖ ក្រុមប្រឹក្សាឃុំដែលជាស្ថាប័នចេញលិខិតបញ្ជាក់អាយុកុមារ គឺមានតម្លាភាព ដើម្បីធានាថាឪពុកម្តាយមិនភូតកុហកពីអាយុកូនដើម្បីអាចធ្វើការក្នុងការដ្ឋានស្រែអំបិលបាន។

❖ មានកត្តាផ្សេងៗគ្នាមួយចំនួន ដែលជួយឱ្យមានការផ្លាស់ប្តូរឥរិយាបថសហគមន៍ ដើម្បីធានាថាពលកម្មកុមារមិនអាចទទួលយកបាន ទៀតទេក្នុងរយៈពេលវែង និងមានការឱ្យតម្លៃខ្ពស់ទៅលើការទទួលបានកំរិតអប់រំខ្ពស់ ឬការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ។

- ឥឡូវនេះ ឪពុកម្តាយកុមារបានឃើញពីគំរូនៃគ្រួសារផ្សេងៗទៀតដែលមានកូនបានរៀនជំនាញវិជ្ជាជីវៈ អាចរកប្រាក់បានគ្រាន់បើ ហើយកូនបងៗ របស់ពួកគេបានជួយបង់ថ្លៃសិក្សាឱ្យប្អូនៗទៀត។
- ថ្វីបើក្នុងឃុំនេះ ភាគច្រើន មានទំនៀមទំលាប់គោរពសាសនាអ៊ិសស្លាម ដែលប្រជាជនប្រមាណ ៦០%ជាអ៊ិសស្លាមសាសនិក ដែលកុមារីឈប់រៀននៅថ្នាក់ទី៦ ហើយរៀបការនៅអាយុប្រហែល១៤ ឬ១៥ឆ្នាំ តែនៅពេលនេះ ទាំងកុមារា និងកុមារីបានយល់ច្បាស់ពីគំរូ នៃគ្រួសារដទៃទៀតដែលគេទទួលបានការអប់រំខ្ពស់ ហើយមានការងារល្អ ដូច្នេះនៅពេលនេះ កុមារចង់រៀនឱ្យបានយូរ ហើយចង់រៀបការកាន់តែយឺត។
- ដោយសារសមាជិកក្រុមប្រឹក្សាឃុំ មានការប្តេជ្ញាចិត្តលុបបំបាត់ពលកម្មកុមារ និងប្តេជ្ញាចិត្តលើកកម្ពស់ការយល់ដឹងក្នុងឃុំ ក្រុមប្រឹក្សាឃុំបានបញ្ចូលការលុបបំបាត់ពលកម្មកុមារទៅក្នុងផែនការប្រចាំឆ្នាំរបស់ ឃុំ។

13 ILO-IPEC ២០១២. លទ្ធផលរកឃើញជាគន្លឹះនៃការអង្កេតវាយតម្លៃក្នុងវិស័យផលិតអំបិលក្នុង ខេត្តកំពត និងវិស័យទូទៅក្នុងខេត្តកែប (ភ្នំពេញ-ILO)។

14 ILO-IPEC. 2013. ការសិក្សាពីបរិយាកាសគាំទ្រ/អំណោយផលដើម្បីកាត់បន្ថយពលកម្មកុមារ,... (2013), op cit.





- អ្នកត្រួតពិនិត្យសហគមន៍ និងអ្នកត្រួតពិនិត្យសាលាជឿជាក់ថាការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយាពាក់ព័ន្ធពលកម្មកុមារ នឹងបន្តទៀតសំរាប់រយៈពេលវែងហើយក៏មានការ "ខ្មាស់អៀន" ចំពោះជនណាដែលបញ្ជូនកូនទៅធ្វើការ ឬជួលកុមារឱ្យធ្វើការ។ ចំណែកឯអាជ្ញាធរមូលដ្ឋានវិញ ក៏បានប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ផងដែរថានឹងមាន "អប់រំ ស្តីបន្ទោស" ចំពោះឪពុកម្តាយណាដែលឱ្យកូនធ្វើការ។

## បញ្ហាប្រឈម/មេរៀនបទពិសោធន៍ចំពោះការអនុវត្តល្អនេះ

នៅក្នុងការសិក្សាស្តី ពីការបង្កើតបរិយាកាសគាំទ្រ/អំណោយផល[15] បានបង្ហាញថា សមាជិកគណៈកម្មាធិការអនុវត្តគម្រោងសកម្មភាពនៃអង្គការ ILO-IPEC បាននិយាយថាពួកគេជួបប្រទះបញ្ហាមួយចំនួន ក្នុងការលុបបំបាត់ពលកម្មកុមារក្នុងវិស័យឧស្សាហកម្មផលិតអំបិល មានដូចខាងក្រោម៖

- ភាពក្រីក្រធ្វើឱ្យមនុស្សគិតតែពីការរស់រានបន្ត ហើយមិនខ្វល់ពីអនាគតឡើយ។ជាលទ្ធផលគឺមានភាពប្រឈមក្នុងការបញ្ចុះបញ្ចូលឪពុកម្តាយដែលអោយកូនធ្វើការដែលប៉ះពាល់ជាអវិជ្ជមានដល់អនាគតក្មេង។

- ភាគច្រើនបំផុត នៃគ្រួសារជនចំណាកស្រុកមកកាន់ខេត្តកំពតមិនយល់ដឹងអំពីបញ្ហាពលកម្មកុមារទេ ហើយអាចឱ្យកូនរបស់គេធ្វើការ។

- ក្នុងចំណោមបញ្ហា ដែលបណ្តាលឱ្យឪពុកម្តាយបញ្ជូនកូនទៅធ្វើការគឺបណ្តាលមកពីធ្វើស្រែមិនបានទិន្នផលដោយសារគ្រោះរាំងស្ងួត ការចំណាយប្រាក់ព្យាបាលឪពុកម្តាយដែលឈឺរយៈពេលវែង គ្រឿងញៀនល្បែងស៊ីសង និងជំពាក់បំណុលគេ។

- មិនមានថវិកាជាតិ ឬមានតិចតួចត្រូវបានបែងចែកឱ្យថ្នាក់ឃុំ ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារ និងមិនមានមន្ត្រីរដ្ឋាភិបាលគ្រប់គ្រាន់ ចាត់តាំងឱ្យធ្វើការលើបញ្ហានេះ។

- ការលើកកម្ពស់ការយល់ដឹង អំពីពលកម្មកុមារ ឱ្យដល់គ្រួសារក្រីក្រនៅជនបទតាមរយៈប្រព័ន្ធផ្សព្វផ្សាយមិនមានប្រសិទ្ធិភាពទេ ពីព្រោះឪពុកម្តាយក្រីក្រជាច្រើនមិនចេះអាន ហើយពួកគេមិនមានលទ្ធភាពទិញ វិទ្យុ ឬទូរទស្សន៍បានទេ។

- ពលករខ្លះ មិនចង់ចូលរួមវគ្គបណ្តុះបណ្តាលអំពីពលកម្មកុមាររយៈពេលពេញមួយថ្ងៃទេ ពីព្រោះពួកគេនឹងខាតបង់ការរកប្រាក់កំរៃប្រចាំថ្ងៃ។

15 Ibid.

## លក្ខខណ្ឌគន្លឹះសំរាប់ប្រតិបត្តិតាមដោយជោគជ័យ និងនិរន្តរភាពនៃការអនុវត្តល្អនេះ



នៅក្នុងការសំភាសន៍ជាមួយភាគីពាក់ព័ន្ធ នៅក្នុងខេត្តកំពត អំពីការអនុវត្តល្អ ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ថ្នាក់ខេត្ត និងថ្នាក់ជាតិស្តីពីការអនុវត្តល្អ និងនៅក្នុងការសិក្សាស្តីការបង្កើតបរិយាកាសគាំទ្រ/អំណោយផល[16] សមាជិកគណៈកម្មាធិការអនុវត្តសកម្មភាពគម្រោងបានរកឃើញលក្ខខណ្ឌ គន្លឹះសំរាប់បន្តប្រតិបត្តិតាម និងធ្វើឱ្យមាននិរន្តរភាពក្នុងការប្រយុទ្ធប្រឆាំងពលកម្មកុមារ៖

- ធ្វើការស្រាវជ្រាវដើម្បី យល់ដឹងអំពីលក្ខណៈនៃពលកម្មកុមារក្នុងវិស័យ និងត្រូវធ្វើបញ្ជីឈ្មោះកុមារដែលត្រូវដកហូត ឬត្រូវទប់ស្កាត់ពីពលកម្មកុមារ។ រៀបចំទម្រង់បែបបទងាយបំពេញ និងងាយយល់ដើម្បីប្រើក្នុងការកត់ត្រាឈ្មោះកុមារម្នាក់ៗ និងការពិនិត្យតាមដាន។ ក្នុងការកំណត់អត្តសញ្ញាណកុមារត្រូវធានាថាឈ្មោះរបស់គេសរសេរត្រឹមត្រូវ ដើម្បីជៀសវាងការភ័ន្តច្រឡំរវាងឈ្មោះនៅក្នុងបញ្ជី និងឈ្មោះនៅក្នុងសៀវភៅគ្រួសារជាផ្លូវការ។
- បង្កើតបទប្បញ្ញត្តិ (ប្រកាស) ចំពោះលក្ខខណ្ឌការងារតាមវិស័យដាក់លាក់រួមទាំងការហាមប្រាមពលកម្មកុមារផងដែរ។
- បញ្ច្រាបបញ្ហាពលកម្មកុមារទៅក្នុងផែនការក្រុមប្រឹក្សាឃុំ ដើម្បីឱ្យមានការបែងចែកថវិកាសំរាប់ការងារនេះ។
- ធ្វើការផាកពិន័យ លើនិយោជកណាដែលនៅតែជួលកុមារធ្វើការ។
- ពង្រឹងសមត្ថភាពសមាគមនិយោជក និងសហជីពកម្មករ ដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលក្នុងការលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារ។
- បណ្តុះបណ្តាលអង្គការក្រៅរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលដែលធ្វើការងារផ្នែកកុមារ ដើម្បីឱ្យពួកគេបញ្ច្រាបពលកម្មកុមារក្នុងការងាររបស់ពួកគេនិងបែងចែកថវិកាសំរាប់ការងារនេះ។ គួរផ្តល់ការបណ្តុះបណ្តាលប្រចាំឆ្នាំសំរាប់បុគ្គលិកទទួលខុសត្រូវការងារពលកម្មកុមារ ពីព្រោះបុគ្គលិកអាចមានការផ្លាស់ប្តូរការងារ។
- បន្តបង្កើតក្រុមជួយខ្លួនឯង និងពង្រឹងក្រុមជួយខ្លួនឯងដែលមានស្រាប់ ដើម្បីជួយកែលំអប្រាក់ចំណូលឪពុកម្តាយកុមារ ដើម្បីកុំឱ្យពួកគេបញ្ជូនកូនទៅធ្វើការរកប្រាក់ផ្គត់ផ្គង់គ្រួសារទៀត។
- ប្រើមូលនិធិវិនិយោគឃុំដើម្បីផ្តល់ជាប្រាក់ដំកល់ចំនួន ១០០ដុល្លារដល់ក្រុមជួយខ្លួនឯង ដើម្បីអាចចាប់ផ្តើមឱ្យសមាជិកខ្ចី ដោយពុំចាំបាច់រង់ចាំទាល់តែមានការសន្សំគ្រប់គ្រាន់។
- បង្កើតកម្មវិធីសិក្សាដើម្បីលើកកម្ពស់ការយល់ដឹងដល់កុមារគ្រប់ឆ្នាំសិក្សា ដើម្បីឱ្យពួកគេយល់ដឹងច្បាស់ពីមូលហេតុដែលពួកគេ និងកុមារដទៃទៀតមិនត្រូវចូលរួមក្នុងពលកម្មកុមារ។
- ពង្រឹងសមត្ថភាព គណៈកម្មាធិការនៅថ្នាក់ខេត្តនិងថ្នាក់ឃុំ ដើម្បីឱ្យអ្នកដែលមានតួនាទីប្រយុទ្ធប្រឆាំងពលកម្មកុមារជួបប្រជុំគ្នាបានទៀងទាត់។ ផ្តល់ការបណ្តុះបណ្តាលមិនត្រឹមតែ អំពីបញ្ហាពលកម្មកុមារប៉ុណ្ណោះទេ ក៏ប៉ុន្តែត្រូវលើកស្ទួយសមត្ថភាពសមាជិកគណៈកម្មាធិការទាំងនោះ ដើម្បីឱ្យពួកគេអាចធ្វើការជាមួយគ្នាក្នុងទម្រង់មួយ ដែលមានការសំរបសំរួល។ គួរផ្តល់ការបណ្តុះបណ្តាលម្តងម្កាលដែរ ដោយសារសមាជិកអាចមានការផ្លាស់ប្តូរ ហើយអ្នកជំនួសត្រូវការការបណ្តុះបណ្តាល។

16 Ibid.



- ❖ ថ្វីបើប្រព័ន្ធផ្សព្វផ្សាយ (កាសែត វិទ្យុ ទូរទស្សន៍) មានប្រសិទ្ធិភាព ដើម្បីលើកកម្ពស់ការយល់ដឹងក្ដីនិងការយល់ដឹងកាន់តែច្រើនទៀតនៃសមាជិកសហគមន៍ ស្ដីពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារក៏ដោយ ក៏ត្រូវប្រើវិធីសាស្ត្រលើកកម្ពស់ការយល់ដឹងជាលក្ខណៈក្រុមនិងលក្ខណៈបុគ្គល ជាមួយប្រជាជនក្រីក្រដែលមិនចេះអាន ឬមិនមានលទ្ធភាពទិញវិទ្យុ ឬទូរទស្សន៍បាន។

- ❖ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារជាមួយសមាជិកសហគមន៍ទាំងកុមារនិងមនុស្សពេញវ័យនិងបង្វឹកសិស្សសាលាឱ្យលើកកម្ពស់ការយល់ដឹងក្នុងសាលារៀន និងក្នុងសហគមន៍តាមរយៈចំរៀង រឿងល្ខោន សំនួរចំលើយ និងគំនូរស្ដីពីពលកម្មកុមារ។

- ❖ បញ្ចុះបញ្ចូលក្រសួងធម៌ការ និងសាសនាឱ្យធ្វើការប្រយុទ្ធប្រឆាំងពលកម្មកុមារជាផ្នែកមួយនៃការងាររបស់ព្រះសង្ឃ។ព្រះសង្ឃជាអ្នកមានឥទ្ធិពលក្នុងសហគមន៍ ហើយអាចលើកកម្ពស់ការយល់ដឹងតាមរយៈធម្មទេសនាក្នុងវត្តក៏ដូចជាលើកទឹកចិត្ត ឱ្យប្រជាជនបរិច្ចាកទានក្នុងហិបជំនួយជាដើម។

- ❖ ត្រូវធានាថាមានការផ្ដល់ មូលនិធិដោយនិរន្តរភាពសំរាប់សម្ភារៈ និងសេវាកម្មដែលផ្ដល់ឱ្យកុមារ និងគ្រួសាររបស់ពួកគេ។ ប្រសិនបើមានការលើកទឹកចិត្តត្រឹមត្រូវ មូលនិធិនេះអាចបានយ៉ាងហោចណាស់ពីបីប្រភពគឺៈ អាជីវកម្ម និងអ្នកមានឥទ្ធិពលក្នុងសហគមន៍ ដែលចង់ផ្ដល់ការគាំទ្រ ដើម្បីឱ្យកុមារចាកផុតពីការងារប្រកបដោយគ្រោះថ្នាក់ ហិបវិភាគទាននៅទីតាំងសំខាន់ៗ និងការជួយគ្រួសារកុមារដែលកំពុងធ្វើការ ឱ្យក្លាយទៅប្រជាជនក្រីក្រ ដែលមានកំណត់ជាផ្លូវការ (ប័ណ្ណសម្គាល់ក្រ១ ឬក្រ២) ដូច្នេះពួកគេអាចទទួលបានសេវាសុខភាពដោយឥតគិតថ្លៃក្នុងមន្ទីរពេទ្យ ឬកន្លែងព្យាបាលរោគនានារបស់រាជរដ្ឋាភិបាល ក៏ដូចជាទទួលបានអត្ថប្រយោជន៍ផ្សេងៗទៀត។

- ❖ ផ្ដល់ប្រាក់ឧបត្ថម្ភគ្រប់គ្រាន់ដល់អ្នកត្រួតពិនិត្យពលកម្មកុមារ ដើម្បីទូទាត់ឱ្យពួកគេដែលតែងតែធ្វើការពេលយប់ និងនៅចុងសប្ដាហ៍ព្រោះជាពេលពលករកុមារ និងឪពុកម្ដាយនៅផ្ទះអាចជួបពិគ្រោះបាន។

- ❖ កម្មវិធីលើកកម្ពស់ការយល់ដឹងគួរផ្ដល់ប្រាក់លើកទឹកចិត្តដល់អ្នកចូលរួមក្រីក្រ ដែលគួរមានចំនួនស្មើនឹងប្រាក់ឈ្នួលដែលត្រូវខាតបង់ដោយសារការចូលរួម។



# ៥- ការបង្កើតផែនការសកម្មភាពទូលំទូលាយ តាមវិស័យ ដើម្បីបញ្ចប់ពលកម្មកុមារ



## សេចក្តីសង្ខេប

ដើម្បីគាំទ្រគោលដៅភ្លោះរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយពលកម្មកុមារមកត្រឹម៨% នៅឆ្នាំ២០១៥ និងលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារត្រឹមឆ្នាំ២០១៦ រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតផែនការសកម្មភាពជាតិស្តីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលនៅកម្ពុជា។ ក្នុងការបង្កើតផែនការនេះដែលត្រូវបានយល់ព្រមដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុគណៈកម្មាធិការជាតិស្តីពីពលកម្មកុមារជាមួយដៃគូនានាដែលបានដកស្រង់ការអនុវត្តល្អៗ ជាអន្តរជាតិមកដាក់បញ្ចូលក្នុងផែនការ ដើម្បីលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល វ៉ារីវប្បកម្ម និងវិស័យកែច្នៃជលផល។ ធ្វើការស្រាវជ្រាវរកបុព្វហេតុ និងផលវិបាកនៃពលកម្មកុមារក្នុងវិស័យជលផលនៅកម្ពុជា និងបានធ្វើការពិគ្រោះយោបល់ទូលំទូលាយ ដើម្បីប្រាកដថាផែនការដែលបានបង្កើតអាចសម្រេចបាន និងមានភាពងាយយល់។ អ្នកពាក់ព័ន្ធក្នុងការបង្កើតផែនការ ពលកម្មកុមារ ក៏ត្រូវធានាផងដែរ ដើម្បីឱ្យផែនការនេះ ស្របតាមក្របខ័ណ្ឌការងារយុទ្ធសាស្ត្រសំរាប់វិស័យជលផលពីឆ្នាំ២០១០-២០១៩ ដែលជាផែនការតាមវិស័យរយៈពេល ១០ឆ្នាំ សំរាប់វិស័យជលផល។

## សារតា

ការបញ្ចប់ពលកម្មកុមារក្នុងវិស័យជលផល គឺជាគោលបំណងដ៏សំខាន់មួយនៃរដ្ឋបាលជលផល នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទនៃប្រទេសកម្ពុជា ក៏ដូចជាកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ នៃអង្គការពលកម្មអន្តរជាតិ (ILO-IPEC)។ ទាំងវិស័យជលផល និងវិស័យកែច្នៃជលផល គឺស្ថិតក្នុងបញ្ជីនៃការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់

ធ្ងន់ធ្ងរនៃពលកម្មកុមារទាំង១៦ ដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តដើម្បីលុបបំបាត់ត្រឹមឆ្នាំ២០១៦ ហើយការស្រាវជ្រាវ[17] បង្ហាញថា វិស័យជលផលមានអត្រាពលកម្មកុមារខ្ពស់។

ការនេសាទត្រូវបានចាត់ទុកថាជា "ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ" ពីព្រោះវាជាការងារប្រកបដោយគ្រោះថ្នាក់។ ទូកតូចៗដែលប្រជានេសាទក្រីក្រប្រើមិនមានស្ថេរភាព ហើយងាយលិចទៅក្នុងទឹក។ កុមារត្រូវលង់ទឹកនៅពេលស្រាវមង ឬនៅពេលប្រើគ្រឿងផ្ទុះ ឬគ្រឿងអគ្គីសនីដើម្បីចាប់ត្រី។ ជាងនេះទៅទៀត ជួនកាលកុមារកម្ពុជា ត្រូវបានគេជួញដូរទៅកាន់ទូកនេសាទនៅប្រទេសដទៃទៀត ដែលពួកគេត្រូវធ្វើការដូចជាទាសករ។

ការនេសាទជាការងារយ៉ាងធ្ងន់ធ្ងរសំរាប់កុមារពីព្រោះជាទូទៅត្រូវធ្វើនៅពេលយប់ ហើយប្រជានេសាទ មិនអាចដេកបានឡើយក្នុងអំឡុងពេលថ្ងៃដ៏ក្តៅហែង និងអ៊ូអរ។ម៉ោងធ្វើការក៏មិនមានលទ្ធភាពឱ្យកុមាររៀនផង និងនេសាទផងបានទេ។ កុមារាជំទង់ៗ ធ្វើការនៅលើទូកជាមួយឪពុករបស់ខ្លួនក្នុងការរាយមង ស្រាវមង និងជួសជុលមង។ កុមារីជំទង់ៗធ្វើការងារជាមួយម្តាយ របស់ខ្លួនក្នុងការកែច្នៃផលត្រី។ ការកែច្នៃផលត្រី ក៏ស្ថិតក្នុងបញ្ជីនៃទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារទាំង ១៦ផងដែរ ពីព្រោះកុមារចំណាយពេលច្រើនម៉ោងក្នុងទឹកកខ្វក់ កាត់ត្រី ឬរើសងាវ និងគ្រឿងសមុទ្រផ្សេងៗទៀត ហើយដៃពួកគេអាចមុត និងអាចក្លាយដំបៅ។



ដើម្បីបញ្ចប់ពលកម្មកុមារ ក្នុងឧស្សាហកម្មនេសាទទឹកសមុទ្រ និងទឹកសាបនៅកម្ពុជា គេត្រូវជំនះលើបញ្ហាប្រឈមជាច្រើន។បញ្ហាប្រឈមទីមួយគឺការផ្តល់ការសិក្សា។ជាទូទៅគ្រួសារដែលធ្វើការនេសាទនៅតាមសមុទ្រ និងទឹកសាបជាប្រជាជនគ្មានដីធ្លី ដែលរស់នៅក្នុងសហគមន៍អនាធិបតេយ្យនៅតាមឆ្នេរសមុទ្រ តាមច្រាំងទន្លេ ឬតាមភូមិបណ្តែតទឹក ហើយសហគមន៍ទាំងនេះនៅឆ្ងាយពីសាលារៀន។ ដើម្បីទៅសាលារៀន កុមារត្រូវធ្វើដំណើរតាមទូកដែលត្រូវការប្រើប្រេងដែលថ្លៃ ហើយការធ្វើដំណើរតាមទូកគឺងាយមានគ្រោះថ្នាក់ជាយថាហេតុនៅរដូវទឹកជំនន់។ ប្រសិនបើមិនមានសាលាសំរាប់កូនប្រជានេសាទទេនោះ ឪពុកម្តាយប្រហែលមិនមានជំរើសណាក្រៅពីបញ្ជូនកូនទៅធ្វើការឡើយ[18]។

សម្ភារៈ គឺជាបញ្ហាប្រឈមមួយទៀត ក្នុងការដកហូតកុមារពីការងារក្នុងឧស្សាហកម្មនេសាទ។ ជាទូទៅ លំនៅដ្ឋាននិងការិយាល័យរបស់ខ្លួន នៅឆ្ងាយពីសហគមន៍នេសាទដែលអ្នកត្រួតពិនិត្យពលកម្មកុមារត្រូវចំណាយប្រាក់ច្រើននិងពេលវេលាដើម្បីធ្វើដំណើរ។ ជាទូទៅប្រជានេសាទទទួលទានដំណេកក្នុងអំឡុងពេល ដែលអ្នកត្រួតពិនិត្យពលកម្មកុមារទៅរកជួប។

## វិធីដែលការអនុវត្តល្អនេះប្រតិបត្តិ

ដោយសារការបញ្ចប់ពលកម្មកុមារ ក្នុងវិស័យជលផលគឺជាអាទិភាពចំបងរបស់រាជរដ្ឋាភិបាលហើយត្រូវបានមើលឃើញថាជាបញ្ហាប្រឈម អ្នកគ្រប់គ្រងរដ្ឋបាលជលផល បានបង្កើតផែនការសកម្មភាពជាតិស្តីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលនៅកម្ពុជា ដើម្បីជាមាគ៌ាសំរាប់ការងាររដ្ឋបាលជលផល និងកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នផ្សេងទៀត។



17 រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឆ្នាំ២០១២. ការវាយតម្លៃបែបចូលរួមនៃគម្រោងជលផលខ្នាតតូចនៅកម្ពុជា តាមរយៈ ការពិគ្រោះយោបល់នៅមូលដ្ឋានជាមួយសហគមន៍នេសាទ ( Phnom Penh, FiA/MAFF )

18 FiA & MAFF. ការវាយតម្លៃបែបចូលរួមនៃគម្រោងជលផលខ្នាតតូច,... (2012), op. cit.

ដូចមានពន្យល់ខាងក្រោមនេះ ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យជលផលនៅកម្ពុជា ត្រូវបានផ្អែកលើមូលដ្ឋាន នៃការស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ លើបុព្វហេតុ និងផលវិបាកនៃពលកម្មកុមារក្នុងវិស័យជលផល និងបានធ្វើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ក្នុងការអនុវត្តផែនការលុបបំបាត់ពលកម្មកុមារ ដើម្បីធានាថាពួកគេព្រមព្រៀងលើផែនការនេះ ហើយនឹងអនុវត្តវា។ ជាសំខាន់ផងដែរ ផែនការនេះ ត្រូវបានអនុម័តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុគណៈកម្មាធិការជាតិលុបបំបាត់ពលកម្មកុមារ។ ការអនុម័តនេះ មានន័យថាអ្នកដែលពាក់ព័ន្ធក្នុងការអនុវត្ត ផែនការ មានសិទ្ធិអំណាចពីថ្នាក់កំពូលនៃរាជរដ្ឋាភិបាល ដើម្បីកំណត់អាទិភាពលើការងារពលកម្មកុមារ។ មានផែនការល្អមួយក៏ជួយដល់ រដ្ឋបាលជលផលឱ្យធានាបានសុវត្ថិភាពផ្នែកមូលនិធិ ដើម្បីចាប់ផ្តើមអនុវត្តផែនការ នៅឆ្នាំ២០១៣។

## ការស្រាវជ្រាវដើម្បីយល់ដឹងពីបុព្វហេតុនៃពលកម្មកុមារ

ជាជំហានដំបូងក្នុងការបង្កើតផែនការ ដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារក្នុងវិស័យឧស្សាហកម្មជលផល រដ្ឋបាលជលផលបានធ្វើការស្រាវជ្រាវក្នុងសហគមន៍នេសាទ ដើម្បីរកកត្តាដែលរួមចំណែកលើពលកម្មកុមារនិងដើម្បីកំណត់វិធីសាស្ត្រល្អបំផុតដើម្បីដោះស្រាយមូលហេតុ នៃពលកម្មកុមារ។ ការស្រាវជ្រាវនេះ គឺជាផ្នែកមួយនៃការប៉ាន់ប្រមាណយ៉ាងទូលំទូលាយថែមទៀត លើបញ្ហាជលផល[19] ដែលផ្តល់មូលនិធិដោយអង្គការស្បៀងអាហារ និងកសិកម្ម (FOA) ហើយការស្រាវជ្រាវនេះក៏ នឹងប្រើជាទិន្នន័យមូលដ្ឋានមួយដើម្បីវាស់វែងលទ្ធផលនៅពេលអនាគត។ លទ្ធផលសំខាន់ៗរួមមាន៖ កង្វះឱកាសដើម្បីការអប់រំគឺជាការរួមចំណែកយ៉ាងសំខាន់ ចំពោះពលកម្មកុមារក្នុងសហគមន៍ នេសាទ។ ក្នុងសហគមន៍នេសាទដែលមានប្រជាជនមូស្លីម ច្រើនបំផុតគេចាត់ទុកថាការអប់រំដល់កុមារាមានសារៈសំខាន់ជាងកុមារី ពីព្រោះកុមារីត្រូវរៀបការនៅវ័យក្មេង។ កុមារភាគច្រើនបំផុតធ្វើការឱ្យគ្រួសារខ្លួន ហើយមិនបានធ្វើការឱ្យអាជីវកម្មនេសាទឬប្រតិបត្តិការ កែច្នៃជលផលឡើយ។

## ការធ្វើឱ្យផែនការលុបបំបាត់ពលកម្មកុមារស្របគ្នានឹងក្របខ័ណ្ឌ ផែនការយុទ្ធសាស្ត្រសំរាប់វិស័យជលផល ឆ្នាំ ២០១០-២០១៩

ដើម្បីបង្កើតផែនការលុបបំបាត់ពលកម្មកុមារ បុគ្គលិករដ្ឋបាលជលផល បានធ្វើឱ្យប្រាកដថាផែនការនេះ មានភាពស៊ីសង្វាក់គ្នានឹងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រ១០ឆ្នាំនៃវិស័យជលផលដែលកំណត់លទ្ធផលខាងក្រោម៖

១. ការរួមចំណែកនៃប្រជានេសាទ និងវារីវប្បកម្មចំពោះវិបុលភាពជាតិមានកំរិតខ្ពស់ និងមាននិរន្តរភាព។

២. ការចិញ្ចឹមជីវិតរបស់ប្រជាជនក្នុងវិស័យនេះ កំពុងមានការកែលម្អហើយនៅលើមធ្យមភាគជាតិ។

៣. វិស័យជលផល និងធនធានពាក់ព័ន្ធស្ថិតក្នុងល័ក្ខខ័ណ្ឌល្អនិងសំបូរបែបហើយត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព

៤. មច្ឆាជាតិជាប្រភពស្បៀងអាហារ យ៉ាងមានតម្លៃ និងសំបូរបែប

៥. អាជីវកម្មជលផល ជាអាជីវកម្មទទួលប្រាក់ចំណេញច្រើន មាននិរន្តរភាព និងមានការទទួលខុសត្រូវ

៦. វិស័យជលផលត្រូវបានគ្រប់គ្រង ត្រូវបានអភិវឌ្ឍន៍ និងអភិរក្សក្នុងកិច្ចសហប្រតិបត្តិការ យ៉ាងជិតស្និទ្ធិជាមួយប្រទេសជិតខាង

៧. គោលនយោបាយបរិយាកាសនិយ័តកម្មនិងគាំទ្រដល់វិស័យជលផលមានភាពគ្រប់គ្រាន់ និងសមស្រប



19 FiA & MAFF. ការវាយតម្លៃបែបចូលរួមនៃគម្រោងជលផលខ្នាតតូច,... (2012), op. cit.

ក្នុងចំណោមលទ្ធផលគន្លឹះទាំងនេះ លទ្ធផលដែលពាក់ព័ន្ធជាពិសេសជាមួយពលកម្មកុមាររួមមានការធ្វើឱ្យប្រសើរឡើងនៃការចិញ្ចឹមជីវិត ការធ្វើប្រតិបត្តិការអាជីវកម្មនេសាទដោយមានផលចំណេញ មាននិរន្តរភាព និងមានការទទួលខុសត្រូវ និងការកែលំអគោលនយោបាយ បទប្បញ្ញត្តិ និងការបង្កើតបរិយាកាសគាំទ្រ/អំណោយផលដោយរាជរដ្ឋាភិបាល។

## ការដកស្រង់ការអនុវត្តល្អបំផុតជាអន្តរជាតិក្នុងគំនិតផ្តួចផ្តើមដើម្បីបញ្ចប់ពលកម្មកុមារ

ក្នុងការបង្កើតផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល នៅកម្ពុជា បុគ្គលិករដ្ឋបាលជលផល បានដកស្រង់ពីគោលការណ៍ណែនាំដែលបង្កើតឡើងដោយអង្គការ FAO និងអង្គការ ILO-IPEC ស្តីពីការណែនាំអនុវត្តល្អដើម្បី ដោះស្រាយបញ្ហាពលកម្មកុមារក្នុងវិស័យជលផល និងវារីវប្បកម្មរបស់អង្គការ FAO និងអង្គការ ILO ៖ គោលនយោបាយ និងការអនុវត្ត[20]។ ឯកសារនេះផ្តល់ជាគោលការណ៍ណែនាំ យុទ្ធសាស្ត្រ និងឧបករណ៍យ៉ាងមានប្រយោជន៍សំរាប់រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារ ដើម្បីលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលមានដូចជា៖

**ផ្នែកទី១៖ កុមារក្នុងវិស័យជលផល និងវារីវប្បកម្ម៖** បានពន្យល់ពីការងារ ដែលបានធ្វើដោយកុមារក្នុងវិស័យជលផលវារីវប្បកម្ម និងការកែច្នៃជលផល ដោយលើកឡើងពីភាពផ្សេងគ្នារវាងការងារដែលអាចទទួលយកបាន ទល់នឹងការងារប្រកបដោយគ្រោះថ្នាក់ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ហើយបានបង្ហាញពីការពិចារណាលើយេនឌ័រ និងពន្យល់ពីចំណងទាក់ទងរវាងពលកម្មកុមារ ភាពក្រីក្រ និងការនេសាទដោយពុំមាននិរន្តរភាព។ ផ្នែកទី១ ក៏ពិភាក្សាផងដែរ ពីបញ្ហាសំខាន់ៗនៃសហគមន៍នេសាទដូចជាការចំណាកស្រុកយ៉ាងច្រើនបញ្ហាមេរោគអេដស៍ អំពើហិង្សាផ្អែកយេនឌ័រ និងការរំលោភបំពានផ្សេងៗទៀតដែលអាចប៉ះពាល់ ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ ពលកម្មកុមារ ក្នុងវិស័យជលផល។

**ផ្នែកទី២៖ គោលការណ៍ណែនាំពីវិធីដោះស្រាយពលកម្មកុមារក្នុងវិស័យជលផល និងវារីវប្បកម្ម៖** ផ្តល់ឱវាទ លើវិធីសាស្ត្រជាក់ស្តែងជាច្រើន និងការធ្វើអន្តរាគមន៍ ដោយចាប់ផ្តើមធ្វើការប៉ាន់ប្រមាណហានិភ័យ នៃពលកម្មកុមារដែលកំណត់រកគ្រោះថ្នាក់ វាយតំលៃលើហានិភ័យ និងរកវិធានការឱ្យមានសុវត្ថិភាព និងសុខភាពក្នុងការងារដើម្បីការពារកុមារឱ្យរួចផុតពីគ្រោះថ្នាក់។ ផ្នែកនេះ ក៏ផ្តល់ឱវាទផងដែរ លើវិធីប៉ាន់ប្រមាណហានិភ័យលើទូកនេសាទ ដោយអនុលោមតាមអនុសញ្ញាអន្តរជាតិផ្សេងៗ ច្បាប់ និងគោលការណ៍ណែនាំស្ម័គ្រចិត្ត និងពីវិធីបង្កើតបញ្ជីការងារប្រកបដោយ គ្រោះថ្នាក់ នៅក្នុងប្រទេស និងទីតាំងឬប្រភេទនៃសហគ្រាសដែលមានការងារប្រកបដោយគ្រោះថ្នាក់ទាំងនេះដែលគួរ ហាមប្រាមដោយច្បាប់។ គោលការណ៍ណែនាំនេះក៏ផ្តល់ឱវាទផងដែរលើការប្រមូលទិន្នន័យ តាមរយៈការប្រើប្រព័ន្ធព័ត៌មានដែលមានស្រាប់ (ដូចជាស្ថិតិថ្នាក់ឃុំ និងស្រុក ការអង្កេតប្រជាជន និងសុខភាព ការធ្វើអធិការកិច្ចការងារ។ល។) និងការប៉ាន់ប្រមាណថ្មីៗ ពាក់ព័ន្ធនឹងវិធីសាស្ត្រផ្អែកលើការអង្កេតដោយមានការចូលរួម និងវិធីសាស្ត្រស្រាវជ្រាវផ្អែកលើការអង្កេត។ គោលការណ៍ណែនាំ បានបង្ហាញពីវិធីដែលអាចប្រើទិន្នន័យពលកម្មកុមារក្នុងការលើកកម្ពស់ ការយល់ដឹង ការកសាងសមត្ថភាព និងការតស៊ូមតិគោលនយោបាយ និងក្របខ័ណ្ឌសកម្មភាព ដើម្បីកាត់បន្ថយ និងលុបបំបាត់ពលកម្មកុមារ ពីវិស័យជលផល និងវារីវប្បកម្ម។

---

20 FAO & ILO-IPEC ២០១១. សង្ខេបនៃគោលការណ៍ណែនាំការអនុវត្តល្អរបស់អង្គការ FAO និងអង្គការ ILO ដើម្បីឆ្លើយតបពលកម្មកុមារក្នុងវិស័យជលផល និងវារីវប្បកម្ម៖ គោលនយោបាយ និងការអនុវត្ត។ Preliminary Version (Rome, FAO). អាចរកបាននៅ: ftp://ftp.fao.org/FI/DOCUMENT/child_labour_FAO-ILO/child_labour_FAO-ILO.pdf.



គោលការណ៍ណែនាំការអនុវត្តល្អរួមគ្នាដោយអង្គការ FAO និងអង្គការ ILO បានធ្វើការសន្និដ្ឋានដោយមានឧទាហរណ៍ជាក់លាក់ពីវិធីដែលក្របខ័ណ្ឌការងារអាចអនុវត្តក្នុងវិស័យនៃការកែលម្អការអប់រំការផ្លាស់ប្តូរឥរិយាបថអាកប្បកិរិយារបស់និយោជកនិងអតិថិជនរបស់ខ្លួនជំរុញផ្សព្វផ្សាយបច្ចេកវិទ្យាទំនើប និងការអនុវត្ត ហើយជាសំខាន់បំផុត គឺការដកហូត និងទប់ស្កាត់កុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។



## ការពិគ្រោះយោបល់ទូលំទូលាយ ពីអ្វីត្រូវបញ្ចូលក្នុងផែនការជាតិលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល

ការពិគ្រោះយោបល់ពីរលើកត្រូវបានរៀបចំធ្វើឡើង ដើម្បីកំណត់រកអ្វីដែលត្រូវបញ្ចូលក្នុង ផែនការជាតិលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ។ ក្នុងកិច្ចពិភាក្សាលើកទីមួយ[21] មានបុគ្គលិកជំនាញជលផលជាង ៤០នាក់បានជួបប្រជុំជាមួយអ្នកជំនាញពលកម្មកុមារ ដើម្បីទទួលការបណ្តុះបណ្តាលអំពីពលកម្មកុមារ។ គោលបំណងគឺដើម្បីបណ្តុះបណ្តាលបុគ្គលិកជលផល ឱ្យលើកកម្ពស់ការយល់ដឹងអំពីពលកម្មកុមារក្នុងសហគមន៍នេសាទ និងក៏ដើម្បីជួយសមាគមសហគមន៍នេសាទ ដើម្បីបញ្ចូលគំនិតផ្តួចផ្តើមប្រឆាំងពលកម្មកុមារក្នុងវិស័យជលផល ទៅក្នុងផែនការ៥ឆ្នាំនៃសមាគមសហគមន៍នេសាទ។ ជាផលត្រឡប់មកវិញ ផែនការ៥ឆ្នាំនៃសមាគមសហគមន៍ នេសាទត្រូវប្រើក្នុងការបង្កើតផែនការ៥ឆ្នាំរបស់ឃុំ ក៏ដូចជាផែនការ និងសមាគមសហគមន៍នេសាទ ថវិកាប្រចាំឆ្នាំរបស់ឃុំ។

នៅទូទាំងកម្ពុជា នៅសហគមន៍នេសាទទាំងទឹកប្រៃ និងទឹកសាបមានអ្នកនេសាទ និងគ្រួសាររបស់ពួកគេជាងកន្លះលាននាក់ ស្ថិតក្នុងសមាគមសហគមន៍នេសាទជាង ៥០០ ។ ក្រុមទាំងនេះត្រូវបានបង្កើតឡើងដោយមានការជួយជ្រោមជ្រែងពីរដ្ឋបាលជលផលមានសារៈសំខាន់ណាស់ ក្នុងការគ្រប់គ្រងធនធានមច្ឆាជាតិឱ្យមាននិរន្តរភាពហើយជួយប្រជានេសាទទាំងអស់ឱ្យកែលម្អការចិញ្ចឹមជីវិតរបស់ខ្លួន តាមរយៈការបណ្តុះបណ្តាលពីវារីវប្បកម្ម និងធ្វើឱ្យផលិតផលមច្ឆាជាតិមានគុណភាពខ្ពស់ដើម្បីលក់។ ចំពោះហេតុផលនេះ រដ្ឋបាលជលផលយល់ថាសមាគម គឺជាគន្លឹះក្នុងការអនុវត្តគំនិតផ្តួចផ្តើមពាក់ព័ន្ធនឹងការលុបបំបាត់ពលកម្មកុមារ។



21 ILO-IPEC. ២០០១. សិក្ខាសាលាស្តីពីពលកម្មកុមារ ទម្រង់ធ្ងន់ធ្ងររបស់វា និងសមាហរណកម្មទៅក្នុងវិស័យជលផលនៅកម្ពុជា។ កំណត់ហេតុព្រាងមិនទាន់បោះពុម្ពផ្សាយ(ភ្នំពេញ ILO)។

ក្នុងកិច្ចពិគ្រោះយោបល់លើកទីពីរ[22] ដែលត្រូវបានរៀបចំឡើង ដូចគ្នានឹងលើកទីមួយ ដែរដោយមានការឧបត្ថម្ភហិរញ្ញវត្ថុ និងបច្ចេកទេសពីអង្គការ FAO និងអង្គការ ILO-IPEC មានអ្នកតំណាងសមាគមសហគមន៍នេសាទ ជាង៥០នាក់ មកពីតំបន់ឆ្នេរ បឹងទន្លេសាប និងតំបន់ទន្លេមេគង្គបានទទួលការអញ្ជើញឱ្យមកចូលរួម។ កិច្ចពិគ្រោះយោបល់នេះបានលើកកម្ពស់ ការយល់ដឹងរបស់អ្នកតំណាងសមាគមសហគមន៍នេសាទអំពីបញ្ហាពលកម្មកុមារ រួមមាន លទ្ធផលពីការប៉ាន់ប្រមាណពលកម្មកុមារក្នុងវិស័យជលផល។អ្នកតំណាងរដ្ឋបាលជលផល ក៏បានពិភាក្សាគ្នាផងដែរពីអ្វីដែលត្រូវបញ្ចូលក្នុងផ្នែកទាំង៤នៃផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យ ជលផលនៅកម្ពុជា។

**សមាសភាពគន្លឹះ នៃផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលនៅកម្ពុជា )[23]**

*១. គោលនយោបាយ និងច្បាប់*

គោលបំណងទាំងឡាយរួមមាន៖ ការបង្កើតលក្ខណៈវិនិច្ឆ័យតាមបទដ្ឋានលើអ្វី ដែលបង្កើតពលកម្មកុមារក្នុងវិស័យជលផល កំណត់អាណត្តិនៃគណៈកម្មាធិការយែនឌ័ររបស់រដ្ឋបាលជលផល ដោយមានភារៈកិច្ចអនុវត្ត និងត្រួតពិនិត្យគំនិតផ្តួចផ្តើមប្រឆាំងពលកម្មកុមារនៅក្នុងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បញ្ចូលបញ្ហាពលកម្មកុមារ ក្នុងក្របខ័ណ្ឌនិងគោលនយោបាយដែលមានស្រាប់របស់រដ្ឋបាលជលផល និងបង្កើតគោលនយោបាយថ្មីដូចជាប្រកាសរួម ក្រមប្រតិបត្តិរបស់និយោជកនិងពិធីសារសំរាប់រាយការណ៍អំពីការរំលោភបំពានពលកម្មកុមារ និងការដាក់ទោសទណ្ឌដល់និយោជក។ គោលបំណងទាំងនេះក៏រួមបញ្ចូលផងដែរនូវ ការជំរុញឱ្យមានការរួមបញ្ចូលវិស័យជលផលក្នុងការអភិវឌ្ឍនិងយុទ្ធសាស្ត្រគាំពារសង្គមថ្នាក់ជាតិនៃកម្មវិធីផ្តល់រង្វាន់សំរាប់សកម្មភាពដ៏អស្ចារ្យ ដែលធ្វើឡើងដើម្បីប្រឆាំងពលកម្មកុមារ។



*២. ចំណេះដឹង និងការយល់ដឹង*

គោលបំណងរួមមានការកែលម្អមូលដ្ឋានចំណេះដឹងចំពោះពលកម្មកុមារ ក្នុងវិស័យជលផលតាមរយៈការប៉ាន់ប្រមាណហានិភ័យ ដោយមានការចូលរួមល័ក្ខខ័ណ្ឌតម្រូវឱ្យក្រុមហ៊ុនដែលដាក់ពាក្យសុំអាជ្ញាប័ណ្ណពីរដ្ឋបាលជលផល ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដែលឱ្យគេប្តេជ្ញាចិត្ត មិនជួលពលករកុមាររួមមានសំនួរស្តីពីពលកម្មកុមារក្នុងការសិក្សាស្រាវជ្រាវទ្រង់ទ្រាយធំដូចជាការអង្កេត វិស័យជលផលនិងការជំរឿនកសិកម្ម ការផ្សព្វផ្សាយព័ត៌មានស្តីពីពលកម្មកុមារ តាមរយៈទិវាជលផលប្រចាំឆ្នាំ ព្រឹត្តិការណ៍សាធារណៈនិងការបណ្តុះបណ្តាលនិយោជកនិងកម្មករ និងការជំរុញឱ្យមានវិធីសាស្ត្រធ្វើការងារប្រកបដោយសុវត្ថិភាព ក្នុងដំណាក់កាលនីមួយៗនៃបណ្តាញសង្វាក់ផលិតកម្ម ជលផលសំរាប់កុមារអាយុពី១៥-១៧ឆ្នាំ និងយុវជនអាយុពី១៨ឆ្នាំឡើង។

*៣. ការចិញ្ចឹមជីវិត និងវិធីសាស្ត្រចំរុះ*

គោលបំណងរួមមានការបង្កើននិរន្តរភាព ផលិតភាពភាពចំរុះ សន្តិសុខស្បៀង និងប្រាក់ចំណូលរបស់គ្រួសារនិងសហគមន៍ប្រជានេសាទដោយកែលម្អការទទួលបានការអប់រំសំរាប់កុមារ ដែលមានអាយុត្រូវសិក្សា និងឱកាសការងារសំរាប់យុវជន ហើយបញ្ចូលបញ្ហាពលកម្មកុមារទៅក្នុងផែនការវិនិយោគឃុំ។

*៤. យន្តការសម្របសម្រួល ការពិនិត្យតាមដាន និងការវាយតម្លៃ*

គោលបំណងនេះរួមមានការបង្កើតវេទិកា និងយន្តការជាក់លាក់ឯទៀតដើម្បី សម្រេចឱ្យបានផែនការ

22 រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១២៖ សង្ខេប កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីពលកម្មកុមារក្នុងវិស័យជលផល. ភ្នំពេញ. កំណត់ហេតុព្រាង ២២ ដល់ ២៣ កុម្ភៈ ២០១២ ( Phnom Penh, FiA/MAFF )។

23 រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១២៖ ផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ( Phnom Penh, FiA/MAFF )។

សកម្មភាពជាតិស្ដីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល តាមរយៈការបង្កើតអនុគណៈកម្មាធិការវិស័យជលផល នៅក្រោមអនុគណៈកម្មាធិការជាតិលុបបំបាត់ពលកម្មកុមារ ផ្ដល់ភារៈកិច្ចដល់គណៈកម្មាធិការយេនឌ័រ នៃរដ្ឋបាលជលផល ថ្នាក់ជាតិ និងខេត្តឱ្យទទួលខុសត្រូវលើបញ្ហាពលកម្មកុមារ ធ្វើឱ្យប្រសើរឡើងនូវ ទំនាក់ទំនងថ្នាក់ជាតិជាមួយគណៈកម្មាធិការពលកម្មកុមារថ្នាក់ខេត្ត និងថ្នាក់ឃុំ ហើយរកសូចនាករផលប៉ះពាល់សំរាប់ ផែនការសកម្មភាពជាតិស្ដីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល និងវាស់វែងផលប៉ះពាល់ទាំងនេះតាមរយៈសេចក្ដីរាយការណ៍ប្រចាំឆ្នាំ និងការវាយតំលៃផ្សេងៗទៀត។

## អ្វីដែលការអនុវត្តល្អនេះសម្រេចបានជោគជ័យ និងភស្តុតាងអំពីលទ្ធផលទាំងនោះ

ការសម្រេចជោគជ័យ នៃផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ត្រូវបានឯកភាពថាៈ ជាការអនុវត្តល្អមួយដោយក្រុមភាគីពាក់ព័ន្ធផ្សេងៗគ្នា៖

- ❖ ភាគីពាក់ព័ន្ធជាច្រើនក្នុងវិស័យជលផល រួមទាំងអ្នកតំណាង ៥០នាក់ មកពីសមាគមសហគមន៍នេសាទ ដែលបានចូលរួមក្នុងការបង្កើតផែនការ និងបានឯកភាពយល់ព្រមលើ ផែនការសកម្មភាពជាតិស្ដីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផលក្នុងកិច្ចពិគ្រោះយោបល់ ដែលបានប្រារព្ធធ្វើឡើងនៅដើមឆ្នាំ ២០១២[24]។



- ❖ ផែនការសកម្មភាពជាតិ ស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ត្រូវបានព្រមព្រៀងថាជាការអនុវត្តល្អមួយ ក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិដែលធ្វើឡើងនៅចុង ឆ្នាំ២០១២ ដើម្បីពិនិត្យឡើងវិញលើលទ្ធផលនៃការសិក្សាស្ដីពីការអនុវត្តល្អនេះ។ ក្នុងការពិភាក្សាតាមក្រុមអ្នកចូលរួមបានប្រើផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារ ក្នុងវិស័យជលផល ដើម្បីដឹកនាំពួកគេឱ្យបង្កើត ផែនការមួយដើម្បីលុបបំបាត់ទម្រង់ធ្ងន់ធ្ងរ នៃពលកម្មកុមារសំរាប់វិស័យផ្សេងៗទៀត។ អ្នកចូលរួមក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិ បាននិយាយថា ផែនការនៃវិស័យជលផល ជាគំរូល្អមួយ ពីព្រោះវាបានរាយការណ៍អំពី សមាសភាគគន្លឹះទាំងអស់ដែលត្រូវពិចារណា ក្នុងការបង្កើតផែនការលុបបំបាត់ពលកម្មកុមារសំរាប់វិស័យផ្សេងៗទៀត។
- ❖ ផែនការសកម្មភាពជាតិ ស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ត្រូវបានព្រមព្រៀងនៅថ្នាក់កំពូលនៃរាជរដ្ឋាភិបាល។ ទាំងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអនុគណៈកម្មាធិការជាតិពលកម្មកុមារបានអនុម័ត យល់ព្រមលើផែនការសកម្មភាពជាតិស្ដីពី ការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល។ ដូចបានរៀបរាប់ពីខាងលើ ការយល់ព្រមពីថ្នាក់ខ្ពស់នេះមានន័យថា អ្នកដែលទទួលខុស ត្រូវអនុវត្តផែនការនេះ នឹងមានការគាំទ្រដែលពួកគេត្រូវការក៏ដូចជាសំពាធដើម្បីធ្វើការងារបានលទ្ធផលល្អ។
- ❖ ដោយមានការបង្កើតផែនការប្រឆាំងពលកម្មកុមារយ៉ាងទូលំទូលាយសំរាប់វិស័យជលផល រដ្ឋបាលជលផលរំពឹងថា នឹងទទួលការផ្ដល់មូលនិធិ ចាប់ផ្ដើមពីឆ្នាំ ២០១៣ ដើម្បីអនុវត្តផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ។

## បញ្ហាប្រឈម និងមេរៀនបទពិសោធន៍

- ❖ ការបង្កើត ផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល ត្រូវចំណាយពេលច្រើនជាងការរំពឹងទុកពីព្រោះ រដ្ឋបាលជលផលដែលមានបុគ្គលិកតិចតួច ហើយពួកគេមានការងារច្រើន។

24 រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១២៖ ផែនការសកម្មភាពជាតិស្ដីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល នៅកម្ពុជា ២០១២ ( Phnom Penh, FiA/MAFF )។

ការបង្កើតផែនការលុបបំបាត់ពលកម្មកុមារ សំរាប់វិស័យផ្សេងៗ ត្រូវប្រើពេលវេលាច្រើនជាង១៨ខែ ដើម្បីធ្វើផែនការស្រាវជ្រាវ ពិគ្រោះយោបល់យ៉ាងទូលំទូលាយអំពីអ្វីដែលគួរដាក់បញ្ចូលក្នុងផែនការហើយបន្ទាប់មកទទួលការអនុម័តសំរេចលើផែនការនេះពីថ្នាក់លើ។

- រដ្ឋបាលជលផលបានព្យាយាម អស់រយៈពេលជាច្រើនឆ្នាំដើម្បីរកការផ្តល់មូលនិធិពីម្ចាស់ជំនួយដើម្បី ធ្វើការងារលើគំនិតផ្តួចផ្តើមដើម្បីបញ្ចប់ពលកម្មកុមារ ប៉ុន្តែកាលពីមុនរដ្ឋបាលជលផល មិនបានទទួលជោគជ័យទេពីព្រោះម្ចាស់ជំនួយ មានចំណាប់អារម្មណ៍តែផ្តល់ជំនួយដល់កិច្ចប្រឹងប្រែង ដើម្បីការពារ និងលើកស្ទួយសន្និធិមច្ឆជាតិតែប៉ុណ្ណោះ។



## ល័ក្ខខ័ណ្ឌគន្លឹះសំរាប់ប្រតិបត្តិតាមដោយជោគជ័យ និងនិរន្តរភាពនៃការអនុវត្តល្អនេះក្នុងវិស័យផ្សេងទៀត

- ផែនការតាមវិស័យមួយ ដើម្បីបញ្ចប់ពលកម្មកុមារត្រូវតែដោះស្រាយរាល់សមាសភាគជាគន្លឹះទាំងអស់ដែលការស្រាវជ្រាវបង្ហាញថា ជាសារៈសំខាន់ក្នុងវិស័យ។ ក្នុងករណីនៃវិស័យជលផល ត្រូវផ្តល់ការអប់រំក្រៅប្រព័ន្ធដើម្បីជួយកុមារឱ្យរៀនទាន់ មិត្តរបស់ខ្លួនដែលមានអាយុដូចគ្នានៅក្នុងសាលារដ្ឋ រីឯសាលាត្រូវមានទីតាំងនៅជិត សហគមន៍នេសាទ។កុមារវ័យជំទង់ក៏ត្រូវទទួលបានវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ចំណែកឯឪពុកម្តាយក៏ត្រូវការវគ្គបណ្តុះបណ្តាលដើម្បីកែលំអការបង្កើនប្រាក់ចំណូលរបស់គ្រួសារដើម្បីពួកគេមិនចាំបាច់ឱ្យកូនទៅធ្វើការ។

- ដើម្បីអនុវត្តផែនការលុបបំបាត់ ពលកម្មកុមារ ត្រូវប្រើស្ថាប័នសហគមន៍ក្នុងមូលដ្ឋាន។ ដូចបានរៀបរាប់ខាងលើ សហគមន៍នេសាទនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តផែនការសកម្មភាពជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារក្នុងវិស័យជលផល។

- ត្រូវផ្សព្វផ្សាយ ផែនការសកម្មភាពដើម្បីប្រយុទ្ធប្រឆាំងពលកម្មកុមារឱ្យបានទូលំទូលាយនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ដើម្បីកៀរគរធនធាន និងមនុស្ស។

- មានថវិកាគ្រប់គ្រាន់ដើម្បីធ្វើកិច្ចប្រជុំពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដើម្បី អាចឱ្យពួកគេដើរតួនាទីក្នុងការរៀបចំផែនការតាមវិស័យ ធានាថា ផែនការនេះអាចធ្វើបានឱ្យពួកគេប្រកាន់យកភាពម្ចាស់ការ លើផែនការនិងអាចឱ្យពួកគេមានឆន្ទៈអនុវត្តអ្វី ដែលរំពឹងថាពួកគេធ្វើ។

- ចាត់តាំងជនទាំងឡាយ ដែលធ្វើការលើគំនិតផ្តួចផ្តើមយេនឌ័រឱ្យធ្វើការ លើបញ្ហាពលកម្មកុមារផងដែរ។ ក្នុងករណីវិស័យជលផល បុគ្គលិករដ្ឋបាលជលផលដែលធ្វើការងារផ្នែកយេនឌ័រ ឱ្យមានការទទួលខុសត្រូវលើពលកម្មកុមារផងដែរ។ ជាផលត្រឡប់មកវិញ ជនបង្គោលយេនឌ័រ និងបុគ្គលិករដ្ឋបាលជលផលនឹងធ្វើការជាមួយជនបង្គោលយេនឌ័រក្នុងសមាគមសហគមន៍នេសាទ និងជាមួយថ្នាក់ខេត្ត និងថ្នាក់ឃុំគឺគណៈកម្មាធិការទទួលបន្ទុកស្ត្រី និងកុមារ ក៏មានការទទួលខុសត្រូវផងដែរលើកិច្ចការបញ្ឈប់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ។





កម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារ (IPEC)
ការិយាល័យអង្គការពលកម្មអន្តរជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
អគារសហប្រជាជាតិជាន់ទី១០ មហាវិថី **Rajdamnern Nok**
ប្រអប់សំបុត្រលេខ ២-៣៤៩
បាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទ៖ (៦៦២) ២៨៨ ២២១៩
ទូរសារ៖ (៦៦២) ២៨៨ ៣០៥៨
**www.ilo.org/bangkok - www.ilo.org/ipec**

ISBN 978-92-2-828985-5
9 789228 289855